ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# យុទ្ធសាស្ត្រ
# ស្តីពី
# ការគ្រប់គ្រងបំណុលសាធារណៈ
# ២០២៤ - ២០២៨

ខែកក្កដា ឆ្នាំ២០២៤

# បុព្វកថា

រាជរដ្ឋាភិបាលយល់ច្បាស់ពីសារៈសំខាន់ និងតួនាទីនៃការគ្រប់គ្រងបំណុលសាធារណៈ ក្នុងការរួមចំណែកគាំទ្រការអនុវត្តគោលនយោបាយសារពើពន្ធ, ការគ្រប់គ្រងនិងរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ការជំរុញអភិវឌ្ឍវិស័យហិរញ្ញវត្ថុ, ការពង្រីកមូលដ្ឋានសេដ្ឋកិច្ច, ការអភិវឌ្ឍតាមវិស័យអាទិភាព, និងការទ្រទ្រង់ចីរភាពកំណើនក្នុងរយៈពេលវែង។ តាមរយៈនេះ, ដោយឈរលើគោលការណ៍គន្លឹះដែលបានប្រកាន់ខ្ជាប់តាំងពីឆ្នាំ១៩៩៣មក រាជរដ្ឋាភិបាលបានអនុម័ត និងដាក់ឱ្យអនុវត្តនូវ យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈចំនួន ៣លើករួចមកហើយ ក្នុងនោះ៖ លើកទី១ សម្រាប់ឆ្នាំ២០១១ - ២០១៨, លើកទី២ សម្រាប់ឆ្នាំ២០១៥ - ២០១៨ ដែលជាការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រលើកទី១, និងលើកទី៣ សម្រាប់ឆ្នាំ២០១៩ - ២០២៣ ស្របតាមអាណត្តិរបស់រាជរដ្ឋាភិបាល។

ក្នុងស្មារតីប្រយ័ត្នប្រយែងខ្ពស់ និងអនុវត្តដោយគ្មានវាងវៀងនូវគោលការណ៍គន្លឹះ និងវិធានការពាក់ព័ន្ធនានាដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រទាំង ៣ លើកខាងលើ រួមទាំងកិច្ចខិតខំប្រឹងប្រែងនារយៈកាលកន្លងមករបស់រាជរដ្ឋាភិបាល, បច្ចុប្បន្ន រាជរដ្ឋាភិបាល កសាងបាននូវប្រព័ន្ធគ្រប់គ្រងបំណុលសាធារណៈមួយដ៏រឹងមាំ ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ ព្រមទាំងមានការទទួលស្គាល់ពីដៃគូអភិវឌ្ឍ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗជាច្រើនដែលថា កម្ពុជាជាប្រទេសគំរូមួយ ដែលគ្រប់គ្រងបំណុលសាធារណៈបានល្អប្រសើរ។ ជាសក្ខីភាព, ស្ថាប័នហិរញ្ញវត្ថុធំៗមួយចំនួនបានវាយតម្លៃ និងផ្តល់ពិន្ទុសូចនាករគោលនយោបាយ និងការគ្រប់គ្រងបំណុលសាធារណៈដល់កម្ពុជា ក្នុងកម្រិត ៥,០ ពិន្ទុ (ធៀបនឹងពិន្ទុអតិបរមា ៦,០) ដែលជាពិន្ទុខ្ពស់ជាងគេធៀបនឹងបណ្តាប្រទេសមានកម្រិតអភិវឌ្ឍប្រហាក់ប្រហែលគ្នា ហើយមានប្រទេសតិចតួចប៉ុណ្ណោះដែលទទួលបានពិន្ទុនេះ។

ប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុលសាធារណៈរបស់កម្ពុជា បានរួមចំណែកយ៉ាងសំខាន់ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តធំៗ ដែលជាជន្ទល់នៃសេដ្ឋកិច្ច និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ ជាអាទិ៍៖ ផ្លូវថ្នល់, ស្ពាន, ផ្លូវដែក, កំពង់ផែ, អាកាសយានដ្ឋាន, រោងចក្រផលិតថាមពលអគ្គិសនី, បណ្តាញបញ្ជូន និងចែកចាយថាមពលអគ្គិសនី, ស្ថានីយ៍ផលិតនិងបណ្តាញផ្គត់ផ្គង់ទឹកស្អាត, ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់, ប្រព័ន្ធធារាសាស្ត្រ, មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ, ការលើកកម្ពស់គុណភាពអប់រំ និងការផ្តល់សេវាសុខាភិបាល ជាដើម។

ទន្ទឹមនឹងការសម្រេចបាននូវសមិទ្ធផលជាទីមោទនៈនេះ, រាជរដ្ឋាភិបាលពិនិត្យឃើញថា ស្ថានការណ៍នយោបាយសកលក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ នៅតែបន្តមានភាពផុយស្រួយ និងប្រឈមនឹងភាពតានតឹងខ្លាំងឡើង ដែលអាចជះឥទ្ធិពលដល់និន្នាការសេដ្ឋកិច្ចទាំងក្នុងកម្រិតសកល, តំបន់, និងប្រទេស ឱ្យកាន់តែមានភាពស្មុគស្មាញ និងពិបាកព្យាករ ខណៈដែលបញ្ហាបំណុល បាននិងកំពុងក្លាយជាកង្វល់របស់ប្រទេសនានាលើសកលលោក។

ឆ្លើយតបទៅនឹងសភាពការណ៍ខាងលើ និងក្នុងបរិការណ៍នៃការវិវត្តន៍ឈានឡើងជាលំដាប់នៃសង្គម-សេដ្ឋកិច្ចកម្ពុជា ព្រមទាំងដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១, រាជរដ្ឋាភិបាល សម្រេចដាក់ឱ្យអនុវត្តនូវ «យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨» ដោយនឹងត្រូវបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់ ប្រកបដោយភាពប្រយ័ត្នប្រយែងខ្ពស់ និងអាចមានភាពបត់បែនតាមសភាពការណ៍ពិភពលោក, តំបន់, និងបរិការណ៍របស់កម្ពុជា នូវគោលការណ៍គន្លឹះទាំង៥ ដែលរួមមាន៖

១) ខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន;

២) ខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះ;

៣) ខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម;

៤) ប្រើប្រាស់ឥណទាន ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធភាពខ្ពស់បំផុត

៥) ប្រើប្រាស់ឥណទានសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលត្រូវមានស្តង់ដា និងគុណភាពខ្ពស់ ស្របតាមគោលការណ៍នៃការគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិនៅក្នុងដំណាក់កាលថ្មី ពិសេស ធានាបាននូវចីរភាពសេដ្ឋកិច្ច, សង្គម, បរិស្ថាន, និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

យុទ្ធសាស្ត្រនេះ ដាក់ចេញនូវបណ្តាវិធានការគន្លឹះជាអាទិភាព ក្នុងគោលបំណងធានានូវប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ រួមទាំងមូលបត្ររដ្ឋ សំដៅរួមចំណែកបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន ឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមធ្វើការវាយតម្លៃខ្ពស់ចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធដែលបានសកម្មចូលរួមអនុវត្តយ៉ាងម៉ឺងម៉ាត់នូវរាល់គោលការណ៍គន្លឹះៗ និងវិធានការពាក់ព័ន្ធ ដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈទាំង ៣ លើកកន្លងមក និងសូមកោតសរសើរចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមការដឹកនាំរបស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចយ៉ាងខ្ជាប់ខ្ជួន លើការរៀបចំ និងតាមដានការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ក៏ដូចជាការរៀបចំ «យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨» នេះឡើង ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាជាមួយនឹងគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល។

ជាទីបញ្ចប់, ខ្ញុំសូមឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ត្រូវបន្តសហការពេញលេញជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការអនុវត្តរាល់គោលការណ៍គន្លឹះៗ និងវិធានការ ដែលបានដាក់ចេញនៅក្នុង «យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨» ប្រកបដោយប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់បំផុត។

ថ្ងៃ សុក្រ ៦ រោច ខែ អាសាឍ ឆ្នាំ រោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# មាតិកា


**បុព្វកថា** ........ i

**ខ្លឹមសារសង្ខេប** ........ v

**ជំពូកទី១៖ សេចក្តីផ្តើម** ........ ១

**ជំពូកទី២៖ គោលបំណង គោលដៅ និងវិសាលភាព** ........ ៣

២.១. គោលបំណង និងគោលដៅ ........ ៣

២.២. វិសាលភាព ........ ៣

**ជំពូកទី៣៖ វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្រ្តស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣** ........ ៤

៣.១. ការកៀរគរហិរញ្ញប្បទាន ........ ៤

៣.២. ការគ្រប់គ្រងបំណុលសាធារណៈ ........ ៥

៣.២.១. ថ្លៃ និងហានិភ័យបំណុល ........ ៥

៣.២.២. ស្ថានភាពបំណុលសាធារណៈ ........ ៦

៣.៣. ការផ្តល់ឥណទានរបស់រដ្ឋ ........ ៩

៣.៤. វឌ្ឍនភាពការងារពាក់ព័ន្ធផ្សេងទៀត ........ ៩

**ជំពូកទី៤៖ បញ្ហាប្រឈម និងកាលានុវត្តភាព** ........ ១២

៤.១.បញ្ហាប្រឈម ........ ១២

៤.១.១. ស្ថានការណ៍សេដ្ឋកិច្ចសកល ........ ១២

៤.១.២. កំណើនថ្លៃដើមហិរញ្ញប្បទាន ........ ១២

៤.១.៣. ចំណាត់ថ្នាក់ឥណទានរបស់ប្រទេសកម្ពុជានៅមានកម្រិត ........ ១២

៤.១.៤. ធនធានមនុស្សក្នុងកិច្ចការគ្រប់គ្រងបំណុលសាធារណៈ និងកិច្ចការពាក់ព័ន្ធ ........ ១២

៤.២. កាលានុវត្តភាព ........ ១៣

៤.២.១. សមត្ថភាពនៃការខ្ចីថ្មីបន្ថែម ........ ១៣

៤.២.២. ប្រភពហិរញ្ញប្បទានពីក្រៅប្រទេស ........ ១៣

៤.២.៣. ការអភិវឌ្ឍមូលបត្ររដ្ឋ ........ ១៤

៤.២.៤. ការចូលរួមពីវិស័យឯកជនក្នុងការវិនិយោគសាធារណៈ ........ ១៥

៤.២.៥. ការគាំទ្របច្ចេកទេសពីដៃគូអភិវឌ្ឍ ........ ១៥

**ជំពូកទី៥៖ ការវិភាគបំណុល** ........ ១៦

៥.១. បទដ្ឋានបច្ចេកទេសក្នុងការវិភាគ ........ ១៦

៥.២. សេណារីយ៉ូនៃការខ្ចី ........ ១៧

៥.៣. សូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗសម្រាប់ការវិភាគ ........ ១៨

៥.៤. លទ្ធផលនៃការវិភាគ ........ ១៩

**ជំពូកទី៦៖ វិធានការជាយុទ្ធសាស្រ្ត** ........ ២៤

៦.១. កំណត់ពិតាននៃការខ្ចីប្រាក់ពីគេ ........ ២៤

៦.២. កំណត់ពិតាននៃការធានារបស់រដ្ឋ ..... ២៤

៦.៣. កំណត់ពិតានសូចនាករបំណុលគន្លឹះៗ ..... ២៤

៦.៣.១. សូចនាករចីរភាពបំណុល ..... ២៤

៦.៣.២.សូចនាករថ្លៃ និងហានិភ័យបំណុល ..... ២៤

៦.៤. កំណត់គោលការណ៍នៃការប្រើប្រាស់ហិរញ្ញប្បទានពីការខ្ចីប្រាក់ពីគេ ..... ២៥

៦.៥. បន្តធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យបានទូលំទូលាយ ..... ២៥

៦.៥.១. ស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍក្រៅប្រទេស ..... ២៥

៦.៥.២. ការបោះផ្សាយលក់មូលបត្ររដ្ឋ ..... ២៥

៦.៥.៣. ប្រភពដទៃទៀត ..... ២៦

៦.៦. បន្តពង្រឹងការតាមដាន និងគ្រប់គ្រងលើហានិភ័យបំណុលពាក់ព័ន្ធ ..... ២៦

៦.៧. បន្តអនុវត្តគោលការណ៍មជ្ឈការនៃការគ្រប់គ្រងបំណុលសាធារណៈ ..... ២៦

៦.៨. បន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការឱ្យប្រាក់គេខ្ចី ..... ២៧

៦.៩. បន្តអនុវត្តគោលនយោបាយ និងកម្មវិធីកែទម្រង់ក្នុងវិស័យសំខាន់ៗ ..... ២៧

៦.១០. បន្តពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ..... ២៨

**ជំពូកទី៧៖ យន្តការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈម** ..... ២៩

៧.១. យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ..... ២៩

៧.២. យន្តការដោះស្រាយបញ្ហាប្រឈម ..... ២៩

**ជំពូកទី៨៖ សេចក្តីសន្និដ្ឋាន** ..... ៣០


**ឧបសម្ព័ន្ធ៖**


- ឧបសម្ព័ន្ធទី១៖ សទ្ទានុក្រម
- ឧបសម្ព័ន្ធទី២៖ ផែនការសកម្មភាព
- ឧបសម្ព័ន្ធទី៣៖ ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស

# ខ្លឹមសារសង្ខេប

ក្នុងរយៈពេល ២៥ឆ្នាំ ចុងក្រោយនេះ, កម្ពុជាសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន លើគ្រប់វិស័យ ជាពិសេសការសម្រេច និងរក្សាបាននូវចីរភាពនៃសុខសន្តិភាព និងស្ថិរភាពនយោបាយ ដែលជាបុព្វលក្ខខណ្ឌមិនអាចខ្វះបាន និងជាមូលដ្ឋានដ៏រឹងមាំសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។ ជាតថភាព, កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យមជាង ៧% ក្នុងមួយឆ្នាំ នៅមុនវិបត្តិនៃជំងឺកូវីដ-១៩ និងបានប្រែក្លាយពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅក្នុងឆ្នាំ២០១៥ និងកំពុងត្រៀមចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ព្រមទាំងបានបោះជំហានឆ្ពោះទៅមុខ ដើម្បីក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

បើទោះជាប្រឈមនឹងវិបត្តិនៃជំងឺកូវីដ-១៩ និងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកលក៏ដោយ ក៏កម្ពុជាអាចមានលទ្ធភាពគ្រប់គ្រងស្ថានការណ៍បានដោយជោគជ័យ ព្រមទាំងអាចស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញបានយ៉ាងឆាប់រហ័ស ហើយស្ថានភាពបំណុលសាធារណៈរបស់កម្ពុជានៅតែមាន «**ចីរភាព**» និង «**ហានិភ័យកម្រិតទាប**» ដោយរាល់សូចនាករបំណុលគន្លឹះៗទាំងអស់សុទ្ធតែស្ថិតក្រោមពិតានកំណត់ ក្នុងនោះ សូចនាករតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹង ផសស ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ មានជាមធ្យមត្រឹមរង្វង់ **១៨%** ប៉ុណ្ណោះ ធៀបនឹងអនុបាតគោល **៤០%**។

ទន្ទឹមនឹងការសម្រេចបាននូវលទ្ធផលខាងលើ និងក្នុងស្ថានការណ៍ដែលនយោបាយសកលនៅតែបន្តមានភាពផុយស្រួយ ហើយក្នុងបរិការណ៍ថ្មីនៃការវិវត្តឈានឡើងជាលំដាប់នៃសេដ្ឋកិច្ចកម្ពុជា ដែលក្នុងនោះកម្ពុជាមានសមត្ថភាពក្នុងការខ្ចីបន្ថែម, មានលទ្ធភាពក្នុងការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានបន្ថែមតាមរយៈការបោះផ្សាយលក់មូលបត្ររដ្ឋ និងពីវិស័យឯកជន, និងមានដៃគូអភិវឌ្ឍជាច្រើនត្រៀមផ្តល់កិច្ចសហប្រតិបត្តិការ ព្រមទាំងដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១, រាជរដ្ឋាភិបាលចាំបាច់ត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ឱ្យកាន់តែគត់មត់ និងគ្រប់ជ្រុងជ្រោយបន្ថែមទៀត។

ក្នុងន័យនេះ, រាជរដ្ឋាភិបាលសម្រេចដាក់ឱ្យអនុវត្តនូវ «**យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨**» ក្នុងគោលបំណងធានានូវប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ រួមទាំងមូលបត្ររដ្ឋ សំដៅរួមចំណែកក្នុងការបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្ន ឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ យុទ្ធសាស្ត្រនេះមានវិសាលភាពគ្របដណ្តប់លើរាល់ប្រតិបត្តិការពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ (រួមមាន៖ ការខ្ចីប្រាក់ពីគេ, ការឱ្យប្រាក់គេខ្ចី, ការធានារបស់រដ្ឋ, និងការគ្រប់គ្រងហានិភ័យបំណុល រួមទាំងកាតព្វកិច្ចបំណុលជាយថាហេតុ) និងការតាមដានលើស្ថានភាព និងនិន្នាការនៃបំណុលរបស់វិស័យឯកជន សំដៅរួមចំណែកគ្រប់គ្រងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេលមធ្យម និងវែង។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ យុទ្ធសាស្ត្រនេះ មានគោលដៅកំណត់នូវវិធានការជាយុទ្ធសាស្ត្រក្នុងការកៀរគរនិងសម្រិតសម្រាំងធនធានហិរញ្ញវត្ថុ ដែលមានថ្លៃដើម និងហានិភ័យទាប ដើម្បីបំពេញតម្រូវការទុនវិនិយោគសាធារណៈសរុប ប្រកបដោយប្រសិទ្ធភាព និងបន្តរក្សាបាននូវចីរភាពបំណុលសាធារណៈរយៈពេលមធ្យម និងវែង ព្រមទាំងគាំទ្រការអភិវឌ្ឍមូលបត្ររដ្ឋ ដើម្បីធ្វើពិពិធកម្មប្រភពហិរញ្ញប្បទាន តាមរយៈការប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះទាំង ៥ និងដាក់ចេញនូវបណ្តាវិធានការគន្លឹះជាអាទិភាពក្នុងការគ្រប់គ្រងបំណុលសាធារណៈ ដូចខាងក្រោម៖

១. កំណត់ពិតាននៃការខ្ចីប្រចាំឆ្នាំ ក្នុងនោះ៖ i) ការខ្ចីពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍក្រៅប្រទេស ក្នុងរង្វង់ **១,៧ ប៊ីលាន** ទៅ **២ ប៊ីលានអេសឌីអ័រ** ក្នុងមួយឆ្នាំ ហើយក្នុងកាលៈទេសៈចាំបាច់ អាចបង្កើនដល់ **២,៥ ប៊ីលានអេសឌីអ័រ** ក្នុងមួយឆ្នាំ ប៉ុន្តែ មិនត្រូវលើសពី **១០ ប៊ីលានអេសឌីអ័រ** (សមមូលនឹងប្រមាណ **១៣,៥ ប៊ីលានដុល្លារអាម៉េរិក**) ក្នុងរយៈពេល ៥ឆ្នាំ និង ii) ការបោះផ្សាយលក់មូលបត្ររដ្ឋក្នុងប្រទេសក្នុងរង្វង់ **៥០០ ប៊ីលាន** ទៅ **១ ទ្រីលានរៀល** ក្នុងមួយឆ្នាំ ហើយក្នុងកាលៈទេសៈចាំបាច់ អាចបង្កើនដល់ **១,២ ទ្រីលានរៀល** ក្នុងមួយឆ្នាំ ប៉ុន្តែ មិនត្រូវលើសពី **៤ ទ្រីលានរៀល** (សមមូលនឹងប្រមាណ **១ ប៊ីលានដុល្លារអាម៉េរិក**) ក្នុងរយៈពេល ៥ឆ្នាំ។

២. កំណត់ពិតាននៃការធានារបស់រដ្ឋ ក្នុងនោះ៖ i) ការធានាទូទាត់សរុបប្រចាំឆ្នាំចំពោះគម្រោងថ្មី មិនត្រូវលើសពី **១០%** នៃចំណូលថវិកាជាតិនាឆ្នាំកន្លងទៅ (Accumulate of Annual Payment Guarantee of New Projects as of Year N < **10%** of Total Domestic Revenue of Year N-1) និង ii) បន្តមិនផ្តល់ការធានាឥណទាន (Credit/Loan Guarantee) ដោយផ្ទាល់ពីរដ្ឋចំពោះវិស័យឯកជន។

៣. កំណត់ពិតានសូចនាករបំណុលគន្លឹះៗ ដោយរួមទាំងពិតានសូចនាករចីរភាពបំណុល និងពិតានសូចនាករថ្លៃ និងហានិភ័យបំណុល ដែលត្រូវគ្រប់គ្រង និងតាមដាន ដូចខាងក្រោម៖
- អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប ធៀបនឹង ផសស ត្រូវស្ថិតក្រោម **៥៥%**។
- អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផសស ត្រូវស្ថិតក្រោម **៤០%**។
- អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ ត្រូវស្ថិតក្រោម **១៨០%**។
- អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ ត្រូវស្ថិតក្រោម **១៥%**។
- អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ចំណូលថវិកាជាតិ ត្រូវស្ថិតក្រោម **១៨%**។
- មធ្យមទម្ងន់អត្រាការប្រាក់នៃសន្និធិបំណុលសាធារណៈសរុប ត្រូវស្ថិតក្រោម **៣%** ក្នុងមួយឆ្នាំ។
- រយៈពេលមធ្យមដល់ឥណប្រតិទាននៃសន្និធិបំណុលសាធារណៈសរុប ត្រូវមានយ៉ាងតិចរង្វង់ **៨ ឆ្នាំ**។
- បំណុលដែលត្រូវទូទាត់នៅឆ្នាំបន្ទាប់ ត្រូវស្ថិតក្រោម **១០%** នៃសន្និធិបំណុលសាធារណៈសរុប។
- សមាសភាគបំណុលសាធារណៈជាប្រភេទអត្រាការប្រាក់ថេរ ត្រូវមានយ៉ាងតិចរង្វង់ **៩០%** នៃសន្និធិបំណុលសាធារណៈសរុប។

៤. កំណត់គោលការណ៍នៃការប្រើប្រាស់ហិរញ្ញប្បទានពីការខ្ចីប្រាក់ពីគេ ដូចខាងក្រោម៖
- ចំពោះហិរញ្ញប្បទានដែលកៀរគរតាមរយៈការខ្ចីពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍក្រៅប្រទេស ត្រូវប្រើប្រាស់សម្រាប់វិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ជាពិសេស ការបង្កើនផលិតភាពផលិតកម្ម, ការជំរុញការតភ្ជាប់, និងការលើកកម្ពស់សមត្ថភាពប្រកួតប្រជែង ដូចជា៖ ផ្លូវថ្នល់, ស្ពាន, ប្រព័ន្ធស្រោចស្រព, អគ្គិសនី, កំពង់ផែ, ការផ្គត់ផ្គង់ទឹកស្អាតនៅទីប្រជុំជន, ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់, ការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម, ឡូជីស្ទីក, ឌីជីថល ជាដើម។ ទន្ទឹមនេះ, គម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈទាំងនោះ ត្រូវមានស្តង់ដា និងគុណភាពខ្ពស់ ស្របតាមគោលការណ៍គ្រឹះនៃការគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិនៅក្នុងដំណាក់កាលថ្មី ពិសេសធានាបាននូវចីរភាពសេដ្ឋកិច្ច, សង្គម, បរិស្ថាន, និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ បន្ថែមលើនេះ, ចំពោះគម្រោងណាដែលអាចបង្កើតចំណូលដោយផ្ទាល់ ត្រូវអនុវត្តតាមយន្តការឱ្យខ្ចីបន្ត ឬយន្តការផ្សេងទៀតដែលមានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

- ចំពោះទុនបានពីការបោះផ្សាយលក់មូលបត្ររដ្ឋក្នុងប្រទេស ត្រូវប្រើប្រាស់ជាអាទិភាពសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈ ស្របតាមច្បាប់ស្តីពីមូលបត្ររដ្ឋ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ព្រមទាំងត្រូវគោរពតាមគោលការណ៍ចីរភាពបំណុលសាធារណៈ។ គម្រោងវិនិយោគសាធារណៈដែលហិរញ្ញប្បទានដោយទុនបានពីការបោះផ្សាយលក់មូលបត្ររដ្ឋក្នុងប្រទេស ត្រូវតែជាៈ ១) គម្រោងដែលអាចហុចផលចំណេញផ្នែកសេដ្ឋកិច្ច ឬហិរញ្ញវត្ថុភ្លាមៗ និង ២) គម្រោងតាមយន្តការឱ្យខ្ចីបន្តដែលអាចបង្កើតចំណូលដោយផ្ទាល់ ហើយផ្តល់ផលហិរញ្ញវត្ថុដែលអាចទូទាត់ថ្លៃដើមនៃឥណទានបាន ឬផលសេដ្ឋកិច្ចខ្ពស់; ដោយឡែក ក្នុងករណីតម្រូវឱ្យមានការឧបត្ថម្ភធនសម្រាប់គម្រោងឱ្យខ្ចីបន្ត គឺត្រូវមានការគណនាច្បាស់លាស់ និងត្រូវស្ថិតក្នុងភាពទ្រទ្រង់បាននៃថវិកាជាតិ និងក្នុងក្របខ័ណ្ឌនៃការធានាបាននូវចីរភាពបំណុលសាធារណៈ ព្រមទាំងប្រសិទ្ធភាពសេដ្ឋកិច្ចរបស់គម្រោង។

៥. បន្តធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យកាន់តែទូលំទូលាយ ពីគ្រប់ប្រភពទាំងអស់ ដោយរួមទាំងពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍក្រៅប្រទេស, ពីការបោះផ្សាយលក់មូលបត្ររដ្ឋ, និងពីប្រភពដទៃទៀត ដោយរាជរដ្ឋាភិបាលនឹងៈ

- បន្តពង្រឹងកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍក្រៅប្រទេសដែលមានស្រាប់ដើម្បីអាចកៀរគរហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់។
- ពង្រីកកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍក្រៅប្រទេសថ្មីផ្សេងទៀត។
- សិក្សារៀបចំឯកសារទស្សនាទានស្តីពី «ផែនការអន្តរកាល (Transition Plan)» ដើម្បីកៀរគរហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានកម្រិតសម្បទានឬលក្ខខណ្ឌអនុគ្រោះខ្ពស់ សម្រាប់បំពេញតម្រូវការវិនិយោគសាធារណៈ ដែលបន្សាំនឹងការប្រែប្រួលអាកាសធាតុ (Climate Adaptation)។
- បន្តរក្សាភាពបត់បែនក្នុងការទទួលយកឥណទានដែលមានកម្រិតសម្បទាន មធ្យម ឬទាប អាស្រ័យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ច, លទ្ធភាពថវិកាជាតិ, និងករណីគម្រោងវិនិយោគសាធារណៈនីមួយៗ។ ក្នុងករណីពិនិត្យឃើញថា អត្រាការប្រាក់នៃឥណទានរបស់ដៃគូអភិវឌ្ឍ មាននិន្នាការកើនឡើងខ្ពស់ ដែលកម្ពុជាពុំអាចទទួលយកបាន រាជរដ្ឋាភិបាលនឹងពិចារណាផ្អាកដកសាច់ប្រាក់ ឬ ផ្អាកខ្ចី ហើយស្វែងរកប្រភពហិរញ្ញប្បទានផ្សេងមកជំនួស។
- បន្តអភិវឌ្ឍមូលបត្ររដ្ឋ តាមរយៈការអនុវត្តផែនការសកម្មភាព ដែលបានដាក់ចេញក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨។
- សិក្សាលម្អិតលើជម្រើសក្នុងការបោះផ្សាយលក់មូលបត្ររដ្ឋជាដុល្លារអាមេរិក និង/ឬ ការអនុវត្តវិធីសាស្ត្រ FX-Linked Bonds ដើម្បីបង្កើនឱ្យមានការចូលរួមកាន់តែច្រើនពីវាល់វិនិយោគិនសក្តានុពល។
- បន្តខិតខំកៀរគរហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានកម្រិតសម្បទានឬលក្ខខណ្ឌអនុគ្រោះខ្ពស់ ពីប្រភពផ្សេងទៀតឱ្យបានច្រើនបំផុត តាមដែលអាចធ្វើបាន តាមវិធីសាស្ត្រហិរញ្ញប្បទានចម្រុះ ដើម្បីកាត់បន្ថយថ្លៃដើម និងហានិភ័យនៃការខ្ចី ក្នុងករណីហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុនិងដៃគូអភិវឌ្ឍក្រៅប្រទេស និងពីការបោះផ្សាយលក់មូលបត្ររដ្ឋ មានអត្រាការប្រាក់ខ្ពស់ ឬប្រឈមនឹងហានិភ័យទីផ្សារខ្លាំង ឬតម្រូវឱ្យអនុវត្តតាមគោលការណ៍បៃតង។
- ខ្ចីឥណទានសម្បទាន ឬប្រើប្រាស់ធនធានរបស់រដ្ឋពីប្រភពផ្សេងទៀត ដើម្បីទាក់ទាញទុនពីវិស័យឯកជន តាមរយៈយន្តការហិរញ្ញប្បទានចម្រុះ, យន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន, និងការវិនិយោគផ្ទាល់ ប៉ុន្តែ ត្រូវមានការប្រុងប្រយ័ត្នក្នុងការផ្តល់ការធានារបស់រដ្ឋចំពោះគម្រោង PPP ដែលអាចបង្កជាហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ មកលើស្ថានភាពបំណុលសាធារណៈ និងសម្ពាធលើថវិកាជាតិ។

- រៀបចំ «ក្របខ័ណ្ឌគោលនយោបាយហិរញ្ញប្បទានជាតិ» សម្រាប់ជាត្រីវិស័យតម្រង់ទិសការកៀរគរហិរញ្ញប្បទាន និងវិនិយោគ សម្រាប់គាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា។
- បន្តខិតខំកៀរគរហិរញ្ញប្បទានពីប្រភពផ្សេងៗទៀត ស្របតាមបទប្បញ្ញត្តិជាធរមាន។

៦. បន្តពង្រឹងការតាមដាន និងគ្រប់គ្រងលើហានិភ័យបំណុលពាក់ព័ន្ធ ដូចខាងក្រោម៖
- រៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ ដែលគ្របដណ្តប់នូវគ្រប់ហានិភ័យបំណុលពាក់ព័ន្ធទាំងអស់ ដោយរួមទាំងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលអាចកើតចេញពីការធានាទូទាត់របស់រដ្ឋ។
- ធនាគារជាតិនៃកម្ពុជា ត្រូវបន្តសិក្សា និងតាមដានលើស្ថានភាព និងនិន្នាការនៃបំណុលរបស់វិស័យឯកជន និងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលអាចកើតចេញពីវិស័យធនាគារ និងហិរញ្ញវត្ថុ ហើយចែករំលែកព័ត៌មាននិងទិន្នន័យទាំងនោះមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ត្រូវធ្វើការវាយតម្លៃការគ្រប់គ្រងបំណុលសាធារណៈ (DeMPA) ដើម្បីជាមូលដ្ឋានបន្តកែលម្អប្រព័ន្ធគ្រប់គ្រងបំណុលសាធារណៈ។

៧. បន្តអនុវត្តគោលការណ៍មជ្ឈការនៃការគ្រប់គ្រងបំណុលសាធារណៈ ដោយស្ថិតក្រោមលក្ខខណ្ឌ និងកម្រិតកំណត់នៃសិទ្ធិអំណាចដែលបានផ្តល់ក្នុងច្បាប់ហិរញ្ញវត្ថុ និងក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុម្នាក់គត់ ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ រួមបញ្ចូលនូវការបោះផ្សាយលក់មូលបត្ររដ្ឋ ការទទួលហិរញ្ញប្បទានឥតសំណង ការវិនិយោគលើទ្រព្យសកម្មហិរញ្ញវត្ថុ ការធានា និងការសន្យាផ្នែកហិរញ្ញវត្ថុនានា និងមានសិទ្ធិក្នុងការឱ្យប្រាក់គេខ្ចី ទាំងក្នុងនិងក្រៅប្រទេស។ ក្រៅពីនេះ គ្មានអ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតណាមួយមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ ឬឱ្យប្រាក់គេខ្ចី ឬចេញជាលិខិតធានា ឬក៏ធ្វើទង្វើណាផ្សេងៗទៀត ដោយផ្ទាល់ ឬដោយប្រយោល ដែលអាចនាំឱ្យកើតមាននូវបំណុល ឬបន្ទុកហិរញ្ញវត្ថុផ្សេងទៀតដោយផ្ទាល់ ឬដោយប្រយោលដល់ព្រះរាជាណាចក្រកម្ពុជាបានទេ។

៨. បន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការឱ្យប្រាក់គេខ្ចី ដោយបន្តអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ជាពិសេស ប្រកាសស្តីពីគោលការណ៍ និងនីតិវិធីគ្រប់គ្រងការផ្តល់ឥណទានដល់សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈ, នីតិបុគ្គលសាធារណៈដទៃទៀត, និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងសិក្សា និងរៀបចំគោលការណ៍ណែនាំសម្រាប់តាមដាន និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុរបស់ឥណាយិកដែលទទួលបានឥណទានពីរដ្ឋ។

៩. បន្តអនុវត្តគោលនយោបាយ និងកម្មវិធីកែទម្រង់ក្នុងវិស័យសំខាន់ៗ រួមមាន៖ i)កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ii) កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ, iii) កម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, និង iv) កម្មវិធីកែទម្រង់ពាក់ព័ន្ធផ្សេងទៀត របស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងអភិបាលកិច្ចក្នុងវិស័យសាធារណៈ សំដៅរួមចំណែកសម្រេចបាននូវចីរភាពកំណើនសេដ្ឋកិច្ច និងធ្វើឱ្យប្រសើរឡើងនូវពិន្ទុសូចនាករគោលនយោបាយ និងការគ្រប់គ្រងបំណុលសាធារណៈ និងចំណាត់ថ្នាក់ឥណទានរបស់កម្ពុជា ដែលនឹងជួយកាត់បន្ថយថ្លៃដើម និងហានិភ័យនៃការខ្ចី ក៏ដូចជា បង្កើនទំនុកចិត្ត និងទាក់ទាញវិស័យឯកជន មកចូលរួមវិនិយោគផងដែរ។ ក្នុងន័យនេះ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំបង្កើតយន្តការអន្តរក្រសួង ស្ថាប័ន ក្នុងការរៀបចំ «ក្របខ័ណ្ឌគោលនយោបាយស្តីពីការពង្រឹងចំណាត់ថ្នាក់ឥណទានរបស់ប្រទេស» ដើម្បីកំណត់ឱ្យបានជាក់លាក់នូវចក្ខុវិស័យ, បង្គោលចរ, វិធានការជាយុទ្ធសាស្ត្រ, និងផែនការសកម្មភាពសំដៅបង្កើនចំណាត់ថ្នាក់ឥណទានរបស់កម្ពុជា (Sovereign Credit Rating) ឱ្យឈានដល់កម្រិតខ្ពស់បំផុត (AAA) ត្រឹមឆ្នាំ២០៥០។

ទន្ទឹមនេះ, ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបន្តអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ (Public Investment Management System Reform Strategy) ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងអនុវត្តគម្រោងវិនិយោគសាធារណៈ ដោយត្រូវផ្សារភ្ជាប់ទៅនឹងគោលការណ៍សមិទ្ធកម្ម និងត្រូវអនុលោមតាមនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ (Standard Operating Procedures - SOPs - for All Externally Financed Projects/ Programs) ជាធរមាន។ ជាមួយនេះ, ត្រូវពង្រឹង និងពង្រីកយន្តការតាមដាន និងត្រួតពិនិត្យជាប្រចាំ ក្នុងដំណាក់កាលនៃការអនុវត្តគម្រោង ដើម្បីធានាការបិទបញ្ចប់គម្រោងតាមពេលកំណត់។ ការពន្យារពេលអនុវត្តគម្រោង អាចត្រូវបានអនុញ្ញាត មិនលើសពី ៣ឆ្នាំ និងត្រូវមានមូលហេតុសមស្រប។ ក្នុងករណីចាំបាច់បំផុត ដែលតម្រូវឱ្យពន្យារពេលអនុវត្តគម្រោងលើសពី ៣ឆ្នាំ, ក្រសួង ស្ថាប័ន តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវគោរពរាយការណ៍ជូននាយករដ្ឋមន្ត្រី។ បន្ថែមលើនេះ, ដើម្បីធានាបាននូវការអនុវត្តគម្រោងប្រកបដោយប្រសិទ្ធភាព, ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបន្តអនុវត្តគោលការណ៍ភាពរួចរាល់សម្រាប់ការចាប់ផ្តើមអនុវត្តគម្រោង (Project Readiness Filters) ដែលក្នុងនោះ ត្រូវមានការវាយតម្លៃសមត្ថភាពរបស់អង្គភាពគ្រប់គ្រងគម្រោង ក្នុងដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាពគម្រោង និងការរៀបចំផែនការបណ្តុះបណ្តាល ក្នុងករណីមានតម្រូវការ។ មិនតែប៉ុណ្ណោះ, ក្រសួង ស្ថាប័ន ត្រូវរៀបចំ និងបង្កើតអង្គភាពគ្រប់គ្រងនិងអនុវត្តគម្រោង ដែលសមាសភាពនៃអង្គភាពនេះត្រូវជ្រើសរើសដោយឈរលើគោលការណ៍គុណវុឌ្ឍិ ស្របតាមនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ។

១០. បន្តពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ដែលចូលរួមបំពេញមុខងារគ្រប់គ្រងបំណុលសាធារណៈ សំដៅរួមចំណែកបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលមធ្យម-វែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប ព្រមទាំងធានានូវការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងអនុវត្តគម្រោងវិនិយោគសាធារណៈ។ ទន្ទឹមនេះ, ត្រូវគិតគូរពិចារណាប្រើប្រាស់ធនធានមនុស្សក្នុងស្រុកជំនួសឱ្យជំនាញការបរទេស សំដៅលើកកម្ពស់ភាពជាម្ចាស់ និងសម្រាលបន្ទុកចំណាយនៃគម្រោងវិនិយោគសាធារណៈ។

ទន្ទឹមនេះ, ដើម្បីធានាបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពក្នុងការអនុវត្តបណ្តាវិធានការគន្លឹះជាអាទិភាព និងផែនការសកម្មភាពគាំទ្រទាំងអស់, យុទ្ធសាស្ត្រនេះ ក៏ដាក់ចេញយន្តការតាមដាន, ត្រួតពិនិត្យ, វាយតម្លៃ, និងយន្តការដោះស្រាយបញ្ហាប្រឈមផងដែរ។

**«យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨»** ត្រូវបានរៀបចំដោយភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាជាមួយនឹងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ហើយត្រូវបានចាត់ទុកជា **«ឯកសាររស់»** ដែលអាចនឹងត្រូវបានធ្វើបច្ចុប្បន្នកម្មជាយថាហេតុ ក្នុងករណីចាំបាច់ ដើម្បីធានាសង្គតិភាព និងការឆ្លើយតបទៅនឹងការវិវឌ្ឍនៃបរិការណ៍ចំពោះមុខជាក់ស្តែងទាំងក្នុងសកល, តំបន់, និងប្រទេស។

ការអនុវត្តដោយជោគជ័យនូវយុទ្ធសាស្ត្រនេះ នឹងជំរុញឱ្យការគ្រប់គ្រងបំណុលសាធារណៈរបស់កម្ពុជាកាន់តែមានប្រសិទ្ធភាព និងមានភាពរឹងមាំថែមទៀត។ ក្នុងន័យនេះ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាល នឹងទទួលបន្ទុកជាស្ថាប័នដឹកមុខក្នុងការសម្របសម្រួលលើការអនុវត្ត **«យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨»** ដោយត្រូវមានការចូលរួមអនុវត្តសហការប្រកបដោយស្មារតីម្ចាស់ការ និងការទទួលខុសត្រូវខ្ពស់របស់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់។

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

ការរក្សាបាននូវសុខសន្តិភាព, ឯកភាពជាតិ, ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច បូករួមទាំងធន្ទះមោះមុត និងការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកន្លងមក គឺជាមូលដ្ឋានគ្រឹះចម្បងដែលអនុញ្ញាតឱ្យកម្ពុជាសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន ក្នុងការជំរុញអភិវឌ្ឍសង្គម-សេដ្ឋកិច្ច បើទោះបីជាត្រូវទទួលរងនូវផលវិបាកពាក់ព័ន្ធនឹងវិបត្តិសុខភាពសាធារណៈធ្ងន់ធ្ងរ, វិបត្តិភូមិសាស្ត្រនយោបាយ ព្រមទាំងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកលក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយក៏ដោយ។ ជាក់ស្តែង, សេដ្ឋកិច្ចកម្ពុជាបានស្ទុះងើបឡើងវិញពីកំណើនអវិជ្ជមាននៅឆ្នាំ២០២០ មកកំណើនក្នុងអត្រា **៣,១%** នៅឆ្នាំ២០២១, **៥,១%** នៅឆ្នាំ២០២២ និង **៥,០%** នៅឆ្នាំ២០២៣ ហើយរំពឹងថា នឹងកើនដល់ **៦,០%** នៅឆ្នាំ២០២៤។

បើពិនិត្យជារួម ក្នុងរយៈពេលពីរទសវត្សរ៍មុនវិបត្តិនៃជំងឺកូវីដ-១៩, កំណើនសេដ្ឋកិច្ចរបស់កម្ពុជា ស្ថិតក្នុងរង្វង់ជាមធ្យមជាង **៧%** ក្នុងមួយឆ្នាំ ដែលនាំឱ្យកម្ពុជាសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ២០១៥ ក្នុងនោះ កម្រិតជីវភាពរបស់ប្រជាជនមានភាពប្រសើរឡើង ដោយ ផសស ក្នុងមនុស្សម្នាក់ បានកើនឡើងជាង ៥ ដង ពោលគឺ ពី **៤៦៤ ដុល្លារអាម៉េរិក** ក្នុងឆ្នាំ២០០៤ ដល់ប្រមាណ **២ ៥២០ ដុល្លារអាម៉េរិក** ក្នុងឆ្នាំ២០២៣ ខណៈអត្រាភាពក្រីក្រត្រូវបានបន្តធ្លាក់ចុះជាលំដាប់ពីជាង **៥៤%** ក្នុងឆ្នាំ២០០៤ មកត្រឹម **១៣,៥%** ក្នុងឆ្នាំ២០១៤ ហើយត្រូវបានប៉ាន់ស្មានថា ស្ថិតក្រោម **១០%** មុនវិបត្តិជំងឺកូវីដ-១៩។

ការសម្រេចបានខាងលើ ពិតជាមិនអាចកាត់ផ្តាច់ចេញពីការរួមចំណែកនៃការគ្រប់គ្រងបំណុលសាធារណៈប្រកបដោយប្រសិទ្ធភាពឡើយ ដែលបានគាំទ្រតាមរយៈការកៀរគរ និងសម្រិតសម្រាំងឥណទានដែលមានកម្រិតសម្បទានខ្ពស់ និងហានិភ័យទាប សម្រាប់យកមកបំពេញតម្រូវការហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈស្របតាមគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាល រួមមាន៖ ផ្លូវថ្នល់, ស្ពាន, ផ្លូវដែក, កំពង់ផែ, អាកាសយានដ្ឋាន, រោងចក្រផលិតថាមពលអគ្គិសនី, បណ្តាញបញ្ជូននិងចែកចាយថាមពលអគ្គិសនី, ស្ថានីយ៍ផលិតនិងបណ្តាញផ្គត់ផ្គង់ទឹកស្អាត, ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់, ប្រព័ន្ធធារាសាស្ត្រ, មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ, ការលើកកម្ពស់គុណភាពអប់រំ និងការផ្តល់សេវាសុខាភិបាល ជាដើម ដែលជាចលករដ៏សំខាន់និងមិនអាចខ្វះបាន ក្នុងការរួមចំណែកសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់។

ជាការពិត, តាមរយៈកិច្ចខិតខំប្រឹងប្រែងកន្លងមក កម្ពុជាកសាងបាននូវប្រព័ន្ធគ្រប់គ្រងបំណុលសាធារណៈមួយដ៏រឹងមាំ ដែលរួមផ្សំដោយសមាសធាតុជាសារវន្តមួយចំនួន ជាអាទិ៍៖ ក្របខ័ណ្ឌគតិយុត្ត រួមទាំងនីតិវិធីច្បាស់លាស់, សមត្ថភាពស្ថាប័ន និងធនធានមនុស្សគ្រប់គ្រាន់, ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងប្រតិបត្តិការ និងរក្សាទុកទិន្នន័យគ្រប់ជ្រុងជ្រោយ ជាពិសេស ការដាក់ចេញ និងអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍វិន័យគន្លឹះៗ តាំងពីឆ្នាំ ១៩៩៣ មក និងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈចំនួន ៣ លើក រួចមកហើយ ក្នុងនោះ៖ លើកទី១ សម្រាប់ **ឆ្នាំ២០១១ - ២០១៨**, លើកទី២ សម្រាប់ឆ្នាំ**២០១៥ - ២០១៨**, និងលើកទី៣ សម្រាប់**ឆ្នាំ២០១៩ - ២០២៣**។

តាមរយៈការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ទាំង ៣ លើកនេះ, ស្ថានភាពបំណុលសាធារណៈកម្ពុជា ត្រូវបានគ្រប់គ្រងប្រកបដោយវិន័យ និងប្រសិទ្ធភាពខ្ពស់ ដោយអាចបន្តរក្សាបាននូវ «**ចីរភាព**» និង «**ហានិភ័យកម្រិតទាប**» ក្នុងនោះ សូចនាករតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹង ផសស ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ មានជាមធ្យមត្រឹមរង្វង់ **១៨%** ប៉ុណ្ណោះ ធៀបនឹងអនុបាតគោល **៤០%**។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលបានចាប់ផ្តើមកៀរគរទុនពីទីផ្សារក្នុងប្រទេស តាមរយៈការបោះផ្សាយលក់មូលបត្ររដ្ឋដែលជាប្រភព

ហិរញ្ញប្បទានថ្មី ជាលើកដំបូងនៅឆ្នាំ២០២២ ហើយនឹងបន្តអនុវត្តយ៉ាងសកម្មនូវរាល់វិធានការ និងផែនការសកម្មភាពដែលបានដាក់ចេញក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨ ដើម្បីកសាងឱ្យបាននូវប្រព័ន្ធគ្រប់គ្រងមួយដ៏រឹងមាំ និងគ្រប់ជ្រុងជ្រោយសម្រាប់ការបោះផ្សាយ និងការជួញដូរមូលបត្ររដ្ឋ។

ក្នុងបរិការណ៍ក្រោយការរាតត្បាតនៃជំងឺកូវីដ-១៩ និងនិន្នាការប្រែប្រួលនៃសេដ្ឋកិច្ចសកល, ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ ព្រមទាំងការកើនឡើងនៃសម្ពាធអតិផរណា បាននាំឱ្យប្រទេសនានាលើសកលលោក ជាពិសេសក្រុមប្រទេសកំពុងអភិវឌ្ឍ ឬប្រទេសមានចំណូលមធ្យមកម្រិតទាប មានក្តីព្រួយបារម្ភខ្លាំង ព្រោះថាបរិការណ៍ទាំងនេះអាចនាំឱ្យមានអស្ថិរភាពសេដ្ឋកិច្ច និងប៉ះពាល់ដល់សុខុមាលភាពរបស់មនុស្ស ហើយក៏អាចធ្វើឱ្យប្រឈមនឹងហានិភ័យនៃវិបត្តិបំណុលផងដែរ ដោយរួមទាំងបញ្ហាដែលអាចកើតចេញពីការកើនឡើងនៃបំណុលសាជីវកម្ម (Corporate Debt) និងបំណុលគ្រួសារ (Household Debt) ក៏ដូចជា ការបន្តកើនឡើងកាន់តែខ្ពស់នៃអត្រាការប្រាក់ ដែលអាចធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចរបស់ប្រទេសទាំងមូល។ បរិការណ៍ទាំងនេះ ត្រូវបានចាត់ទុកជាបញ្ហាប្រឈមបង្កឡើងដោយកត្តាខាងក្រៅ ដែលទាមទារឱ្យរាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវគិតគូរពិចារណាឱ្យបានហ្មត់ចត់អំពីការកំណត់គោលដៅ និងអាទិភាពនៃការប្រើប្រាស់ឥណទានយ៉ាងប្រយ័ត្នប្រយែងបំផុត ខណៈដែលកម្ពុជា ត្រូវប្រឈមនឹងការបាត់បង់លក្ខខណ្ឌអនុគ្រោះពីប្រភពហិរញ្ញប្បទានប្រពៃណីដែលមានទម្រង់ជាហិរញ្ញប្បទានឥតសំណង និងឥណទានមានកម្រិតសម្បទានខ្ពស់ ហើយត្រូវអនុវត្តតាមលក្ខខណ្ឌហិរញ្ញប្បទានថ្មី នៅពេលដែលកម្ពុជាក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ និងចាកចេញពីក្រុមប្រទេសអភិវឌ្ឍតិចតួច នាពេលខាងមុខ។

ឆ្លើយតបនឹងបរិការណ៍ខាងលើ និងផ្អែកលើគ្រប់ទិដ្ឋភាពពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ដោយរួមទាំងវឌ្ឍនភាព, ហានិភ័យ, បញ្ហាប្រឈម, និងកាលានុវត្តភាព, រាជរដ្ឋាភិបាល មានភាពចាំបាច់ត្រូវពិនិត្យឡើងវិញនូវវិធានការជាយុទ្ធសាស្ត្រកន្លងមក និងធ្វើបច្ចុប្បន្នកម្មឱ្យទៅជា «**យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨**» ដែលកាន់តែប្រយ័ត្នប្រយែង និងមុតស្រួចជាងមុន សំដៅរួមចំណែកក្នុងការបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន ឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

ជារួម, «**យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨**» នេះ គឺជាផែនទីបង្ហាញផ្លូវដើម្បីតម្រង់ទិស និងពង្រឹងវិន័យក្នុងការខ្ចីប្រាក់ពីគេ ការឱ្យប្រាក់គេខ្ចី ការធានារបស់រដ្ឋ និងការគ្រប់គ្រងហានិភ័យបំណុល រួមទាំងកាតព្វកិច្ចបំណុលជាយថាហេតុ ព្រមទាំងការប្រើប្រាស់ឥណទានប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព ចីរភាព និងការទទួលខុសត្រូវខ្ពស់ សំដៅឈានទៅសម្រេចឱ្យបាននូវការគ្រប់គ្រងបំណុលសាធារណៈប្រកបដោយចីរភាព ដែលរួមចំណែកយ៉ាងសំខាន់ដល់ការរក្សាស្ថិរភាពគោលនយោបាយសារពើពន្ធ ជំរុញកំណើនសេដ្ឋកិច្ច និងការពារសុខភាពហិរញ្ញវត្ថុរបស់ប្រទេសក្នុងរយៈពេលវែង។

# ជំពូកទី២
# គោលបំណង គោលដៅ
# និងវិសាលភាព

# ជំពូកទី២
# គោលបំណង គោលដៅ និងវិសាលភាព

## ២.១. គោលបំណង និងគោលដៅ

យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨ មានគោលបំណងធានានូវប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ រួមទាំងមូលបត្ររដ្ឋ សំដៅរួមចំណែកក្នុងការបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន ឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ, យុទ្ធសាស្ត្រនេះ មានគោលដៅកំណត់នូវវិធានការជាយុទ្ធសាស្ត្រក្នុងការៈ

១) កៀរគរនិងសម្រិតសម្រាំងធនធានហិរញ្ញវត្ថុពីគ្រប់ប្រភព ដែលមានថ្លៃដើមនិងហានិភ័យទាប ដើម្បីបំពេញតម្រូវការទុនវិនិយោគសាធារណៈសរុប ប្រកបដោយប្រសិទ្ធភាព និងបន្តរក្សាបាននូវចីរភាពបំណុលសាធារណៈរយៈពេលមធ្យម និងវែង;

២) គាំទ្រការអភិវឌ្ឍមូលបត្ររដ្ឋ។

## ២.២. វិសាលភាព

យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨ មានវិសាលភាពគ្របដណ្តប់លើៈ

១) រាល់ប្រតិបត្តិការពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ រួមមានៈ ការខ្ចីប្រាក់ពីគេ, ការឱ្យប្រាក់គេខ្ចី, ការធានារបស់រដ្ឋ, និងការគ្រប់គ្រងហានិភ័យបំណុល រួមទាំងកាតព្វកិច្ចបំណុលជាយថាហេតុ;

២) ការតាមដានលើស្ថានភាព និងនិន្នាការនៃបំណុលរបស់វិស័យឯកជន សំដៅរួមចំណែកគ្រប់គ្រងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេលមធ្យម និងវែង។

# ជំពូកទី៣
# វឌ្ឍនភាពនៃការអនុវត្ត
# យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រង
# បំណុលសាធារណៈ
# ២០១៩-២០២៣

# ជំពូកទី៣
# វឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣

ក្នុងរយៈពេល ៥ឆ្នាំ នៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់បំណុលសាធារណៈ ២០១៩ - ២០២៣ រាជរដ្ឋាភិបាលបន្តកសាងបាននូវប្រព័ន្ធគ្រប់គ្រងបំណុលសាធារណៈមួយកាន់តែរឹងមាំជាងមុន ព្រមទាំងសម្រេចបាននូវសមិទ្ធផល និងវឌ្ឍនភាពគួរឱ្យកត់សម្គាល់ជាច្រើន ក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងបំណុលសាធារណៈ រួមទាំងមូលបត្ររដ្ឋ ជាអាទិ៍៖

## ៣.១. ការកៀរគរហិរញ្ញប្បទាន

**ក. ហិរញ្ញប្បទានក្រៅប្រទេស៖** បានកៀរគរហិរញ្ញប្បទានពីដៃគូអភិវឌ្ឍក្រៅប្រទេសសរុបចំនួនប្រមាណ **៩ ៧៥៧ លានដុល្លារអាម៉េរិក** ដើម្បីយកមកបំពេញតម្រូវការវិនិយោគសាធារណៈ សំដៅរួមចំណែកទ្រទ្រង់ចីរភាពនៃកំណើនរយៈពេលវែង និងបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម ក្នុងនោះ៖

- ហិរញ្ញប្បទានឥតសំណង (ដែលបានចុះកិច្ចព្រមព្រៀងដោយរាជរដ្ឋាភិបាល) មានចំនួនប្រមាណ **១ ៥៩៥ លានដុល្លារអាម៉េរិក** សម្រាប់អនុវត្តគម្រោង/កម្មវិធី ចំនួន ៨៩; និង
- ហិរញ្ញប្បទានឥណទានសម្បទាន មានចំនួនប្រមាណ **៨ ១៦២ លានដុល្លារអាម៉េរិក** សមមូលនឹង **៥ ៩០៧ លានអេសដេអ៊ែ** សម្រាប់អនុវត្តគម្រោង/កម្មវិធី ចំនួន ១០៨ ក្នុងនោះ ឥណទានបន្ត មានចំនួន **១ ២៥៩ លានដុល្លារអាម៉េរិក** ស្មើនឹងប្រមាណ **១៣%** នៃឥណទានដែលបានចុះកិច្ចព្រមព្រៀងសរុប ដូចមានលម្អិតក្នុងចំណុច ៣.៣. ខាងក្រោម។

ជារួម, ទំហំនៃការខ្ចីឥណទានសម្បទានក្នុងរយៈពេល ៥ ឆ្នាំកន្លងទៅនេះ ត្រូវបានគ្រប់គ្រងមិនឱ្យលើសពីពិតានកំណត់ ដោយសម្រេចបានប្រមាណ **៥៤%** នៃពិតានដែលកំណត់នៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ឬជាមធ្យមប្រមាណ **៧២%** ធៀបនឹងពិតានដែលកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំ ដូចមានលម្អិតក្នុងក្រាហ្វទី១ ខាងក្រោម៖

### ក្រាហ្វទី១៖ ការចុះកិច្ចព្រមព្រៀងឥណទានធៀបនឹងពិតាននៃច្បាប់ពីឆ្នាំ២០១៩ - ២០២៣




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

**ខ. ហិរញ្ញប្បទានក្នុងប្រទេស៖** គិតចាប់ពីការបោះផ្សាយលក់មូលបត្ររដ្ឋលើកដំបូងនៅខែកញ្ញា ឆ្នាំ២០២២ រហូតដល់ដំណាច់ឆ្នាំ២០២៣ បានបោះផ្សាយលក់មូលបត្ររដ្ឋសរុបចំនួន **៣១០ ប៊ីលានរៀល** សមមូលនឹងប្រមាណ **៧៦ លានដុល្លារអាមេរិក** ដើម្បីធ្វើហិរញ្ញប្បទានលើគម្រោងវិនិយោគ ដែលអាចផ្តល់ចំណូលដោយត្រង់មករាជរដ្ឋាភិបាល និងផ្តល់ផលរហ័ស ដើម្បីធានាប្រសិទ្ធភាពនៃការវិនិយោគនិងចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ និងថវិកាជាតិ ដូចមានក្នុងក្រាហ្វទី២ ខាងក្រោម៖

ក្រាហ្វទី២៖ ការបោះផ្សាយលក់មូលបត្ររដ្ឋធៀបនឹងពិតាននៃច្បាប់ពីឆ្នាំ២០២២ - ២០២៣




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

**គ. ហិរញ្ញប្បទានពីប្រភពផ្សេងទៀត៖** បានកៀរគរទុនពីវិស័យឯកជនតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) មកបំពេញតម្រូវការវិនិយោគសាធារណៈសរុបចំនួន **៥ ០៨០ លានដុល្លារអាមេរិក**។

## ៣.២. ការគ្រប់គ្រងបំណុលសាធារណៈ

### ៣.២.១. ថ្លៃ និងហានិភ័យបំណុល

បានកៀរគរ និងសម្រិតសម្រាំងនូវធនធានហិរញ្ញវត្ថុពីក្នុង និងក្រៅប្រទេស ដែលមានថ្លៃដើម និងហានិភ័យទាប ដើម្បីបំពេញតម្រូវការទុនវិនិយោគសាធារណៈសរុប ព្រមទាំងគ្រប់គ្រងរាល់ហានិភ័យបំណុលពាក់ព័ន្ធទាំងអស់ រួមទាំងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ប្រកបដោយភាពប្រយ័ត្នប្រយែងខ្ពស់ ដោយបន្តរក្សាបាននូវចីរភាពបំណុលសាធារណៈ។ ជាក់ស្តែង, សូចនាករថ្លៃ និងហានិភ័យបំណុលរបស់កម្ពុជា សម្រាប់ឆ្នាំ២០១៩-២០២៣ មានស្ថានភាពដូចក្នុងតារាងទី១ ខាងក្រោម៖

### តារាងទី១៖ សូចនាករថ្លៃ និងហានិភ័យបំណុលឆ្នាំ២០១៩ - ២០២៣

| ប្រភេទសូចនាករ | សូចនាករ* | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| ថ្លៃដើមហិរញ្ញប្បទាន<br>Cost of Debt | មធ្យមទម្ងន់នៃអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)<br>Weighted Average Interest Rate (p.a.) | ១,៣៤% | ១,២៧% | ១,២២% | ១,២១% | ១,១៨% |
| ហានិភ័យ<br>បុនហិរញ្ញប្បទាន<br>Refinancing Risk | រយៈពេលមធ្យមដល់ឥណប្រតិទាន (ឆ្នាំ)<br>Average Time to Maturity – ATM (year) | ៩,៩៩ | ១០,៣២ | ១០,១១ | ១០,១៦ | ១០,១៤ |
| | បំណុលដែលត្រូវទូទាត់នៅឆ្នាំបន្ទាប់<br>(% នៃសរុប)<br>Debt Maturing in 1 year (% of total) | ៤% | ៣% | ៤% | ៤% | ៤% |
| ហានិភ័យ<br>អត្រាការប្រាក់<br>Interest Rate Risk | រយៈពេលមធ្យមនៃការប្រែប្រួល<br>អត្រាការប្រាក់ (ឆ្នាំ)<br>Average Time to Refixing – ATR (year) | ៩,៩៩ | ១០,៣២ | ១០,១០ | ១០,១៣ | ១០,០៤ |
| | សមាសភាគបំណុលសាធារណៈ ជា<br>ប្រភេទអត្រាការប្រាក់ថេរ (% នៃសរុប)<br>Fixed Rate Debt (% of total) | ១០០% | ១០០% | ៩៩,៩៤% | ៩៩,៧៩% | ៩៩,២៦% |
| ហានិភ័យ<br>រូបិយប័ណ្ណ<br>FX Risk | សមាសភាគបំណុលសាធារណៈជា<br>រូបិយប័ណ្ណបរទេស (% នៃសរុប)<br>Foreign Currency Debt (% of total) | ៩៩,៩៨% | ១០០% | ១០០% | ៩៩,៥១% | ៩៩,៥៣% |

**សូចនាករទាំងនេះ ត្រូវបានគណនាដោយផ្អែកលើទិន្នន័យត្រឹមដំណាច់ឆ្នាំនីមួយៗ។*

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

### ៣.២.២. ស្ថានភាពបំណុលសាធារណៈ

**ក. សន្និធិបំណុលសាធារណៈ៖** គិតត្រឹមដំណាច់ឆ្នាំ២០២៣ កម្ពុជាមានសន្និធិបំណុលសាធារណៈសរុបចំនួនប្រមាណ **១១ ២៣៨ លានដុល្លារអាម៉េរិក** ដែលភាគច្រើនលើសលុបជាបំណុលសាធារណៈក្រៅប្រទេស មានចំនួនប្រមាណ **១១ ១៨៥ លានដុល្លារអាម៉េរិក** ស្មើនឹង **៩៩,៥%** នៃសន្និធិសរុប ក្នុងនោះ៖ ក្របខ័ណ្ឌទ្វេភាគីប្រមាណ **៦៤%** និងក្របខ័ណ្ឌពហុភាគីប្រមាណ **៣៦%** ខណៈដែលបំណុលសាធារណៈក្នុងប្រទេស មានចំនួន **២១៤ ប៊ីលានរៀល** សមមូលនឹងប្រមាណ **៥២ លានដុល្លារអាម៉េរិក** ស្មើនឹង **០,៥%** នៃសន្និធិសរុប ដូចមានលម្អិតក្នុងក្រាហ្វទី៣ ខាងក្រោម៖

## ក្រាហ្វទី៣៖ សន្និធិបំណុលសាធារណៈ ត្រឹមដំណាច់ឆ្នាំ២០២៣




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

**ខ. ការដកសាច់ប្រាក់៖** បានដកសាច់ប្រាក់ក្នុងក្របខ័ណ្ឌនៃការខ្ចីឥណទានសម្បទានពីក្រៅប្រទេសសរុបចំនួនប្រមាណ **៦ ០៨១ លានដុល្លារអាមេរិក** ក្នុងនោះ ប្រមាណ **៦៨%** ត្រូវបានប្រើប្រាស់ដើម្បីហិរញ្ញប្បទានលើគម្រោងវិនិយោគសាធារណៈក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ផ្លូវថ្នល់, ស្ពាន, ផ្លូវដែក, កំពង់ផែ, អគ្គិសនី, អាកាសយានដ្ឋាន, ប្រព័ន្ធធារាសាស្ត្រ, ការផ្គត់ផ្គង់ទឹកស្អាត, និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់) និងប្រមាណ **៣២%** ទៀតក្នុងវិស័យអាទិភាពចំពោះមុខផ្សេងទៀត (សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ទេសចរណ៍, អប់រំ, សេវាសាធារណៈ, សុខាភិបាល, និងការគ្រប់គ្រងដីធ្លី) ដូចមានលម្អិតក្នុងក្រាហ្វទី៤ ខាងក្រោម៖

## ក្រាហ្វទី៤៖ ការដកសាច់ប្រាក់ក្នុងក្របខ័ណ្ឌនៃការខ្ចីឥណទានសម្បទានពីក្រៅប្រទេសឆ្នាំ២០១៩ - ២០២៣




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

**គ. ការទូទាត់សេវាបំណុល៖** បានទូទាត់សេវាបំណុលសរុបចំនួនប្រមាណ **២ ០០៩,៧ លានដុល្លារអាម៉េរិក** ក្នុងនោះ៖ ប្រាក់ដើម **១ ៥០៤,៣ លានដុល្លារអាម៉េរិក** និងការប្រាក់និងកម្រៃផ្សេងៗ **៥០៥,៤ លានដុល្លារអាម៉េរិក** ដូចមានលម្អិតក្នុងក្រាហ្វទី៥ ខាងក្រោម៖

**ក្រាហ្វទី៥៖ ការទូទាត់សេវាបំណុលឆ្នាំ២០១៩ - ២០២៣**




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

**ឃ. សូចនាករចីរភាពបំណុល៖** បានបន្តគ្រប់គ្រងបំណុសាធារណៈប្រកបដោយ «**ចីរភាព**» និង «**ហានិភ័យកម្រិតទាប**» ដោយរាល់សូចនាករបំណុលគន្លឹះៗទាំងអស់សុទ្ធតែស្ថិតក្រោមពិតានកំណត់ ដូចមានក្នុងតារាងទី២ ខាងក្រោម៖

**តារាងទី២៖ សូចនាករចីរភាពបំណុលឆ្នាំ២០១៩ - ២០២៣**

*ជាភាគរយ*

| សូចនាករ | ពិតាន | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| –តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប | | | | | | |
| *ធៀបនឹង ផសស* | *៥៥* | ១៥,០ | ១៨,២ | ១៨,៦ | ១៨,១ | ១៨,៨ |
| – តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស | | | | | | |
| *ធៀបនឹង ផសស* | *៤០* | ១៥,០ | ១៨,២ | ១៨,៦ | ១៨,០ | ១៨,៧ |
| *ធៀបនឹង ការនាំចេញ* | *១៨០* | ២៦,៧ | ៣២,៨ | ៣៤,២ | ២៨,៤ | ២៩,០ |
| –សេវាបំណុលសាធារណៈក្រៅប្រទេស | | | | | | |
| *ធៀបនឹង ការនាំចេញ* | *១៥* | ១,៥ | ១,៨ | ១,៩ | ១,៨ | ១,៨ |
| *ធៀបនឹង ចំណូលថវិកាជាតិ* | *១៨* | ៤,៥ | ៦,២ | ៦,៩ | ៦,៩ | ៧,៥ |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## ៣.៣. ការផ្តល់ឥណទានរបស់រដ្ឋ

បានចុះកិច្ចព្រមព្រៀងផ្តល់ឥណទានសរុបចំនួនប្រមាណ **២ ៤៨២ លានដុល្លារអាមេរិក** ក្នុងនោះ ការផ្តល់ឥណទានផ្ទាល់ ចំនួនប្រមាណ **៩៧២ លានដុល្លារអាមេរិក** និងការផ្តល់ឥណទានបន្ត ចំនួនប្រមាណ **១ ៥១០ លានដុល្លារអាមេរិក**។ ទន្ទឹមនេះ, បានបើកផ្តល់សាច់ប្រាក់ឱ្យឥណាយិកប្រើប្រាស់សរុបចំនួនប្រមាណ **១ ៦៩៥ លានដុល្លារអាមេរិក** និងបានប្រមូលចំណូលសេវាបំណុលសរុបចំនួនប្រមាណ **៣៤៧ លានដុល្លារអាមេរិក** ក្នុងនោះ ប្រាក់ដើម **១៩១ លានដុល្លារអាមេរិក** និងការប្រាក់និងកម្រៃផ្សេងៗ **១៥៦ លានដុល្លារអាមេរិក**។

គិតត្រឹមដំណាច់ឆ្នាំ២០២៣, សន្និធិបំណុលក្នុងក្របខ័ណ្ឌការផ្តល់ឥណទានរបស់រដ្ឋ សរុបមានប្រមាណ **២ ៦០០ លានដុល្លារអាមេរិក** ស្មើនឹងប្រមាណ **២៣%** នៃសន្និធិបំណុលសាធារណៈសរុប ឬប្រមាណ **៦%** នៃ ផសស (ជាតម្លៃចារីក) ដូចមានលម្អិតក្នុងក្រាហ្វទី៦ ខាងក្រោម៖

### ក្រាហ្វទី៦៖ សន្និធិបំណុលក្នុងក្របខ័ណ្ឌការផ្តល់ឥណទានរបស់រដ្ឋត្រឹមដំណាច់ឆ្នាំ២០២៣

៦.១. តាមប្រភពហិរញ្ញប្បទាន




៦.២. តាមរូបិយប័ណ្ណ




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## ៣.៤. វឌ្ឍនភាពការងារពាក់ព័ន្ធផ្សេងទៀត

ទន្ទឹមនឹងវឌ្ឍនភាពការងារសំខាន់ៗខាងលើ កិច្ចការអាទិភាពផ្សេងទៀតក៏មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ផងដែរ ស្របតាមផែនការសកម្មភាពដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣ មានជាអាទិ៍៖

**ក. ការជំរុញការអភិវឌ្ឍមូលបត្ររដ្ឋ** ដោយសម្រេចនូវសមិទ្ធផលសំខាន់ៗជាច្រើន ដូចជា៖

- បានរៀបចំ **«ច្បាប់ស្តីពីមូលបត្ររដ្ឋ»** ថ្មី ដែលត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត តាមរយៈព្រះរាជក្រមលេខ នស/រកម/១២២០/០៤០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០។
- បានដាក់ចេញនូវ **«ក្របខ័ណ្ឌគោលនយោបាយបឋមស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ»** ជាជំហានដំបូងដែលទទួលបានការអនុម័តពីរាជរដ្ឋាភិបាលកាលពីដើមខែតុលា ឆ្នាំ២០២១ ដោយផ្តោតសំខាន់លើការដាក់ចេញនូវកញ្ចប់វិធានការគោលនយោបាយបន្ទាន់ចំពោះមុខ ដើម្បីអាចសាកល្បងបោះផ្សាយលក់

មូលបត្ររដ្ឋនៅលើទីផ្សារក្នុងប្រទេស ជាលើកដំបូងនៅឆ្នាំ២០២២ សម្រាប់យកមកបំពេញតម្រូវការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិនៃជំងឺកូវីដ-១៩។

- បានអនុម័ត និងដាក់ឱ្យអនុវត្តនូវ «**ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨**» សំដៅកសាងឱ្យបាននូវប្រព័ន្ធគ្រប់គ្រងមួយដ៏រឹងមាំ និងគ្រប់ជ្រុងជ្រោយ សម្រាប់ការបោះផ្សាយ និងការជួញដូរមូលបត្ររដ្ឋនៅក្នុងប្រទេស និងត្រៀមលក្ខណៈឱ្យបានរួចរាល់ជាមុនក្នុងការឈានទៅបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស ក្នុងកាលៈទេសៈចាំបាច់។
- ក្រៅពីនេះ, បានដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តសំខាន់ៗ ដូចជា៖ ប្រកាសស្តីពីការបោះផ្សាយមូលបត្ររដ្ឋ, អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ, ប្រកាសស្តីពីការណែនាំអនុវត្តការលើកទឹកចិត្តពន្ធកាត់ទុក និងពន្ធលើចំណេញមូលធនដល់អ្នកវិនិយោគមូលបត្ររដ្ឋ, ប្រកាសស្តីពីការប្រើប្រាស់មូលបត្ររដ្ឋក្នុងប្រតិបត្តិការរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា, សារាចរណែនាំស្តីពីការអនុវត្តចំពោះមូលបត្ររដ្ឋដែលកាន់កាប់ដោយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ, សេចក្តីជូនដំណឹងស្តីពីការចូលរួមវិនិយោគមូលបត្ររដ្ឋសម្រាប់វិនិយោគិនទូទៅ, លិខិតជូនដំណឹងស្តីពីការអនុញ្ញាតឱ្យបញ្ចូលការវិនិយោគលើមូលបត្ររដ្ឋក្នុងសំពៀតឥណទានជារូបិយវត្ថុជាតិ (១០% KHR Loan Portfolio), ប្រកាសស្តីពីការអនុញ្ញាតលើការវិនិយោគសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង, អនុក្រឹត្យស្តីពីគោលការណ៍ណែនាំសម្រាប់ការវិនិយោគមូលនិធិសន្តិសុខសង្គម ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។

**ខ. ការបន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការវិនិយោគសាធារណៈ** តាមរយៈការអនុវត្តយ៉ាងម៉ឺងម៉ាត់តាមវិធានការជាយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥ ក្នុងនោះ ការងារសំខាន់ៗ ដែលសម្រេចបានក្នុងរយៈពេល ៥ឆ្នាំកន្លងទៅនេះ រួមមាន៖

- បានអនុម័ត និងដាក់ឱ្យអនុវត្តបទដ្ឋានគតិយុត្តពាក់ព័ន្ធសំខាន់ៗ ដូចជា៖ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី), ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន, ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (ថ្មី), អនុក្រឹត្យគោលស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ, អនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តនីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានក្រៅប្រទេស, អនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តនីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។
- បានកែសម្រួលរចនាសម្ព័ន្ធស្ថាប័នក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយបានដំឡើងអង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាល ទៅជាអគ្គនាយកដ្ឋាន, បង្កើតគណៈកម្មការវិនិយោគសាធារណៈប្រចាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, បង្កើតនាយកដ្ឋានប្រសិទ្ធភាពចំណាយ ក្រោមអគ្គនាយកដ្ឋានគោលនយោបាយ, បង្កើតនាយកដ្ឋានតាមដាន និងវាយតម្លៃ ក្រោមអគ្គនាយកដ្ឋានថវិកា, បង្កើតនាយកដ្ឋានតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង ក្រោមអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល។
- ក្រៅពីការងារជាសារវន្តខាងលើ, កិច្ចការផ្សេងទៀតដែលសម្រេចបាន រួមមាន៖ បានរៀបចំការវាយតម្លៃប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈនៅកម្ពុជា ដោយប្រើវិធីសាស្ត្រ Public Investment Management Assessment (PIMA) របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក្នុងឆ្នាំ២០១៩ និងឆ្នាំ២០២២, បានរៀបចំ

វគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសរយៈពេលមធ្យម កម្រិតវិញ្ញាបនបត្រ (Certificate Program) លើជំនាញវិនិយោគសាធារណៈ នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃក្រសួង ស្ថាប័ន, និងបានរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ (Public Investment Project Database Management System - PIP_DBMS) ជំនាន់ទី១ ជាដើម។

**គ. ការកសាងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស** ស្របតាមផែនការសកម្មភាពអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣ ក្នុងនោះ៖

- បានកែសម្រួលរចនាសម្ព័ន្ធនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ដែលជាអង្គភាពគ្រប់គ្រងបំណុលសាធារណៈ ដោយបានដំឡើងមុខងារការិយាល័យជួរមុខលើកិច្ចការមូលបត្ររដ្ឋ, មុខងារការិយាល័យកណ្តាល និងមុខងារការិយាល័យជួរក្រោយ ទៅជាកម្រិតនាយកដ្ឋាន ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងបរិការណ៍ថ្មីរបស់កម្ពុជា។
- បានចូលរួមវគ្គបណ្តុះបណ្តាល, ទស្សនកិច្ចសិក្សា, សិក្ខាសាលា, វេទិកា, សន្និសីទដោយផ្ទាល់ និងតាមរយៈប្រព័ន្ធវីឌីអូអនឡាញ និងការអនុវត្តតាមអភិក្រម «**រៀនផង-ធ្វើផង**» ធនធានមនុស្សក្នុងការគ្រប់គ្រងបំណុលសាធារណៈក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ ដោយអាចសម្រេចបាននូវកិច្ចការសំខាន់ៗ ប្រកបដោយភាពជាម្ចាស់ ដូចជា៖ ១) ការកសាងបទដ្ឋានគតិយុត្ត, ការរៀបចំឯកសារគោលនយោបាយ, យុទ្ធសាស្ត្រ, នីតិវិធី, និងទស្សនាទាន, ៣) ការផលិតរបាយការណ៍ និងព្រឹត្តិបត្រស្ថិតិបំណុល, ៤) ការវិភាគចីរភាពបំណុល, ចង្កោមបំណុល, ធាតុអំណោយ, ហានិភ័យបំណុលពាក់ព័ន្ធដោយរួមទាំងកាតព្វកិច្ចបំណុលជាយថាហេតុ, និង ៥) កិច្ចការពាក់ព័ន្ធសំខាន់ៗជាច្រើនផ្សេងទៀត។

# ជំពូកទី៤
# បញ្ហាប្រឈម និង
# កាលានុវត្តភាព

# ជំពូកទី៤
# បញ្ហាប្រឈម និងកាលានុវត្តភាព

## ៤.១.បញ្ហាប្រឈម

រាជរដ្ឋាភិបាលពិនិត្យឃើញថា មានបញ្ហាប្រឈមពីកត្តាខាងក្រៅ និងខាងក្នុងមួយចំនួន ដែលអាចនឹងបង្កផលប៉ះពាល់ជាយថាហេតុមកលើការគ្រប់គ្រងបំណុលសាធារណៈរបស់កម្ពុជា ជាអាទិ៍៖

### ៤.១.១. ស្ថានការណ៍សេដ្ឋកិច្ចសកល

ការប្រែប្រួលនៃរចនាសម្ព័ន្ធ និងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល បណ្តាលមកពីការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ, ភាពតានតឹងផ្នែកពាណិជ្ជកម្មរវាងប្រទេសមហាអំណាច, វិបត្តិដែលបង្កឡើងដោយការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងការរីករាលដាលនៃជម្លោះនៅមជ្ឈិមបូព៌ា, សម្ពាធអតិផរណា, បច្ច័យនៃការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់បណ្តាប្រទេសអភិវឌ្ឍ ក៏ដូចជា ការថមថយនៃកំណើនសេដ្ឋកិច្ចរបស់ប្រទេសដៃគូធំៗ និងការកើនឡើងនៃវិបត្តិអាកាសធាតុ អាចនឹងជះឥទ្ធិពលអវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជា ដែលនាំឱ្យសូចនាករម៉ាក្រូសេដ្ឋកិច្ចពុំសម្រេចបានតាមគោលដៅរំពឹងទុក។ ក្នុងករណីសូចនាករម៉ាក្រូសេដ្ឋកិច្ចសម្រេចបានទាបជាងគោលដៅ នោះស្ថានភាពបំណុលសាធារណៈរបស់កម្ពុជា ក៏នឹងត្រូវទទួលនូវរងផលប៉ះពាល់ខ្លាំងផងដែរ។

### ៤.១.២. កំណើនថ្លៃដើមហិរញ្ញប្បទាន

ជាមួយនឹងការសម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប កាលពីឆ្នាំ២០១៥ ក៏ដូចជាការចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួចបំផុត នាពេលខាងមុខ និងការបោះជំហានក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ កម្ពុជាត្រូវប្រឈមនឹងការកើនឡើងថ្លៃដើមហិរញ្ញប្បទាន ដោយត្រូវអនុវត្តតាមលក្ខខណ្ឌហិរញ្ញប្បទានថ្មីរបស់ដៃគូអភិវឌ្ឍ ក្នុងនោះ ប្រភពហិរញ្ញប្បទានឥតសំណងនឹងកាន់តែរីងស្ងួត ហើយកម្រិតសម្បទាននៃឥណទាននឹងកាន់តែថយចុះជាងមុន។ ទន្ទឹមនេះ, ឥទ្ធិពលនៃការកើនឡើងអត្រាការប្រាក់លើទីផ្សារអន្តរជាតិ អាចនឹងធ្វើឱ្យថ្លៃដើមហិរញ្ញប្បទានបន្តស្ថិតក្នុងកម្រិតមួយខ្ពស់ ជាពិសេស ប្រភេទហិរញ្ញប្បទានដែលមានការប្រាក់ប្រែប្រួល (Floating Interest) និងការខ្ចីថ្មី។ បន្ថែមលើនេះ, ថ្លៃដើមនៃការបោះផ្សាយលក់មូលបត្ររដ្ឋក៏នៅមានកម្រិតខ្ពស់ និងត្រូវបត់បែនទៅតាមស្ថានភាពជាក់ស្តែងនៃទីផ្សារ ហើយការចូលរួមវិនិយោគលើមូលបត្ររដ្ឋនៅមានកម្រិត ដោយវិនិយោគិនស្ថាប័នមួយចំនួន មានភាពរារែកក្នុងការវិនិយោគលើមូលបត្ររដ្ឋជាប្រាក់រៀល ព្រោះប្រភពទុនរបស់វិនិយោគិនស្ថាប័នភាគច្រើន គឺជាដុល្លារអាមេរិក។ ជាមួយនេះ, វិនិយោគិនភាគច្រើនបានស្នើឱ្យមានការបោះផ្សាយលក់មូលបត្ររដ្ឋជាដុល្លារអាមេរិក និង/ឬ ការអនុវត្ត FX-Linked Bonds ដែលការណ៍នេះ អាចនឹងធ្វើឱ្យថ្លៃដើមនៃការបោះផ្សាយលក់មូលបត្ររដ្ឋកើនឡើង ព្រោះរដ្ឋត្រូវរ៉ាប់រងលើហានិភ័យអត្រាប្តូរប្រាក់ជំនួសវិនិយោគិន។

ស្របពេលដែលថ្លៃដើមហិរញ្ញប្បទានបន្តកើនឡើង, រាជរដ្ឋាភិបាលក៏មានតម្រូវការហិរញ្ញប្បទានកាន់តែច្រើនបន្ថែមទៀត ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ សំដៅលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច ឈានទៅសម្រេចបានចក្ខុវិស័យកម្ពុជា ឆ្នាំ២០៣០ និងឆ្នាំ២០៥០ ដែលកត្តានេះនឹងដាក់សម្ពាធបន្ថែមដល់ការគ្រប់គ្រងបំណុលសាធារណៈ ជាពិសេស ការកៀរគរនិងសម្រិតសម្រាំងហិរញ្ញប្បទានដែលមានកម្រិតសម្បទានខ្ពស់មកបំពេញតម្រូវការវិនិយោគសាធារណៈសរុប។

### ៤.១.៣. ចំណាត់ថ្នាក់ឥណទានរបស់ប្រទេសកម្ពុជានៅមានកម្រិត

រហូតមកទល់បច្ចុប្បន្ន, កម្ពុជាពុំទាន់បានរៀបចំឱ្យមានយន្តការវាយតម្លៃចំណាត់ថ្នាក់ឥណទានផ្លូវការ (Solicited Sovereign Credit Rating) នៅឡើយ។ ផ្អែកតាមលទ្ធផលនៃការវាយតម្លៃចំណាត់ថ្នាក់ឥណទានក្រៅ

ផ្លូវការ (Unsolicited Sovereign Credit Rating) បង្ហាញថា ចំណាត់ថ្នាក់ឥណទានរបស់កម្ពុជាស្ថិតនៅក្នុងកម្រិតមួយទាបនៅឡើយ ពោលគឺ ក្រោមកម្រិតវិនិយោគ (Investment Grade) ដែលនេះនឹងធ្វើឱ្យរាជរដ្ឋាភិបាលត្រូវចំណាយថ្លៃដើមខ្ពស់ក្នុងការកៀរគរទុនពីទីផ្សារ។ តាមរយៈនេះ, រាជរដ្ឋាភិបាលយល់ឃើញថា ការរៀបចំឱ្យមានចំណាត់ថ្នាក់ឥណទានផ្លូវការ និងការធ្វើឱ្យប្រសើរឡើងនូវចំណាត់ថ្នាក់ឥណទានរបស់ប្រទេស គឺជាកិច្ចការមួយចាំបាច់ ដើម្បីទាក់ទាញការចូលរួមពីវិស័យឯកជនក្នុងការវិនិយោគសាធារណៈឱ្យកាន់តែទូលំទូលាយ និងជាពិសេសកាត់បន្ថយថ្លៃដើមនៃការខ្ចីពីទីផ្សារមូលធន នៅក្នុងរយៈពេលមធ្យម និងវែងខាងមុខ។

### ៤.១.៤. ធនធានមនុស្សក្នុងកិច្ចការគ្រប់គ្រងបំណុលសាធារណៈ និងកិច្ចការពាក់ព័ន្ធ

តាមរយៈការដាក់ចេញ និងអនុវត្តប្រកបដោយប្រសិទ្ធភាពនូវផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈនារយៈកាលកន្លងមក ធនធានមនុស្សក្នុងកិច្ចការគ្រប់គ្រងបំណុលសាធារណៈ និងកិច្ចការពាក់ព័ន្ធ មានភាពរីកចម្រើនគួរឱ្យកត់សម្គាល់។ ទោះជាយ៉ាងនេះក្តី, នៅក្នុងបរិការណ៍នៃការឡើងឋានៈទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប និងការអភិវឌ្ឍមូលបត្ររដ្ឋ ធនធានមនុស្សសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ នៅពុំទាន់អាចឆ្លើយតបបានទៅនឹងតម្រូវការការងារបច្ចុប្បន្ន ក៏ដូចជា ទៅអនាគតនៅឡើយ ពិសេសការវិភាគស៊ីជម្រៅ និងការគ្រប់គ្រងហិរញ្ញវត្ថុនិងហានិភ័យពាក់ព័ន្ធ ខណៈដែលភាពស្មុគស្មាញ និងទំហំការងារបន្តកើនឡើងជាលំដាប់។

## ៤.២. កាលានុវត្តភាព

ទន្ទឹមនឹងបញ្ហាប្រឈមដូចបានរៀបរាប់ខាងលើ រាជរដ្ឋាភិបាលយល់ឃើញថា នៅក្នុងបរិការណ៍ថ្មីនេះ កម្ពុជាក៏មាននូវកាលានុវត្តភាពសំខាន់ៗជាច្រើនសម្រាប់ពង្រីកទំហំនៃការខ្ចី និងពិពិធកម្មប្រភពហិរញ្ញប្បទាន សំដៅគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមផងដែរ ជាអាទិ៍៖

### ៤.២.១. សមត្ថភាពនៃការខ្ចីថ្មីបន្ថែម

តាមរយៈភាពជោគជ័យនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំង ៣ ដំណាក់កាលកន្លងមក ដោយរួមទាំងការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលប្រកបដោយប្រសិទ្ធភាព ជាពិសេស លទ្ធផលដ៏ប្រសើរក្នុងកិច្ចខិតខំប្រឹងប្រែងកៀរគរ និងកែលម្អការគ្រប់គ្រងចំណូល ក៏ដូចជា ការពង្រឹងប្រសិទ្ធភាពចំណាយ បានបង្កលទ្ធភាពឱ្យរាជរដ្ឋាភិបាលកសាងបាននូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមួយដ៏រឹងមាំ ដែលមានភាពធន់នឹងវិបត្តិ។ ជាក់ស្តែង, បើទោះបីជាស្ថានភាពសេដ្ឋកិច្ចកម្ពុជា បានរងនូវផលប៉ះពាល់ដោយសារវិបត្តិកូវីដ-១៩ និងកត្តាខាងក្រៅក្តី ក៏រាជរដ្ឋាភិបាល នៅតែមានសមត្ថភាពពេញលេញក្នុងការទូទាត់សេវាបំណុលជូនដៃគូអភិវឌ្ឍ ដោយពុំមានភាពអាក់អួល។

ទន្ទឹមនេះ, តាមរយៈការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាយគន្លឹះៗ និងវិធានការដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងសាធារណៈ, ស្ថានភាពបំណុលសាធារណៈកម្ពុជា មានភាពប្រសើរឡើងជាលំដាប់ ហើយត្រូវបានវាយតម្លៃថា មាន «**ចីរភាព**» និង «**ហានិភ័យកម្រិតទាប**» ដោយរាល់សូចនាករបំណុលគន្លឹះៗទាំងអស់ សុទ្ធតែស្ថិតក្រោមពិតានកំណត់។ បន្ថែមលើនេះ, ការកែសម្រួលប្រព័ន្ធស្ថិតិគណនេយ្យជាតិ ដោយផ្លាស់ប្តូរឆ្នាំគោលគណនេយ្យជាតិ ពីឆ្នាំ២០០០ មកឆ្នាំ២០១៤, បានធ្វើឱ្យសូចនាករបំណុលសាធារណៈធៀបនឹង ផសស កាន់តែរួមតូចជាងមុន ពោលគឺ សល់លំហកាន់តែធំ ធៀបនឹងពិតានគោល។

ឈរលើទិដ្ឋភាពទាំងនេះ, មានន័យថា ជាបច្ចេកទេស កម្ពុជា នៅមានលំហច្រើនក្នុងការខ្ចីថ្មីបន្ថែម ដោយមិនប៉ះពាល់ដល់សមត្ថភាពសង សម្រាប់យកមកបំពេញតម្រូវការវិនិយោគសាធារណៈក្នុងវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល។

### ៤.២.២. ប្រភពហិរញ្ញប្បទានពីក្រៅប្រទេស

ភាពរីកចម្រើនជាលំដាប់នៃសេដ្ឋកិច្ចកម្ពុជា គួបផ្សំនឹងការរក្សាបាននូវចីរភាពនៃកំណើនសេដ្ឋកិច្ច និងភាពរឹងមាំនៃការគ្រប់គ្រងបំណុលសាធារណៈ បានធ្វើឱ្យដៃគូអភិវឌ្ឍនានាមានទំនុកចិត្តខ្ពស់ក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា។ ជាក់ស្តែង, តាមរយៈការបន្តពង្រឹងកិច្ចសហប្រតិបត្តិការឱ្យកាន់តែស៊ីជម្រៅកន្លងមក, ដៃគូអភិវឌ្ឍជាច្រើនបានបង្ហាញឆន្ទៈក្នុងការជួយគាំទ្រកម្ពុជា ដោយបន្តផ្តល់ហិរញ្ញប្បទានដែលមានកម្រិតសម្បទានខ្ពស់ ព្រមទាំងបង្កើនទំហំហិរញ្ញប្បទាន កាន់តែធំជាងមុន ដើម្បីបំពេញតម្រូវការវិនិយោគសាធារណៈរបស់កម្ពុជា ដែលកាន់តែមានការកើនឡើងជាលំដាប់។ ទន្ទឹមគ្នានេះ, រាជរដ្ឋាភិបាលក៏បន្តប្រកាន់យកនូវគោលការណ៍ពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍថ្មី ដើម្បីទទួលបាននូវឥណទានដែលមានកម្រិតសម្បទានខ្ពស់ជាងមុនតាមយន្តការ គំនិតផ្តួចផ្តើម និងបង្គុំហិរញ្ញប្បទានថ្មីៗបន្ថែមទៀត។

ក្រៅពីប្រភពហិរញ្ញប្បទានប្រពៃណីបច្ចុប្បន្ន, រាជរដ្ឋាភិបាលក៏សម្លឹងឃើញមានយន្តការហិរញ្ញប្បទាននវានុវត្តន៍ថ្មីៗ ដែលកម្ពុជាអាចពិចារណាសម្រាប់ការកៀរគរហិរញ្ញប្បទានផងដែរ ជាអាទិ៍៖ ហិរញ្ញប្បទានចម្រុះ (Blended Finance), ការវិនិយោគដែលផ្តោតលើបច្ច័យវិជ្ជមាន (Impact Investment Scheme), មូលនិធិបរិច្ចាគមហាជន (Crowdfunding), និងយន្តការដោះដូរបំណុល (Debt Swap Mechanism) ជាដើម។ បន្ថែមលើនេះ, កម្ពុជាក៏មានឱកាសទាញយកផលប្រយោជន៍បន្ថែមពីយន្តការ និង/ឬ ប្រភពហិរញ្ញប្បទានពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ដូចជា៖ មូលនិធិអាកាសធាតុបៃតង (Green Climate Fund - GCF), មូលនិធិវិនិយោគអាកាសធាតុ (Climate Investment Funds - CIF), មូលនិធិបរិស្ថានពិភពលោក (Global Environment Facility - GEF), មូលនិធិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (Adaptation Fund) ជាដើម ដើម្បីយកមកបំពេញតម្រូវការហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈ ជាពិសេស គម្រោងដែលគាំទ្រការអនុវត្តសកម្មភាពស្តីពីការទប់ទល់និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការធ្វើអន្តរកាលឆ្ពោះទៅការកសាងសេដ្ឋកិច្ចបៃតង ដែលមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

### ៤.២.៣. ការអភិវឌ្ឍមូលបត្ររដ្ឋ

ទោះបីជាការបោះផ្សាយលក់មូលបត្ររដ្ឋរបស់កម្ពុជា ទើបតែត្រូវបានចាប់ផ្តើមដំបូងនៅក្នុងខែកញ្ញា ឆ្នាំ២០២២ ហើយការចាប់ផ្តើមនេះ ស្ថិតក្នុងស្ថានភាពដែលទីផ្សារហិរញ្ញវត្ថុទាំងក្នុង និងក្រៅប្រទេសមិនសូវអំណោយផលក្តី ក៏តាមលទ្ធផលនៃការបោះផ្សាយលក់មូលបត្ររដ្ឋក្នុងប្រទេសកន្លងមក ឃើញថា ដំណើរការអភិវឌ្ឍមូលបត្ររដ្ឋនៅតែមានវឌ្ឍនភាពល្អប្រសើរ។ ជាមួយនេះ, រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨ ដោយមានចក្ខុវិស័យអភិវឌ្ឍមូលបត្ររដ្ឋ ឱ្យក្លាយជាប្រភពហិរញ្ញប្បទានមួយដ៏សំខាន់សម្រាប់ការកៀរគរទុនយកបំពេញតម្រូវការវិនិយោគសាធារណៈ។ តាមរយៈការអនុវត្តក្របខ័ណ្ឌគោលនយោបាយនេះ, កម្ពុជានឹងមានប្រព័ន្ធគ្រប់គ្រងមួយដ៏រឹងមាំ និងគ្រប់ជ្រុងជ្រោយ សម្រាប់ជំរុញប្រសិទ្ធភាពនៃការបោះផ្សាយគ្រប់គ្រង និងជួញដូរមូលបត្ររដ្ឋនៅក្នុងប្រទេស ព្រមទាំងត្រៀមលក្ខណៈឱ្យបានរួចរាល់ទុកជាមុន សម្រាប់ការបោះផ្សាយសញ្ញាបណ្ណរដ្ឋតាមវិស័យ (Thematic Bond) និងសញ្ញាបណ្ណរដ្ឋនៅក្រៅប្រទេស (International Bond) នៅក្នុងកាលៈទេសៈចាំបាច់។

### ៤.២.៤. ការចូលរួមពីវិស័យឯកជនក្នុងការវិនិយោគសាធារណៈ

តាមរយៈការរីកលូតលាស់នៃសង្គមនិងសេដ្ឋកិច្ច, ការវិនិយោគឯកជននៅកម្ពុជាបន្តមានសន្ទុះគួរឱ្យកត់សម្គាល់ ដែលស្តែងចេញតាមរយៈលំហូរនៃការវិនិយោគផ្ទាល់ពីបរទេស[១] ដែលបានកើនឡើងពីក្នុងរង្វង់ប្រមាណ **២ ប៊ីលានដុល្លារអាម៉េរិក** នៅឆ្នាំ២០១៣ ទៅប្រមាណ **៣,៩ ប៊ីលានដុល្លារអាម៉េរិក** នៅឆ្នាំ២០២៣ (តួលេខប៉ាន់ស្មាន) ហើយប្រាក់បញ្ញើរបស់វិស័យឯកជន[២] បានកើនពីប្រមាណ **៧ ប៊ីលានដុល្លារអាម៉េរិក** ទៅប្រមាណ **៤៤,៥ ប៊ីលានដុល្លារអាម៉េរិក** ក្នុងរយៈពេលដូចគ្នានេះ។ ការរីកចម្រើននៃការវិនិយោគឯកជន គួបផ្សំនឹងការរីកលូតលាស់វិស័យធនាគារ និងហិរញ្ញវត្ថុ បានក្លាយជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការកសាងទីផ្សារមូលធនក្នុងប្រទេស ដែលនឹងក្លាយជាប្រភពទុនចម្បងមួយសម្រាប់ការកៀរគរទុនមកបំពេញតម្រូវការវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ, តាមរយៈការដាក់ចេញនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន, ការចូលរួមរបស់វិស័យឯកជនទាំងក្នុង និងក្រៅប្រទេស ក្នុងការវិនិយោគសាធារណៈ ក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។ តាមរយៈនេះ, វិស័យឯកជនគឺជាប្រភពទុនសក្តានុពល និងជាដៃគូដ៏សំខាន់ មិនអាចខ្វះបាន សម្រាប់ការកៀរគរទុនបន្ថែមយកមកបំពេញតម្រូវការវិនិយោគសាធារណៈជាអាទិភាពរបស់រាជរដ្ឋាភិបាល។

### ៤.២.៥. ការគាំទ្របច្ចេកទេសពីដៃគូអភិវឌ្ឍ

តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការកន្លងមក, កម្ពុជាទទួលបានជំនួយបច្ចេកទេសជាច្រើន លើការរៀបចំក្របខ័ណ្ឌគោលនយោបាយ, យុទ្ធសាស្ត្រ, ច្បាប់, និងលិខិតបទដ្ឋានគតិយុត្ត ក៏ដូចជា ការវិភាគនិងគ្រប់គ្រងហានិភ័យ និងការងារបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ និងការអភិវឌ្ឍមូលបត្ររដ្ឋ ពីដៃគូអភិវឌ្ឍនានាជាច្រើន ដូចជា៖ ធនាគារពិភពលោក (World Bank), មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF), ធនាគារអភិវឌ្ឍន៍អាស៊ី (ADB), កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP), វិទ្យាស្ថានកំណើនបៃតងសកល (GGGI), គណៈកម្មការសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ (UNESCAP), ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD), ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA), ទីភ្នាក់ងារសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចនៃប្រទេសជិតខាង (NEDA) និងមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការពហុភាគីសម្រាប់ហិរញ្ញប្បទានអភិវឌ្ឍ (MCDF) ជាដើម។ ទន្ទឹមនេះ, ដោយមើលឃើញពីប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុលសាធារណៈ ដែលកាន់តែមាំមួនឡើងជាលំដាប់ ដៃគូអភិវឌ្ឍទាំងនេះក៏នៅតែបង្ហាញឆន្ទៈក្នុងការជួយគាំទ្រដល់កម្ពុជា លើការកសាងនិងពង្រឹងសមត្ថភាពស្ថាប័ននិងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ និងការអភិវឌ្ឍមូលបត្ររដ្ឋ ផងដែរ។

---

[១] ប្រភពទិន្នន័យ៖ ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម

[២] ប្រភពទិន្នន័យ៖ ទិន្នន័យស្ថិតិរូបិយវត្ថុ និងហិរញ្ញវត្ថុ ដោយធនាគារជាតិនៃកម្ពុជា

# ជំពូកទី៥
# ការវិភាគបំណុល

# ជំពូកទី៥
# ការវិភាគបំណុល

## ៥.១. បទដ្ឋានបច្ចេកទេសក្នុងការវិភាគ

តាមបទដ្ឋានបច្ចេកទេសរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក ក្នុងការវិភាគ និងវាយតម្លៃស្ថានភាពបំណុលសាធារណៈរបស់ប្រទេសមួយ ជាទូទៅ គេប្រើវិធីសាស្ត្រក្នុងការវិភាគចំនួន ២ គឺ៖ ការវិភាគចីរភាពបំណុល (Debt Sustainability Analysis - DSA) និងការវិភាគថ្លៃ និងហានិភ័យបំណុល (Debt Portfolio Analysis - DPA)។

**ក. ការវិភាគចីរភាពបំណុល៖** គឺជាវិធីសាស្ត្រក្នុងការវិភាគ ដើម្បីវាស់ស្ទង់អំពីស្ថានភាពបំណុលសាធារណៈ និងសមត្ថភាពសងរបស់ប្រទេសមួយ ក្នុងរយៈខ្លី មធ្យម និងវែង ដោយពិនិត្យលើសូចនាករបំណុលគន្លឹះៗចំនួន ៥ ធៀបនឹងអនុបាតគោល (Threshold) ដែលមាន ៣ កម្រិត គឺ៖ ទាប, មធ្យម និងខ្ពស់ អាស្រ័យលើពិន្ទុនៃសូចនាករបន្សំ (Composite Indicator - CI)[៣] ដោយកម្ពុជាស្ថិតក្នុងកម្រិតមធ្យម ដូចក្នុងតារាងទី៣ ខាងក្រោម៖

**តារាងទី៣៖ សូចនាករចីរភាពបំណុល**

| សូចនាករ | អនុបាតគោល | | |
|---|---|---|---|
| | កម្រិតទាប CI < ២,៦៩ | កម្រិតមធ្យម ២,៦៩ ≤ CI ≤ ៣,០៥ | កម្រិតខ្ពស់ CI > ៣,០៥ |
| - តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប | | | |
| *ធៀបនឹង ផសស* | *៣៥%* | *៥៥%* | *៧០%* |
| - តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស | | | |
| *ធៀបនឹង ផសស* | *៣០%* | *៤០%* | *៥៥%* |
| *ធៀបនឹង ការនាំចេញ* | *១៤០%* | *១៨០%* | *២៤០%* |
| - សេវាបំណុលនៃបំណុលសាធារណៈក្រៅប្រទេស | | | |
| *ធៀបនឹង ការនាំចេញ* | *១០%* | *១៥%* | *២១%* |
| *ធៀបនឹង ចំណូលថវិកាជាតិ* | *១៤%* | *១៨%* | *២៣%* |

*ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក - ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៨*

**ខ. ការវិភាគថ្លៃ និងហានិភ័យបំណុល៖** គឺជាវិធីសាស្ត្រក្នុងការវិភាគ ដើម្បីវាស់ស្ទង់ថ្លៃ និងហានិភ័យនៃបំណុលសាធារណៈរបស់ប្រទេសមួយ ក្នុងរយៈពេលខ្លី និងមធ្យម ដោយពិនិត្យលើសូចនាករគន្លឹះៗ មួយចំនួនដូចក្នុងតារាងទី៤ ខាងក្រោម៖

[៣] *Composite Indicator – CI : គឺជាមធ្យមទម្ងន់នៃពិន្ទុវាយតម្លៃគោលនយោបាយនិងស្ថាប័នរបស់ប្រទេស (Country Policy and Institutional Assessment – CPIA), កំណើនសេដ្ឋកិច្ចរបស់ប្រទេស, ទុនបម្រុង, ការផ្ញើប្រាក់, និងកំណើនសេដ្ឋកិច្ចសកល ដែលគណនាដោយធនាគារពិភពលោក ក្នុងនោះ ពិន្ទុ CI ចុងក្រោយសម្រាប់កម្ពុជា (ខែមេសា ឆ្នាំ២០២៤) គឺ ៣,០២។*

## តារាងទី៤៖ សូចនាករថ្លៃ និងហានិភ័យបំណុល

| សូចនាករថ្លៃ និងហានិភ័យ | សូចនាករ |
|---|---|
| **ថ្លៃដើមហិរញ្ញប្បទាន**<br>Cost of Debt | មធ្យមទម្ងន់អត្រាការប្រាក់ (ក្នុងមួយឆ្នាំ)<br>Weighted Average Interest Rate (p.a. %) |
| | បន្ទុកការប្រាក់ធៀបនឹង ផសស (%)<br>Interest payment as percent of GDP (%) |
| **ហានិភ័យបុនហិរញ្ញប្បទាន**<br>Refinancing Risk | រយៈពេលមធ្យមដល់ឥណប្រតិទាន (ឆ្នាំ)<br>Average Time to Maturity - ATM (year) |
| | បំណុលដែលត្រូវទូទាត់នៅឆ្នាំបន្ទាប់ (% នៃសរុប)<br>Debt Maturing in 1 year (% of total) |
| | បំណុលដែលត្រូវទូទាត់នៅឆ្នាំបន្ទាប់ (% នៃ ផសស)<br>Debt Maturing in 1 year (% of GDP) |
| **ហានិភ័យអត្រាការប្រាក់**<br>Interest Rate Risk | រយៈពេលមធ្យមនៃការប្រែប្រួលអត្រាការប្រាក់ (ឆ្នាំ)<br>Average Time to Refixing - ATR (year) |
| | សមាសភាគបំណុលសាធារណៈដែលត្រូវផ្លាស់ប្តូរអត្រាការប្រាក់នៅឆ្នាំបន្ទាប់ (% នៃសរុប)<br>Debt re-fixing in 1 year (% of total) |
| | សមាសភាគបំណុលសាធារណៈជាប្រភេទអត្រាការប្រាក់ថេរ រួមបញ្ចូលទាំងបណ្ណរតនាគារ (% នៃសរុប)<br>Fixed rate debt including T-bills (% of total) |
| | សមាសភាគបណ្ណរតនាគារ (% នៃសរុប)<br>T-bills (% of total) |
| **ហានិភ័យរូបិយប័ណ្ណ**<br>FX Risk | សមាសភាគបំណុលសាធារណៈជារូបិយប័ណ្ណបរទេស (% នៃសរុប)<br>Foreign Currency Debt (% of total) |
| | សមាសភាគបំណុលសាធារណៈជារូបិយប័ណ្ណបរទេសរយៈពេលខ្លី (% នៃទុនបម្រុង)<br>Short Term Foreign Currency Debt (% of Reserves) |

ដោយឡែក, កម្ពុជា អាចជ្រើសតែសូចនាករពាក់ព័ន្ធសំខាន់ៗ សម្រាប់គ្រប់គ្រង និងតាមដាន ផ្អែកតាមបរិការណ៍ជាក់ស្តែង ដូចជា៖ មធ្យមទម្ងន់អត្រាការប្រាក់ (Weighted Average Interest Rate), បំណុលដែលត្រូវទូទាត់នៅឆ្នាំបន្ទាប់ (Debt Maturing in One Year), រយៈពេលមធ្យមដល់ឥណប្រតិទាន (Average Time to Maturity – ATM), សមាសភាគបំណុលសាធារណៈជាប្រភេទអត្រាការប្រាក់ថេរ (Fixed Rate Debt)។

ដើម្បីធ្វើការវិភាគបំណុលតាមវិធីសាស្ត្រទាំងពីរខាងលើបាន ទាមទារចាំបាច់នូវធាតុចូលសំខាន់ៗមួយចំនួន បន្ថែមលើទិន្នន័យបំណុល ជាអាទិ៍៖ សេណារីយ៉ូនៃការខ្ចី និងសូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ ដូចមានលម្អិតក្នុងចំណុច ៥.២ និង ៥.៣ ខាងក្រោម។ ជាលក្ខខណ្ឌតម្រូវ ទិន្នន័យទាំងនេះត្រូវមានរយៈពេល ៣១ឆ្នាំ ក្នុងនោះ៖ ១) ការអនុវត្តជាក់ស្តែងរយៈពេល ១០ឆ្នាំ ចុងក្រោយ, ២) ឆ្នាំបច្ចុប្បន្ន, និង ៣) ព្យាករណ៍រយៈពេល ២០ឆ្នាំ ទៅមុខ។

## ៥.២. សេណារីយ៉ូនៃការខ្ចី

ក្នុងការគាំទ្រយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បីកំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព, និងចីរភាព និងការប្ដេជ្ញាចិត្តគោលនយោបាយ ដទៃទៀត ក៏ដូចជាដើម្បីប្រែក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០, រាជរដ្ឋាភិបាលកំណត់ទំហំនៃការខ្ចីថ្មីបន្ថែមសម្រាប់ឆ្នាំ២០២៤ - ២០២៨ តាមសេណារីយ៉ូចំនួន ២ សម្រាប់ជាមូលដ្ឋានក្នុងការវិភាគបំណុល ដូចខាងក្រោម៖

- **សេណារីយ៉ូទី១៖**
  - ✓ ទំហំនៃការខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍ៖ **១,៧ ប៊ីលាន** ទៅ **២,០ ប៊ីលានអេសដេអ៊ែ** (សមមូល **២,៣ ប៊ីលាន** ទៅ **២,៧ ប៊ីលានដុល្លារអាមេរិក** [៤])
  - ✓ ការបោះផ្សាយលក់មូលបត្ររដ្ឋក្នុងប្រទេស **៤៤០ ប៊ីលាន** ទៅ **៨៥០ ប៊ីលានរៀល**
- **សេណារីយ៉ូទី២៖**
  - ✓ ទំហំនៃការខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍ៖ **២,៥ ប៊ីលាន** ទៅ **៣,០ ប៊ីលានអេសដេអ៊ែ** (សមមូល **៣,៤ ប៊ីលាន** ទៅ **៤,១ ប៊ីលានដុល្លារអាមេរិក**)
  - ✓ ការបោះផ្សាយលក់មូលបត្ររដ្ឋក្នុងប្រទេស **៨០០ ប៊ីលាន** ទៅ **៤ ទ្រីលានរៀល**

## ៥.៣. សូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗសម្រាប់ការវិភាគ

ជាតុចូលដ៏សំខាន់ដែលមិនអាចខ្វះបាន សម្រាប់ការវិភាគបំណុល គឺ សូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ ដូចជា៖ កំណើន ផសស, ចំណូលថវិកាជាតិ, ការនាំចេញ, និងអត្រាប្តូរប្រាក់ ជាដើម។

ក្នុងក្របខ័ណ្ឌនៃការវិភាគបំណុលនេះ រាជរដ្ឋាភិបាលបានព្យាករដោយឈរលើគោលការណ៍ប្រយ័ត្នប្រយែង និងមានសង្គតិភាពជាមួយក្របខ័ណ្ឌយុទ្ធសាស្ត្រនិងគោលនយោបាយពាក់ព័ន្ធនានា ព្រមទាំងបានផ្ទៀងផ្ទាត់ជាមួយនឹងការព្យាកររបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ ផងដែរ។

ផ្អែកតាមក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ២០២៥ - ២០២៧ និងក្នុងបរិការណ៍សេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន សូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ សម្រាប់ឆ្នាំ២០២៤ - ២០២៨ ត្រូវបានព្យាករ ដូចខាងក្រោម៖

- **កំណើន ផសស៖** ជាមធ្យម ក្នុងរង្វង់ **៦,៥ ភាគរយ**
- **ចំណូលថវិកាជាតិ៖** ជាមធ្យមកើនក្នុងរង្វង់ **០,១ ពិន្ទុភាគរយ** នៃ ផសស
- **ការនាំចេញ៖** ជាមធ្យមកើនក្នុងរង្វង់ **១២ ភាគរយ** ក្នុងមួយឆ្នាំ
- **អត្រាប្តូរប្រាក់៖** **៤ ០៨៣ រៀល** - **៤ ១០០ រៀល** ក្នុងមួយដុល្លារអាមេរិក។

ដោយឡែក, ការព្យាករនេះក៏បានផ្អែកតាមស្ថានភាពទីផ្សារនាពេលបច្ចុប្បន្ន និងការរំពឹងទុកក្នុងរយៈពេលខ្លីទៅមធ្យម ដែលបានវិភាគ និងវាយតម្លៃដោយដៃគូអន្តរជាតិមួយចំនួនដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក, ធនាគារអភិវឌ្ឍន៍អាស៊ី ដែលសន្មតថា អត្រាការប្រាក់ទីផ្សារនៅបន្តកើនឡើង ដែលបណ្តាលមកពីភាពតានតឹងនៃភូមិសាស្ត្រនយោបាយ, ការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍ ក្នុងការឆ្លើយតបទៅនឹងសម្ពាធអតិផរណា, ភាពរឹងស្ងួតនៃប្រភពហិរញ្ញប្បទាន និងរនាំងសេដ្ឋកិច្ច ក៏ដូចជា ការមិនទាន់លូតលាស់គ្រប់ជ្រុងជ្រោយនៃការអភិវឌ្ឍទីផ្សារមូលបត្រក្នុងប្រទេស ជាអាទិ៍។

---

[៤] ១ អេសដេអ៊ែ ស្មើនឹង ១,៣៥ ដុល្លារអាមេរិក។

## ៥.៤. លទ្ធផលនៃការវិភាគ

លទ្ធផលនៃការវិភាគបង្ហាញថា៖

**ក. សេណារីយ៉ូទី១៖** ករណីទំហំនៃការខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍក្នុងរង្វង់ **១,៧ ប៊ីលាន** ទៅ **២,០ ប៊ីលានអេសដេអ៊ែ** (សមមូលនឹងប្រមាណ **២,៣ ប៊ីលាន** ទៅ **២,៧ ប៊ីលានដុល្លារអាម៉េរិក**) និងការបោះផ្សាយលក់មូលបត្ររដ្ឋក្នុងរង្វង់ **៤៤០ ប៊ីលាន** ទៅ **៨៥០ ប៊ីលានរៀល** ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០២៤ - ២០២៨ រាល់សូចនាករបំណុលគន្លឹះៗទាំងអស់ សុទ្ធតែស្ថិតក្រោមអនុបាតគោលដូចមានលម្អិតក្នុងតារាង និងក្រាហ្វទី៧ ខាងក្រោម។ ដូចនេះ, មានន័យថា ស្ថានភាពបំណុលសាធារណៈរបស់កម្ពុជាមាន «**ចីរភាព**» និង «**ហានិភ័យកម្រិតទាប**»។

### ក្រាហ្វទី៧៖ លទ្ធផលនៃការវិភាគចីរភាពបំណុលតាមសេណារីយ៉ូទី១




* *លទ្ធផលនៃការវិភាគនេះ នឹងត្រូវធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ*

## តារាងទី៥៖ លទ្ធផលនៃការវិភាគចីរភាពបំណុលតាមសេណារីយ៉ូទី១

| សូចនាករបំណុល Debt Indicator | | អនុបាតគោល Threshold | 2024 | 2025 | 2026 | 2027 | 2028 |
|---|---|---|---|---|---|---|---|
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប/ PV of Total Public Debt | | | | | | | |
| *ធៀបនឹង ផសស to GDP* | Baseline | 55% | 19.3 | 19.4 | 19.2 | 19.0 | 18.5 |
| | Sensitivity | | 19.3 | 21.6 | 24.7 | 26.2 | 27.3 |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស/ PV of Public and Publicly Guaranteed External Debt | | | | | | | |
| *ធៀបនឹង ផសស to GDP* | Baseline | 40% | 19.0 | 18.9 | 18.5 | 18.0 | 17.6 |
| | Sensitivity | | 19.0 | 25.8 | 37.2 | 35.9 | 34.5 |
| *ធៀបនឹង ការនាំចេញ to Exports* | Baseline | 180% | 29.1 | 27.4 | 25.8 | 24.5 | 24.0 |
| | Sensitivity | | 29.1 | 39.5 | 57.8 | 54.1 | 52.4 |
| អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស/ Public and Publicly Guaranteed External Debt Service | | | | | | | |
| *ធៀបនឹង ការនាំចេញ to Exports* | Baseline | 15% | 1.8 | 1.9 | 2.0 | 1.8 | 1.7 |
| | Sensitivity | | 1.8 | 2.1 | 2.6 | 2.8 | 2.7 |
| *ធៀបនឹង ចំណូលថវិកាជាតិ to Revenue* | Baseline | 18% | 7.8 | 8.8 | 9.1 | 8.7 | 7.9 |
| | Sensitivity | | 7.8 | 9.1 | 10.9 | 12.1 | 11.2 |

## តារាងទី៦៖ លទ្ធផលនៃការវិភាគថ្លៃ និងហានិភ័យបំណុលតាមសេណារីយ៉ូទី១

| សូចនាករថ្លៃ និងហានិភ័យ Cost-Risk Indicators | | 2023 | 2024 | 2025 | 2026 | 2027 | 2028 |
|---|---|---|---|---|---|---|---|
| **ថ្លៃដើមហិរញ្ញប្បទាន** Cost of Debt | មធ្យមទម្ងន់អត្រាការប្រាក់ (% ក្នុងមួយឆ្នាំ) Weighted Average Interest Rate (% p.a.) | 1.18 | 1.16 | 1.19 | 1.26 | 1.29 | 1.35 |
| **ហានិភ័យបុនហិរញ្ញប្បទាន** Refinancing Risk | រយៈពេលមធ្យមដល់តំណាប្រតិទាន (ឆ្នាំ) Average Time to Maturity - ATM (year) | 10.1 | 10.9 | 11.2 | 11.5 | 11.8 | 11.9 |
| | បំណុលដែលត្រូវទូទាត់នៅឆ្នាំបន្ទាប់ (% នៃសរុប) Debt Maturing in 1 year (% of total) | 4.0 | 4.6 | 4.8 | 4.9 | 4.7 | 5.9 |
| **ហានិភ័យអត្រាការប្រាក់** Interest Rate Risk | សមាសភាគបំណុលសាធារណៈជាប្រភេទអត្រាការប្រាក់ថេរ (% នៃសរុប) Fixed Rate Debt (% of total) | 99.5 | 98.6 | 97.8 | 96.4 | 94.4 | 92.3 |

**ខ- សេណារីយ៉ូទី២៖** ករណីទំហំនៃការខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍក្នុងរង្វង់ **២,៥ ប៊ីលាន** ទៅ **៣,០ ប៊ីលានអេសឌីអ៊ែ** (សមមូលនឹងប្រមាណ **៣,៤ ប៊ីលាន** ទៅ **៤,១ ប៊ីលានដុល្លារអាមេរិក**) និងការបោះផ្សាយលក់មូលបត្ររដ្ឋក្នុងរង្វង់ **៨០០ ប៊ីលាន** ទៅ **៤ ទ្រីលានរៀល** ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០២៤ - ២០២៨ នោះស្ថានភាពបំណុលសាធារណៈរបស់កម្ពុជា អាចប្រឈមនឹង «ហានិភ័យកម្រិតមធ្យម»។ តាមការវិភាគវេទយិតភាពរាល់សូចនាករបំណុលគន្លឹះៗទាំងអស់ នៅតែស្ថិតក្រោមអនុបាតគោលដែលបានកំណត់ ក៏ប៉ុន្តែមានសូចនាករចំនួន ២ បានទៅកៀកនឹងអនុបាតគោល ដែលកម្ពុជាត្រូវប្រយ័ត្នប្រយែងខ្លាំង ពោលគឺ អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសធៀបនឹង ផសស និងអនុបាតសេវាបំណុលសាធារណៈក្រៅប្រទេសធៀបនឹងចំណូលថវិកាជាតិ ក្នុងករណីមានការរងនូវការប៉ះទង្គិច (Shock) ណាមួយ ក្នុងចំណោមករណីទាំង ៤ រួមមាន៖ ១) តម្លៃ

រូបិយវត្ថុជាតិធ្លាក់ចុះគំហុក ធៀបនឹង រូបិយប័ណ្ណបរទេស, ២) ការនាំចេញរងការប៉ះទង្គិចខ្លាំង, ៣) ការកើតឡើងនូវបំណុលចេញពីកាតព្វកិច្ចបំណុលជាយថាហេតុ, និង ៤) កំណើន ផសស ថមថយខ្លាំង។

## ក្រាហ្វទី៨៖ លទ្ធផលនៃការវិភាគចីរភាពបំណុលតាមសេណារីយ៉ូទី២




* លទ្ធផលនៃការវិភាគនេះ នឹងត្រូវធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ

### តារាងទី៧ ៖លទ្ធផលនៃការវិភាគចីរភាពបំណុលតាមសេណារីយ៉ូទី២

| សូចនាករបំណុល<br>Debt Indicator | | អនុបាតគោល<br>Threshold | 2024 | 2025 | 2026 | 2027 | 2028 |
|---|---|---|---|---|---|---|---|
| **អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប/ PV of Total Public Debt** | | | | | | | |
| *ធៀបនឹង ផសស*<br>*to GDP* | Baseline | 55% | 19.7 | 20.6 | 21.5 | 22.6 | 23.4 |
| | Sensitivity | | 19.7 | 22.8 | 27.3 | 30.3 | 32.9 |
| **អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស/ PV of Public and Publicly Guaranteed External Debt** | | | | | | | |
| *ធៀបនឹង ផសស*<br>*to GDP* | Baseline | 40% | 19.2 | 19.4 | 19.4 | 19.7 | 19.9 |
| | Sensitivity | | 19.2 | 26.8 | 40.3 | 39.3 | 38.6 |
| *ធៀបនឹង ការនាំចេញ*<br>*to Exports* | Baseline | 180% | 29.4 | 28.1 | 27.2 | 26.7 | 27.2 |
| | Sensitivity | | 29.4 | 41.1 | 61.9 | 59.2 | 58.6 |
| **អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស/ Public and Publicly Guaranteed External Debt Service** | | | | | | | |
| *ធៀបនឹង ការនាំចេញ*<br>*to Exports* | Baseline | 15% | 1.8 | 2.0 | 2.0 | 1.9 | 1.8 |
| | Sensitivity | | 1.8 | 2.1 | 2.7 | 3.1 | 3.0 |
| *ធៀបនឹង ចំណូលថវិកាជាតិ*<br>*to Revenue* | Baseline | 18% | 7.8 | 8.9 | 9.4 | 9.1 | 8.4 |
| | Sensitivity | | 7.8 | 11.9 | 13.1 | 14.5 | 14.2 |

### តារាងទី៨៖ លទ្ធផលនៃការវិភាគថ្លៃ និងហានិភ័យបំណុលតាមសេណារីយ៉ូទី២

| សូចនាករថ្លៃ និងហានិភ័យ<br>Cost-Risk Indicators | | 2023 | 2024 | 2025 | 2026 | 2027 | 2028 |
|---|---|---|---|---|---|---|---|
| **ថ្លៃដើមហិរញ្ញប្បទាន**<br>Cost of Debt | មធ្យមទម្ងន់អត្រាការប្រាក់ (% ក្នុងមួយឆ្នាំ)<br>Weighted Average Interest Rate (% p.a.) | 1.18 | 1.20 | 1.42 | 1.67 | 1.92 | 2.20 |
| **ហានិភ័យបុនហិរញ្ញប្បទាន**<br>Refinancing Risk | រយៈពេលមធ្យមដល់ឥណប្រតិទាន (ឆ្នាំ)<br>Average Time to Maturity - ATM (year) | 10.1 | 10.1 | 10.2 | 10.3 | 10.5 | 10.7 |
| | បំណុលដែលត្រូវទូទាត់នៅឆ្នាំបន្ទាប់ (% នៃសរុប)<br>Debt Maturing in 1 year (% of total) | 4.0 | 4.7 | 4.9 | 5.5 | 5.8 | 6.6 |
| **ហានិភ័យអត្រាការប្រាក់**<br>Interest Rate Risk | សមាសភាគបំណុលសាធារណៈជាប្រភេទអត្រាការប្រាក់ថេរ (% នៃសរុប)<br>Fixed Rate Debt (% of total) | 99.5 | 98.5 | 97.4 | 95.4 | 92.5 | 89.4 |

ជាសន្និដ្ឋានរួម ក្នុងបរិការណ៍សេដ្ឋកិច្ចបច្ចុប្បន្ន, សម្រាប់ឆ្នាំ២០២៤ - ២០២៨ កម្ពុជាមានសមត្ថភាពខ្ចីពីក្រៅប្រទេស ក្នុងរង្វង់ **១,៧ ប៊ីលាន** ទៅ **២ ប៊ីលានអេសដេអ៊ែ** ក្នុងមួយឆ្នាំ ហើយក្នុងកាលៈទេសៈចាំបាច់ អាចបង្កើនដល់ **២,៥ ប៊ីលានអេសដេអ៊ែ** ក្នុងមួយឆ្នាំ ប៉ុន្តែមិនត្រូវលើសពី **១០ ប៊ីលានអេសដេអ៊ែ** (សមមូលនឹងប្រមាណ **១៣,៥ ប៊ីលានដុល្លារអាមេរិក**) ក្នុងរយៈពេល ៥ឆ្នាំ និង បោះផ្សាយលក់មូលបត្ររដ្ឋក្នុងប្រទេស ក្នុងរង្វង់ **៥០០ ប៊ីលាន** ទៅ **១ ទ្រីលានរៀល** ក្នុងមួយឆ្នាំ ហើយក្នុងកាលៈទេសៈចាំបាច់ អាចបង្កើនដល់ **១,២ ទ្រីលានរៀល** ក្នុងមួយឆ្នាំ ប៉ុន្តែមិនត្រូវលើសពី **៤ ទ្រីលានរៀល** (សមមូលនឹងប្រមាណ **១ ប៊ីលានដុល្លារអាមេរិក**) ក្នុងរយៈពេល ៥ឆ្នាំ អាស្រ័យតាមវិវឌ្ឍនាការម៉ាក្រូសេដ្ឋកិច្ចជាក់ស្តែង។ ទន្ទឹមនេះ, ដើម្បីបន្តរក្សាចីរភាពបំណុលសាធារណៈក្នុងរយៈពេលមធ្យម និងវែង ព្រមទាំងកម្រិតហានិភ័យបំណុលឱ្យនៅទាបបាន លុះត្រាតែ៖

- សម្រិតសម្រាំងកៀរគរនូវឥណទានសម្បទានខ្ពស់ ហើយមានហានិភ័យទាប និងខ្ចីសម្រាប់តែវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមានផលិតភាពសេដ្ឋកិច្ចខ្ពស់ និងវិស័យបង្កើនផលិតភាពផលិតកម្ម សំដៅទ្រទ្រង់ចីរភាពកំណើនរយៈពេលវែង។ រាល់គម្រោងវិនិយោគសាធារណៈ ដែលនឹងត្រូវហិរញ្ញប្បទានដោយឥណទានសម្បទាន ត្រូវតែជាគម្រោងដែលមានស្តង់ដា និងគុណភាពខ្ពស់ ស្របតាមគោលការណ៍គ្រឹះនៃការគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិនៅក្នុងដំណាក់កាលថ្មី ពិសេស ធានាបាននូវចីរភាពសេដ្ឋកិច្ច, សង្គម, បរិស្ថាន, និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។
- ចំពោះទុនបានពីការបោះផ្សាយលក់មូលបត្ររដ្ឋក្នុងប្រទេស ត្រូវប្រើប្រាស់ជាអាទិភាពសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈ ស្របតាមច្បាប់ស្តីពីមូលបត្ររដ្ឋ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ព្រមទាំងត្រូវគោរពតាមគោលការណ៍ចីរភាពបំណុលសាធារណៈ។ គម្រោងវិនិយោគសាធារណៈដែលហិរញ្ញប្បទានដោយទុនបានពីការបោះផ្សាយលក់មូលបត្ររដ្ឋក្នុងប្រទេស ត្រូវតែជា៖ ១) គម្រោងដែលអាចហុចផលចំណេញផ្នែកសេដ្ឋកិច្ច ឬហិរញ្ញវត្ថុភ្លាមៗ និង ២) គម្រោងតាមយន្តការឱ្យខ្ចីបន្តដែលអាចបង្កើតចំណូលដោយផ្ទាល់ ហើយផ្តល់ផលហិរញ្ញវត្ថុដែលអាចទូទាត់ថ្លៃដើមនៃឥណទានបាន ឬផលសេដ្ឋកិច្ចខ្ពស់។
- សម្រាប់ឆ្នាំ២០២៤ - ២០២៨ កំណើន ផសស នឹងសម្រេចបានជាមធ្យម ក្នុងរង្វង់ **៦,៥ ភាគរយ** ហើយកំណើនចំណូលថវិកាជាតិនឹងសម្រេចបាន ជាមធ្យម **០,១ ពិន្ទុភាគរយ** នៃ ផសស ក្នុងមួយឆ្នាំ តាមគោលដៅកំណត់នៅក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ។
- បន្តអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នូវកម្មវិធីកែទម្រង់គន្លឹះៗ ដែលជាមូលដ្ឋាននៃការទ្រទ្រង់ចីរភាពកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង ដូចជា៖ ១) កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២) កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ, និង ៣) កម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។ល។
- បន្តពង្រឹងការគ្រប់គ្រងកាតព្វកិច្ចបំណុលជាយថាហេតុ ប្រកបដោយភាពប្រយ័ត្នប្រយែងខ្ពស់ ជាពិសេសហានិភ័យដែលអាចកើតចេញពី ការធានារបស់រដ្ឋចំពោះគម្រោងវិនិយោគសាធារណៈតាមយន្តការ PPP និងវិស័យធនាគារនិងហិរញ្ញវត្ថុ។
- បន្តអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ហិរញ្ញប្បទានពីការខ្ចីប្រាក់ពីគេ។

# ជំពូកទី៦
# វិធានការជាយុទ្ធសាស្ត្រ

# ជំពូកទី៦
# វិធានការជាយុទ្ធសាស្ត្រ

ក្នុងគោលបំណងធានានូវប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ រួមទាំងមូលបត្ររដ្ឋ សំដៅរួមចំណែកក្នុងការបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន ឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០២៤ - ២០២៨ ដូចតទៅ៖

## ៦.១. កំណត់ពិតាននៃការខ្ចីប្រាក់ពីគេ ដូចខាងក្រោម៖

- ការខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍក្រៅប្រទេស ក្នុងរង្វង់ **១,៧ ប៊ីលាន** ទៅ **២ ប៊ីលានអេសឌីអ៊ែ** ក្នុងមួយឆ្នាំ ហើយក្នុងកាលៈទេសៈចាំបាច់ អាចបង្កើនដល់ **២,៥ ប៊ីលានអេសឌីអ៊ែ** ក្នុងមួយឆ្នាំ ប៉ុន្តែ មិនត្រូវលើសពី **១០ ប៊ីលានអេសឌីអ៊ែ** (សមមូលនឹងប្រមាណ **១៣,៥ ប៊ីលានដុល្លារអាម៉េរិក**) ក្នុងរយៈពេល ៥ឆ្នាំ។
- ការបោះផ្សាយលក់មូលបត្ររដ្ឋក្នុងប្រទេស ក្នុងរង្វង់ **៥០០ ប៊ីលាន** ទៅ **១ ទ្រីលានរៀល** ក្នុងមួយឆ្នាំ ហើយក្នុងកាលៈទេសៈចាំបាច់ អាចបង្កើនដល់ **១,២ ទ្រីលានរៀល** ក្នុងមួយឆ្នាំ ប៉ុន្តែ មិនត្រូវលើសពី **៤ ទ្រីលានរៀល** (សមមូលនឹងប្រមាណ **១ ប៊ីលានដុល្លារអាម៉េរិក**) ក្នុងរយៈពេល ៥ឆ្នាំ។
- ទន្ទឹមនេះ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំ និងធ្វើបច្ចុប្បន្នកម្មផែនការខ្ចីប្រាក់ពីគេប្រចាំឆ្នាំ (Annual Borrowing Plan) តាមការចាំបាច់។

## ៦.២. កំណត់ពិតាននៃការធានារបស់រដ្ឋ ដូចខាងក្រោម៖

- ការធានាទូទាត់សរុបប្រចាំឆ្នាំចំពោះគម្រោងថ្មី សម្រាប់ឆ្នាំ២០២៤ - ២០២៨ មិនត្រូវលើសពី **១០ ភាគរយ** នៃចំណូលថវិកាជាតិនាឆ្នាំកន្លងទៅ (Accumulate of Annual Payment Guarantee of New Projects as of Year N < **10%** of Total Domestic Revenue of Year N-1)។ ក្នុងករណីដែលការធានាទូទាត់សរុបលើសពី **១០ ភាគរយ** ត្រូវមានការសម្រេចពីនាយករដ្ឋមន្ត្រី តាមរយៈការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បន្តមិនផ្តល់ការធានាឥណទាន (Credit/Loan Guarantee)ដោយផ្ទាល់ពីរដ្ឋចំពោះវិស័យឯកជន។

## ៦.៣. កំណត់ពិតានសូចនាករបំណុលគន្លឹះៗ ដូចខាងក្រោម៖

### ៦.៣.១. សូចនាករចីរភាពបំណុល ដែលជាយុថ្កាហិរញ្ញវត្ថុសាធារណៈ (Fiscal Anchor)

- អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប ធៀបនឹង ផសស (Present Value of Total Public Debt to GDP Ratio) ត្រូវស្ថិតក្រោម **៥៥ ភាគរយ**។
- អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផសស (Present Value of Public and Publicly Guaranteed External Debt to GDP Ratio) ត្រូវស្ថិតក្រោម **៤០ ភាគរយ**។
- អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ (Present Value of Public and Publicly Guaranteed External Debt to Exports Ratio) ត្រូវស្ថិតក្រោម **១៨០ ភាគរយ**។
- អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ (Public and Publicly Guaranteed External Debt Service to Exports Ratio) ត្រូវស្ថិតក្រោម **១៥ ភាគរយ**។
- អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ចំណូលថវិកាជាតិ (Public and Publicly Guaranteed External Debt Service to Revenue Ratio) ត្រូវស្ថិតក្រោម **១៨ ភាគរយ**។

### ៦.៣.២.សូចនាករថ្លៃ និងហានិភ័យបំណុល

- មធ្យមទម្ងន់អត្រាការប្រាក់នៃសន្និធិបំណុលសាធារណៈសរុប ត្រូវស្ថិតក្រោម **៣ ភាគរយ** ក្នុងមួយឆ្នាំ (Weighted Average Interest Rate < 3% p.a.)។
- រយៈពេលមធ្យមដល់ឥណប្រតិទាននៃសន្និធិបំណុលសាធារណៈសរុប ត្រូវមានយ៉ាងតិចបង្គង់ **៨ ឆ្នាំ** (Minimum Average Time to Maturity ≈ 8 Years)។
- បំណុលដែលត្រូវទូទាត់នៅឆ្នាំបន្ទាប់ ត្រូវស្ថិតក្រោម **១០ ភាគរយ** នៃសន្និធិបំណុលសាធារណៈសរុប (Debt Maturing in One Year < 10% of Total Public Debt)។
- សមាសភាគបំណុលសាធារណៈជាប្រភេទអត្រាការប្រាក់ថេរ ត្រូវមានយ៉ាងតិចបង្គង់ **៩០ ភាគរយ** នៃសន្និធិបំណុលសាធារណៈសរុប (Minimum Fixed Rate Debt ≈ 90% of Total Public Debt)។

ទន្ទឹមនេះ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពិនិត្យ និងតាមដានជាប្រចាំនូវរាល់សូចនាករទាំងនេះ ហើយធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់។

## ៦.៤. កំណត់គោលការណ៍នៃការប្រើប្រាស់ហិរញ្ញប្បទានពីការខ្ចីប្រាក់ពីគេ ដូចខាងក្រោម៖

- ចំពោះហិរញ្ញប្បទានដែលកៀរគរតាមរយៈការខ្ចីពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍក្រៅប្រទេស ត្រូវប្រើប្រាស់សម្រាប់វិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ជាពិសេស ការបង្កើនផលិតភាពផលិតកម្ម, ការជំរុញការតភ្ជាប់, និងការលើកកម្ពស់សមត្ថភាពប្រកួតប្រជែង ដូចជា៖ ផ្លូវថ្នល់, ស្ពាន, ប្រព័ន្ធស្រោចស្រព, អគ្គិសនី, កំពង់ផែ, ការផ្គត់ផ្គង់ទឹកស្អាតនៅទីប្រជុំជន, ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់, ការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម, ឡជីស្ទីក, ឌីជីថល ជាដើម។ ទន្ទឹមនេះ, គម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈទាំងនោះ ត្រូវមានស្តង់ដា និងគុណភាពខ្ពស់ ស្របតាមគោលការណ៍គ្រឹះនៃការគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិនៅក្នុងដំណាក់កាលថ្មី ពិសេស ធានាបាននូវចីរភាពសេដ្ឋកិច្ច, សង្គម, បរិស្ថាន, និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ បន្ថែមលើនេះ, ចំពោះគម្រោងណាដែលអាចបង្កើតចំណូលដោយផ្ទាល់ ត្រូវអនុវត្តតាមយន្តការឱ្យខ្ចីបន្ត ឬយន្តការផ្សេងទៀតដែលមានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។
- ចំពោះទុនបានពីការបោះផ្សាយលក់មូលបត្ររដ្ឋក្នុងប្រទេស ត្រូវប្រើប្រាស់ជាអាទិភាពសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈ ស្របតាមច្បាប់ស្តីពីមូលបត្ររដ្ឋ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ព្រមទាំងត្រូវគោរពតាមគោលការណ៍ចីរភាពបំណុលសាធារណៈ។ គម្រោងវិនិយោគសាធារណៈដែលហិរញ្ញប្បទានដោយទុនបានពីការបោះផ្សាយលក់មូលបត្ររដ្ឋក្នុងប្រទេស ត្រូវតែជា៖ ១) គម្រោងដែលអាចហុចផលចំណេញផ្នែកសេដ្ឋកិច្ច ឬហិរញ្ញវត្ថុភ្លាមៗ និង ២) គម្រោងតាមយន្តការឱ្យខ្ចីបន្តដែលអាចបង្កើតចំណូលដោយផ្ទាល់ ហើយផ្តល់ផលហិរញ្ញវត្ថុដែលអាចទូទាត់ថ្លៃដើមនៃឥណទានបាន ឬផលសេដ្ឋកិច្ចខ្ពស់; ដោយឡែក ក្នុងករណីតម្រូវឱ្យមានការឧបត្ថម្ភធនសម្រាប់គម្រោងឱ្យខ្ចីបន្ត គឺត្រូវមានការគណនាច្បាស់លាស់ និងត្រូវស្ថិតក្នុងភាពទ្រទ្រង់បាននៃថវិកាជាតិ និងក្នុងក្របខ័ណ្ឌនៃការធានាបាននូវចីរភាពបំណុលសាធារណៈ ព្រមទាំងប្រសិទ្ធភាពសេដ្ឋកិច្ចរបស់គម្រោង។

## ៦.៥. បន្តធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យបានទូលំទូលាយ ពីប្រភពដូចខាងក្រោម៖

### ៦.៥.១. ស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍក្រៅប្រទេស ដោយរាជរដ្ឋាភិបាល នឹង៖

- បន្តពង្រឹងកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍក្រៅប្រទេសដែលមានស្រាប់ ដើម្បីកៀរគរហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានកម្រិតសម្បទានឬលក្ខខណ្ឌអនុគ្រោះខ្ពស់។
- ពង្រីកកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍក្រៅប្រទេសថ្មីផ្សេងទៀត។

- សិក្សារៀបចំឯកសារទស្សនាទានស្តីពី «ផែនការអន្តរកាល (Transition Plan)» ដើម្បីកៀរគរហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានកម្រិតសម្បទានឬលក្ខខណ្ឌអនុគ្រោះខ្ពស់ សម្រាប់បំពេញតម្រូវការវិនិយោគសាធារណៈដែលបន្សាំនឹងការប្រែប្រួលអាកាសធាតុ(Climate Adaptation)។
- បន្តរក្សាភាពបត់បែនក្នុងការទទួលយកឥណទានដែលមានកម្រិតសម្បទាន មធ្យម ឬទាប អាស្រ័យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ច, លទ្ធភាពថវិកាជាតិ, និងករណីគម្រោងវិនិយោគសាធារណៈនីមួយៗ។ ក្នុងករណីពិនិត្យឃើញថា អត្រាការប្រាក់នៃឥណទានរបស់ដៃគូអភិវឌ្ឍ មាននិន្នាការកើនឡើងខ្ពស់ ដែលកម្ពុជាពុំអាចទទួលយកបាន រាជរដ្ឋាភិបាលនឹងពិចារណាផ្អាកដកសាច់ប្រាក់ ឬ ផ្អាកខ្ចី ហើយស្វែងរកប្រភពហិរញ្ញប្បទានផ្សេងមកជំនួស។

**៦.៥.២. ការបោះផ្សាយលក់មូលបត្ររដ្ឋ** ដោយរាជរដ្ឋាភិបាល នឹង៖

- បន្តអភិវឌ្ឍមូលបត្ររដ្ឋ តាមរយៈការអនុវត្តផែនការសកម្មភាព ដែលបានដាក់ចេញក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨។
- សិក្សាលម្អិតលើជម្រើសក្នុងការបោះផ្សាយលក់មូលបត្ររដ្ឋជាដុល្លារអាម៉េរិក និង/ឬ ការអនុវត្តវិធីសាស្ត្រ FX-Linked Bonds ដើម្បីបង្កើនឱ្យមានការចូលរួមកាន់តែច្រើនពីវាល់វិនិយោគិនសក្តានុពល។

**៦.៥.៣. ប្រភពដទៃទៀត** ដោយរាជរដ្ឋាភិបាល នឹង៖

- បន្តខិតខំកៀរគរហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានកម្រិតសម្បទានឬលក្ខខណ្ឌអនុគ្រោះខ្ពស់ ពីប្រភពផ្សេងទៀតឱ្យបានច្រើនបំផុត តាមដែលអាចធ្វើបាន តាមវិធីសាស្ត្រហិរញ្ញប្បទានចម្រុះ ដើម្បីកាត់បន្ថយថ្លៃដើម និងហានិភ័យនៃការខ្ចី ក្នុងករណីហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុនិងដៃគូអភិវឌ្ឍក្រៅប្រទេស និងពីការបោះផ្សាយលក់មូលបត្ររដ្ឋ មានអត្រាការប្រាក់ខ្ពស់ ឬប្រឈមនឹងហានិភ័យទីផ្សារខ្លាំង ឬតម្រូវឱ្យអនុវត្តតាមគោលការណ៍បៃតង។
- ខ្ចីឥណទានសម្បទាន ឬប្រើប្រាស់ធនធានរបស់រដ្ឋពីប្រភពផ្សេងទៀត ដើម្បីទាក់ទាញទុនពីវិស័យឯកជនតាមរយៈយន្តការហិរញ្ញប្បទានចម្រុះ, យន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន, និងការវិនិយោគផ្ទាល់ ប៉ុន្តែត្រូវមានការប្រុងប្រយ័ត្នក្នុងការផ្តល់ការធានារបស់រដ្ឋចំពោះគម្រោង PPP ដែលអាចបង្កជាហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ មកលើស្ថានភាពបំណុលសាធារណៈ និងសម្ពាធលើថវិកាជាតិ។
- រៀបចំ «**ក្របខ័ណ្ឌគោលនយោបាយហិរញ្ញប្បទានជាតិ**» សម្រាប់ជាត្រីវិស័យតម្រង់ទិសការកៀរគរហិរញ្ញប្បទាន និងវិនិយោគ សម្រាប់គាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា។
- បន្តខិតខំកៀរគរហិរញ្ញប្បទានពីប្រភពផ្សេងៗទៀត ស្របតាមបទប្បញ្ញត្តិជាធរមាន។

## ៦.៦. បន្តពង្រឹងការតាមដាន និងគ្រប់គ្រងលើហានិភ័យបំណុលពាក់ព័ន្ធ ដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈដែលគ្របដណ្តប់នូវគ្រប់ហានិភ័យបំណុលពាក់ព័ន្ធទាំងអស់ ដោយរួមទាំងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលអាចកើតចេញពីការធានាទូទាត់របស់រដ្ឋ។
- ធនាគារជាតិនៃកម្ពុជា ត្រូវបន្តសិក្សា និងតាមដានលើស្ថានភាព និងនិន្នាការនៃបំណុលរបស់វិស័យឯកជន និងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលអាចកើតចេញពីវិស័យធនាគារនិងហិរញ្ញវត្ថុ ហើយចែករំលែកព័ត៌មាន និងទិន្នន័យទាំងនោះមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើការវាយតម្លៃការគ្រប់គ្រងបំណុលសាធារណៈ (DeMPA) ដើម្បីជាមូលដ្ឋានបន្តកែលម្អប្រព័ន្ធគ្រប់គ្រងបំណុលសាធារណៈ។

**៦.៧. បន្តអនុវត្តគោលការណ៍មជ្ឈការនៃការគ្រប់គ្រងបំណុលសាធារណៈ** ដូចខាងក្រោម៖

- រាជរដ្ឋាភិបាល នឹងបន្តអនុវត្តឱ្យបានម៉ឺងម៉ាត់នូវគោលការណ៍មជ្ឈការនៃការគ្រប់គ្រងបំណុលសាធារណៈ ស្របតាមមាត្រា ៧៨ នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ គឺ *«ស្ថិតក្រោមលក្ខខណ្ឌ និងកម្រិតកំណត់នៃសិទ្ធិអំណាចដែលបានផ្តល់ក្នុងច្បាប់ហិរញ្ញវត្ថុ និងក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុម្នាក់គត់ ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេរួមបញ្ចូលនូវការបោះផ្សាយមូលបត្ររដ្ឋ ការទទួលហិរញ្ញប្បទានឥតសំណង ការវិនិយោគលើទ្រព្យសកម្មហិរញ្ញវត្ថុ ការធានានិងការសន្យាផ្នែកហិរញ្ញវត្ថុនានា និងមានសិទ្ធិក្នុងការឱ្យប្រាក់គេខ្ចី ទាំងក្នុងនិងក្រៅប្រទេស។ ក្រៅពីនេះ គ្មានអ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតណាមួយ មានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេឬឱ្យប្រាក់គេខ្ចី ឬចេញជាលិខិតធានា ឬក៏ធ្វើទង្វើណាផ្សេងៗទៀត ដោយផ្ទាល់ឬដោយប្រយោល ដែលអាចនាំឱ្យកើតមាននូវបំណុលឬបន្ទុកហិរញ្ញវត្ថុផ្សេងទៀត ដោយផ្ទាល់ឬដោយប្រយោលដល់ព្រះរាជាណាចក្រកម្ពុជាបានទេ»*។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំដំឡើងអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ឱ្យទៅជាច្បាប់ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ សំដៅធានាបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា។

**៦.៨. បន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការឱ្យប្រាក់គេខ្ចី** ដូចខាងក្រោម៖

- បន្តអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ជាពិសេស ប្រកាសស្តីពីគោលការណ៍ និងនីតិវិធីគ្រប់គ្រងការផ្តល់ឥណទានដល់សហគ្រាសសាធារណៈ, គ្រឹះស្ថានសាធារណៈ, នីតិបុគ្គលសាធារណៈដទៃទៀត, និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាពខ្ពស់។
- សិក្សា និងរៀបចំគោលការណ៍ណែនាំសម្រាប់តាមដាន និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុរបស់ឥណាយិកដែលទទួលបានឥណទានពីរដ្ឋ។

**៦.៩. បន្តអនុវត្តគោលនយោបាយ និងកម្មវិធីកែទម្រង់ក្នុងវិស័យសំខាន់ៗ** រួមមាន៖ ១) កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២) កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ, ៣) កម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, និង ៤) កម្មវិធីកែទម្រង់ពាក់ព័ន្ធផ្សេងទៀតរបស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងអភិបាលកិច្ចក្នុងវិស័យសាធារណៈ សំដៅរួមចំណែកសម្រេចបាននូវចីរភាពកំណើនសេដ្ឋកិច្ច និងធ្វើឱ្យប្រសើរឡើងនូវពិន្ទុគោលនយោបាយ និងគ្រប់គ្រងបំណុលសាធារណៈ និងចំណាត់ថ្នាក់ឥណទានរបស់កម្ពុជា ដែលនឹងជួយកាត់បន្ថយថ្លៃដើម និងហានិភ័យនៃការខ្ចី ក៏ដូចជា បង្កើនទំនុកចិត្ត និងទាក់ទាញវិស័យឯកជនមកចូលរួមវិនិយោគផងដែរ។ ក្នុងន័យនេះ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំបង្កើតយន្តការអន្តរក្រសួង ស្ថាប័ន ក្នុងការរៀបចំ «**ក្របខ័ណ្ឌគោលនយោបាយស្តីពីការពង្រឹងចំណាត់ថ្នាក់ឥណទានរបស់ប្រទេស**» ដើម្បីកំណត់ឱ្យបានជាក់លាក់នូវចក្ខុវិស័យ, បង្គោលចរ, វិធានការជាយុទ្ធសាស្ត្រ, និងផែនការសកម្មភាពសំដៅបង្កើនចំណាត់ថ្នាក់ឥណទានរបស់កម្ពុជា (Sovereign Credit Rating) ឱ្យឈានដល់កម្រិតខ្ពស់បំផុត (AAA) ត្រឹមឆ្នាំ២០៥០។

ទន្ទឹមនេះ, ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបន្តអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ (Public Investment Management System Reform Strategy) ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងអនុវត្តគម្រោងវិនិយោគសាធារណៈ ដោយត្រូវផ្សារភ្ជាប់ទៅនឹងគោលការណ៍សមិទ្ធកម្ម និងត្រូវអនុលោម

តាមនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ (Standard Operating Procedures - SOPs - for All Externally Financed Projects/ Programs) ជាធរមាន។ ជាមួយនេះ, ត្រូវពង្រឹង និងពង្រីកយន្តការតាមដាន និងត្រួតពិនិត្យជាប្រចាំ ក្នុងដំណាក់កាលនៃការអនុវត្តគម្រោង ដើម្បីធានាការបិទបញ្ចប់គម្រោងតាមពេលកំណត់។ ការពន្យារពេលអនុវត្តគម្រោង អាចត្រូវបានអនុញ្ញាត មិនលើសពី ៣ឆ្នាំ និងត្រូវមានមូលហេតុសមស្រប។ ក្នុងករណីចាំបាច់បំផុត ដែលតម្រូវឱ្យពន្យារពេលអនុវត្តគម្រោងលើសពី ៣ឆ្នាំ, ក្រសួង ស្ថាប័ន តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវគោរពរាយការណ៍ជូននាយករដ្ឋមន្ត្រី។

បន្ថែមលើនេះ, ដើម្បីធានាបាននូវការអនុវត្តគម្រោងប្រកបដោយប្រសិទ្ធភាព, ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបន្តអនុវត្តគោលការណ៍ភាពរួចរាល់សម្រាប់ការចាប់ផ្តើមអនុវត្តគម្រោង (Project Readiness Filters) ដែលក្នុងនោះ ត្រូវមានការវាយតម្លៃសមត្ថភាពរបស់អង្គភាពគ្រប់គ្រងគម្រោង ក្នុងដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាពគម្រោង និងការរៀបចំផែនការបណ្តុះបណ្តាល ក្នុងករណីមានតម្រូវការ។ មិនតែប៉ុណ្ណោះ, ក្រសួង ស្ថាប័នត្រូវរៀបចំ និងបង្កើតអង្គភាពគ្រប់គ្រងនិងអនុវត្តគម្រោង ដែលសមាសភាពនៃអង្គភាពនេះ ត្រូវជ្រើសរើសដោយឈរលើគោលការណ៍គុណវុឌ្ឍិ ស្របតាមនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ។

**៦.១០. បន្តពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស** ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តផែនការសកម្មភាពដែលបានដាក់ចេញនៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨ ដែលជាឧបសម្ព័ន្ធទី៣ នៃយុទ្ធសាស្ត្រនេះ សំដៅរួមចំណែកបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលមធ្យម-វែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប ព្រមទាំងធានានូវការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងអនុវត្តគម្រោងវិនិយោគសាធារណៈ។ ទន្ទឹមនេះ, ត្រូវគិតគូរពិចារណាប្រើប្រាស់ធនធានមនុស្សក្នុងស្រុកជំនួសឱ្យជំនាញការបរទេស សំដៅលើកកម្ពស់ភាពជាម្ចាស់ និងសម្រាលបន្ទុកចំណាយនៃគម្រោងវិនិយោគសាធារណៈ។

ដើម្បីគាំទ្រការអនុវត្តវិធានការជាយុទ្ធសាស្ត្រទាំងអស់ខាងលើ ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, និងគណនេយ្យភាព, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឋានៈជាសេនាធិការរបស់រាជរដ្ឋាភិបាល ត្រូវទទួលបន្ទុកជាស្ថាប័ននាំមុខ ក្នុងការសម្របសម្រួលលើការអនុវត្តផែនការសកម្មភាព ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី២។

# ជំពូកទី៧
# យន្តការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈម

# ជំពូកទី៧
# យន្តការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈម

ដើម្បីធានាបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្ត «**យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨**», រាជរដ្ឋាភិបាលសម្រេចដាក់ចេញយន្តការតាមដាន, ត្រួតពិនិត្យ, វាយតម្លៃ, និងដោះស្រាយបញ្ហាប្រឈម ដូចខាងក្រោម៖

## ៧.១. យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាលេខាធិការដ្ឋាន នៃគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ មានភារកិច្ចតាមដាន, ត្រួតពិនិត្យ, និងវាយតម្លៃការអនុវត្តវិធានការជាយុទ្ធសាស្ត្រ និងផែនការសកម្មភាព ព្រមទាំងរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស ប្រចាំឆ្នាំ និងពាក់កណ្តាលអាណត្តិ (Midterm Review) ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី២ នៃយុទ្ធសាស្ត្រនេះ។ ក្នុងន័យនេះ, អង្គភាពពាក់ព័ន្ធ ត្រូវសហការផ្តល់ព័ត៌មាន និងទិន្នន័យ មកលេខាធិការដ្ឋាន ដើម្បីបូកសរុប និងរាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ (គ.គ.ប.)។

**ដ្យាក្រាមទី១៖ យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**




## ៧.២. យន្តការដោះស្រាយបញ្ហាប្រឈម

ក្នុងករណីមានបញ្ហាប្រឈមដែលអាចកើតឡើងជាយថាហេតុ ក្នុងពេលអនុវត្តវិធានការជាយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី២ នៃយុទ្ធសាស្ត្រនេះ, លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ត្រូវស្នើវិធានការដោះស្រាយ ដើម្បីសុំគោលការណ៍សម្រេចពីរដ្ឋមន្ត្រី ក.ស.ហ.វ. ឬ គ.គ.ប.។ ក្នុងករណីមានវេទយិតភាពខ្ពស់, ត្រូវស្នើសុំគោលការណ៍សម្រេចដ៏ខ្ពង់ខ្ពស់ពីនាយករដ្ឋមន្ត្រី។

**ដ្យាក្រាមទី២៖ យន្តការដោះស្រាយបញ្ហាប្រឈម**



# ជំពូកទី៨
# សេចក្តីសន្និដ្ឋាន

# ជំពូកទី៨
# សេចក្តីសន្និដ្ឋាន

ការអនុម័ត និងដាក់ឱ្យអនុវត្ត «**យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨**» នាពេលនេះ ពិតជាមានសារៈសំខាន់ និងចាំបាច់ ក្នុងការឆ្លើយតបទៅនឹងការវិវត្តថ្មីៗនៅក្នុងការគ្រប់គ្រងបំណុលសាធារណៈកម្ពុជា និងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិនៅក្នុងដំណាក់កាលថ្មី ជាពិសេស ការធានាបាននូវចីរភាពសេដ្ឋកិច្ច, សង្គម, បរិស្ថាន, និងភាពធន់នឹងបម្រែបម្រួលអាកាសធាតុ។

រាជរដ្ឋាភិបាលមានជំនឿយ៉ាងមុតមាំថា យុទ្ធសាស្ត្រនេះ នឹងត្រូវបានប្រើប្រាស់ជាផែនទីបង្ហាញផ្លូវសម្រាប់បន្តពង្រឹងប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ និងជាឧបករណ៍គាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ សំដៅរួមចំណែកក្នុងការបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះរឹងមាំ ក្នុងការរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន ឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

យុទ្ធសាស្ត្រនេះ គឺជា «**ឯកសាររស់**» ដែលអាចនឹងត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់ ដើម្បីធានាបាននូវសង្គតិភាព និងភាពប្រទាក់ក្រឡាជាមួយនឹងគោលនយោបាយ និងយុទ្ធសាស្ត្រគន្លឹះៗរបស់រាជរដ្ឋាភិបាល ក៏ដូចជាការវិវឌ្ឍនៃបរិការណ៍ជាក់ស្តែងទាំងក្នុង និងក្រៅប្រទេស ព្រមទាំងការវិវត្តឆាប់រហ័សនៃនិម្មាបនកម្មសកល។

ក្នុងន័យនេះ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចសម្របសម្រួល និងតាមដានការអនុវត្ត «**យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨**» ដោយត្រូវមានការចូលរួមផ្តល់កិច្ចសហប្រតិបត្តិការពេញលេញ និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធ របស់រាជរដ្ឋាភិបាល ដើម្បីទទួលបានជោគជ័យជាអតិបរមា ប្រកបដោយប្រសិទ្ធភាពខ្ពស់៕

# សន្ធានុក្រម

# សទ្ទានុក្រម

| ល.រ. | ភាសាអង់គ្លេស | ភាសាខ្មែរ | និយមន័យ |
|---|---|---|---|
| ១ | Borrowing | ការខ្ចីប្រាក់ពីគេ | សំដៅដល់ការកៀរគរធនធានហិរញ្ញប្បទាន តាមរយៈការបោះផ្សាយលក់មូលបត្ររដ្ឋ និងការខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុ ពីដៃគូអភិវឌ្ឍ និងពីនីតិបុគ្គលផ្សេងទៀតស្របតាមបទប្បញ្ញត្តិជាធរមាន។[9] |
| ២ | Contingent Liabilities | កាតព្វកិច្ចបំណុលជាយថាហេតុ | សំដៅដល់កាតព្វកិច្ចហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ក្នុងការទូទាត់សំណង ប្រសិនបើមានព្រឹត្តិការណ៍ជាក់លាក់ណាមួយកើតឡើងនាពេលអនាគត ដូចជា ការធានា ការរ៉ាប់រង ការទូទាត់សំណងអន្តរាយ ការបង់វិភាគទានដើម្បីធានាសមាជិកភាពកម្ពុជាក្នុងអង្គការអន្តរជាតិនានា និងការផ្តល់សំណងតាមបណ្តឹងនីត្យានុកូល។ |
| ៣ | Commercial Loan | ឥណទានពាណិជ្ជកម្ម | សំដៅដល់ឥណទានដែលហិរញ្ញប្បទានដោយធនាគារពាណិជ្ជ ឬស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត តាមលក្ខខណ្ឌឥណទានទីផ្សារ។ |
| ៤ | Concessional Loan | ឥណទានសម្បទាន | សំដៅដល់ឥណទាន ដែលមានលក្ខខណ្ឌអនុគ្រោះខ្ពស់ជាងលក្ខខណ្ឌឥណទានទីផ្សារឬលក្ខខណ្ឌឥណទានពាណិជ្ជកម្ម។ |
| ៥ | Debt Stock | សន្និធិបំណុល | សំដៅដល់ទំហំបំណុលជាក់ស្តែង ដែលឥណាយិកមិនទាន់ទូទាត់ជូនឥណទាយក។ ជាទូទៅ, សន្និធិបំណុល ស្មើនឹងការបោះផ្សាយលក់មូលបត្ររដ្ឋ បូកនឹងការដកសាច់ប្រាក់សរុប ដកឱ្យ៖ ការបង្វែរសាច់ប្រាក់ទៅឥណទាយក និងការទូទាត់ប្រាក់ដើមសរុប។ ជាករណីពិសេស សម្រាប់កម្ពុជា សន្និធិបំណុលសាធារណៈក្រៅប្រទេស ស្មើនឹង៖ ការដកសាច់ប្រាក់សរុប ដកឱ្យ ការបង្វែរសាច់ប្រាក់ទៅដៃគូអភិវឌ្ឍវិញ, ការទូទាត់ប្រាក់ដើមសរុប, និងបំណុលដែលបានលុបដោយដៃគូអភិវឌ្ឍ បូកនឹងបំណុលមរតកដែលបានចរចាដោះស្រាយរួច ហើយកំពុងសង និងបំណុលមរតកដែលកំពុងចរចាដោះស្រាយ។ |
| ៦ | Debt Service | សេវាបំណុល | សំដៅដល់ការទូទាត់ប្រាក់ដើម ការប្រាក់ និងកម្រៃពាក់ព័ន្ធផ្សេងទៀតនៃកាតព្វកិច្ចបំណុល។ |
| ៧ | Fixed Rate Debt | បំណុលជាប្រភេទអត្រាការប្រាក់ថេរ | សំដៅដល់បំណុលដែលមានអត្រាការប្រាក់មិនប្រែប្រួលឡើង ឬ ចុះតាមស្ថានភាពសេដ្ឋកិច្ច ឬ ទីផ្សារហិរញ្ញវត្ថុ។ |

[9] យោងតាមសទ្ទានុក្រមនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

| | | | |
|---|---|---|---|
| ៨ | Floating Rate Debt | បំណុលជាប្រភេទអត្រាការប្រាក់ប្រែប្រួល | សំដៅដល់បំណុលដែលមានអត្រាការប្រាក់ប្រែប្រួលឡើង ឬ ចុះ តាមស្ថានភាពសេដ្ឋកិច្ច ឬ ទីផ្សារហិរញ្ញវត្ថុ។ |
| ៩ | Government Securities | មូលបត្ររដ្ឋ | សំដៅដល់បណ្ណ សញ្ញាបណ្ណ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត ដែលបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល នៅក្រោមច្បាប់ស្ដីពីមូលបត្ររដ្ឋ រួមមាន៖<br>ក- បណ្ណរតនាគារដែលមានឥណទានប្រតិទានតិចជាងមួយឆ្នាំ។<br>ខ- សញ្ញាបណ្ណរតនាគារដែលមានឥណប្រតិទាន ចាប់ពីមួយឆ្នាំឡើងទៅ។<br>គ- មូលបត្ររដ្ឋផ្សេងៗដទៃទៀត។<br>មូលបត្ររដ្ឋទាំងអស់ខាងលើនេះ មិនរួមបញ្ចូលលនូវមូលបត្រដែលបោះផ្សាយដោយសហគ្រាសសាធារណៈ ឬការសុំខ្ចីផ្សេងៗរបស់រាជរដ្ឋាភិបាល ដែលមិនស្ថិតក្រោមវិសាលភាពនៃច្បាប់ស្ដីពីមូលបត្ររដ្ឋទេ។[២] |
| ១០ | Lending and On-lending | ការឱ្យប្រាក់គេខ្ចី | សំដៅដល់ការផ្ដល់ប្រាក់ឱ្យគេខ្ចីដោយប្រើថវិការដ្ឋ និង/ឬដោយប្រើហិរញ្ញប្បទានដែលរដ្ឋខ្ចីប្រាក់ពីគេ ស្របតាមបទប្បញ្ញត្តិជាធរមាន។[៣] |
| ១១ | Grace Period | រយៈពេលអនុគ្រោះ | សំដៅដល់រយៈពេលចន្លោះពីពេលដែលកិច្ចព្រមព្រៀងឥណទាន ឬ កិច្ចព្រមព្រៀងការផ្ដល់ឥណទានចូលជាធរមាន រហូតដល់ពេលត្រូវសងប្រាក់ដើមដំបូង ដោយក្នុងរយៈពេលនោះ មានតែការប្រាក់ និងកម្រៃផ្សេងៗប៉ុណ្ណោះ ដែលត្រូវទូទាត់។ |
| ១២ | Grant | ហិរញ្ញប្បទានឥតសំណង | សំដៅដល់ហិរញ្ញប្បទានក្រោមទម្រង់នានា ដូចជា៖ សាច់ប្រាក់, ទំនិញ, ឬ សេវា ដែលមិននាំឱ្យកើតមានបន្ទុកសេវាបំណុល។ |
| ១៣ | Grant Element | ធាតុអំណោយ | សំដៅដល់ផលធៀបរវាង៖ ១) ផលដកនៃតម្លៃចារឹករបស់ឥណទាន និងតម្លៃបច្ចុប្បន្ននៃការទូទាត់សេវាបំណុល, និង ២) តម្លៃចារឹករបស់ឥណទាន។ ធាតុអំណោយ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការវាស់ស្ទង់កម្រិតសម្បទាននៃឥណទាន។ |
| ១៤ | Guarantee | ការធានា | សំដៅដល់កាតព្វកិច្ចទូទាត់សេវាបំណុលរបស់សហគ្រាសសាធារណៈ សហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលរាជរដ្ឋាភិបាលបានធានាសងជំនួសនូវប្រាក់ ឬប្រាក់ដើម ឬទាំងការប្រាក់និងប្រាក់ដើម ព្រមទាំងកម្រៃពាក់ព័ន្ធផ្សេងទៀត ក្នុងករណីដែលសហគ្រាសសាធារណៈ សហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនោះ ពុំមានលទ្ធភាពបំពេញកាតព្វកិច្ចទូទាត់សេវាបំណុល។ |

[២] យោងតាមសទ្ទានុក្រមនៃគោលនយោបាយស្ដីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨

[៣] យោងតាមសទ្ទានុក្រមនៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

| | | | |
|---|---|---|---|
| ១៥ | International Bond | មូលបត្ររដ្ឋនៅក្រៅប្រទេស | សំដៅដល់សញ្ញាបណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល នៅលើទីផ្សារអន្តរជាតិ។ |
| ១៦ | Maturity | ឥណប្រតិទាន | សំដៅដល់រយៈពេលខ្ចី ដោយគិតចាប់ពីពេលដែលកិច្ចព្រមព្រៀងឥណទានចូលជាធរមាន រហូតដល់បំណុលត្រូវបានសងអស់។ ឥណប្រតិទាន ស្មើនឹងរយៈពេលអនុគ្រោះ បូកនឹងរយៈពេលសងដើម។ |
| ១៧ | Old Debt | បំណុលមរតក | សំដៅដល់បំណុលដែលបន្សល់ទុកដោយរដ្ឋាភិបាលជំនាន់មុន។ ក្នុងបរិការណ៍កម្ពុជា បំណុលមរតក គឺជាបំណុលដែលបានកើតឡើងមុនឆ្នាំ១៩៩៣។ ភាគច្រើននៃបំណុលទាំងនេះ ត្រូវបានចរចាដោះស្រាយជាមួយដៃគូរួចរាល់ហើយ ក្នុងនោះ មួយចំនួនត្រូវបានទូទាត់សងរួចរាល់ជាស្ថាពរ និងមួយចំនួនកំពុងត្រូវបានទូទាត់តាមកម្មវិធីសងក្នុងកិច្ចព្រមព្រៀង។ ដោយឡែក ចំពោះបំណុលមរតកដែលនៅសេសសល់ បច្ចុប្បន្ន, រាជរដ្ឋាភិបាលបាននិងកំពុងខិតខំបន្តចរចាដោះស្រាយជាមួយដៃគូឱ្យបានជ្រះស្រឡះ។ |
| ១៨ | Present Value of Debt | តម្លៃបច្ចុប្បន្ននៃបំណុល | សំដៅដល់ទំហំសន្និធិបំណុល ក្រោយដកតម្លៃអប្បហារ (កម្ពុជាប្រើប្រាស់អត្រាអប្បហាររួម ៥ ភាគរយ តាមបទដ្ឋានបច្ចេកទេសរបស់ IMF)។ តាមបទដ្ឋានបច្ចេកទេសអន្តរជាតិ ក្នុងការគណនាអនុបាតបំណុល សម្រាប់ក្រុមប្រទេសដែលនៅទទួលបានឥណទានសម្បទាន គេមិនប្រើតម្លៃចារឹកនៃបំណុលទេ គឺគេប្រើតម្លៃបច្ចុប្បន្ននៃបំណុល។ ចំពោះកម្ពុជាក៏ដូចគ្នាដែរ គឺត្រូវប្រើតម្លៃបច្ចុប្បន្ននៃបំណុល ព្រោះថាឥណទានដែលរដ្ឋខ្ចីពីក្រៅប្រទេសទាំងអស់ សុទ្ធសឹងជាឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់។ |
| ១៩ | Public Debt | បំណុលសាធារណៈ | សំដៅដល់បំណុលរបស់រដ្ឋ ដែលកើតឡើងស្របតាមច្បាប់អនុញ្ញាត និងដោយមិនរួមបញ្ចូលបំណុលដែលពុំមានការធានាពីរាជរដ្ឋាភិបាល។ |
| ២០ | Public Domestic Debt | បំណុលសាធារណៈក្នុងប្រទេស | សំដៅដល់បំណុលក្នុងប្រទេសរបស់រដ្ឋ ដែលកើតឡើងស្របតាមច្បាប់អនុញ្ញាត ដោយគិតបញ្ចូលនូវបំណុលដែលមានការធានាពីរដ្ឋ។ |
| ២១ | Public External Debt | បំណុលសាធារណៈក្រៅប្រទេស | សំដៅដល់បំណុលក្រៅប្រទេសរបស់រដ្ឋ ដែលកើតឡើងស្របតាមច្បាប់អនុញ្ញាត ដោយគិតបញ្ចូលទាំងបំណុលដែលមានការធានាពីរដ្ឋ។ ក្នុងបរិការណ៍កម្ពុជាបច្ចុប្បន្នបំណុលនេះមានតែការខ្ចីឥណទានសម្បទានពីដៃគូអភិវឌ្ឍទ្វេភាគី និងពហុភាគីក្រៅប្រទេសប៉ុណ្ណោះ។ ទោះជាយ៉ាងណាក្តី ទៅថ្ងៃមុខ បំណុលនេះ អាចនឹងរួមបញ្ចូលផងដែរនូវឧបករណ៍បំណុលផ្សេងទៀត ដូចជា មូលបត្ររដ្ឋនៅក្រៅប្រទេសជាដើម ក្នុងករណីរាជរដ្ឋាភិបាលសម្រេចធ្វើការបោះផ្សាយ។ |

| | | | |
|---|---|---|---|
| ២២ | Solicited Sovereign Credit Rating | ការវាយតម្លៃចំណាត់ថ្នាក់ឥណទានរបស់ប្រទេសផ្លូវការ | សំដៅដល់ការវាយតម្លៃ ដែលធ្វើឡើងដោយក្រុមហ៊ុនវាយតម្លៃចំណាត់ថ្នាក់ឥណទាន ដោយមានការស្នើសុំពីប្រទេសបោះផ្សាយ ហើយត្រូវបង់កម្រៃសេវា និងផ្តល់ទិន្នន័យផ្លូវការ។ |
| ២៣ | Thematic Bond | សញ្ញាបណ្ណរដ្ឋតាមវិស័យ | សំដៅដល់សញ្ញាបណ្ណរដ្ឋ ដែលត្រូវបានបោះផ្សាយដើម្បីកៀរគរទុនសម្រាប់អនុវត្តគម្រោងអភិវឌ្ឍ ដែលមានគោលដៅជាក់លាក់ជាពិសេស ឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDGs)។ |
| ២៤ | Unsolicited Sovereign Credit Rating | ការវាយតម្លៃចំណាត់ថ្នាក់ឥណទានរបស់ប្រទេសមិនផ្លូវការ | សំដៅដល់ការវាយតម្លៃ ដែលធ្វើឡើងដោយក្រុមហ៊ុនវាយតម្លៃចំណាត់ថ្នាក់ឥណទាន ដោយពុំមានការស្នើសុំពីប្រទេសបោះផ្សាយ។ |

ឧបសម្ព័ន្ធទី២

# ផែនការសកម្មភាព

# ផែនការសកម្មភាព
# សម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨

| ល.រ. | ចង្កោមសកម្មភាព/សកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | អង្គភាពទទួលបន្ទុក | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|---|---|
| ១ | **រៀបចំលិខិតបទដ្ឋានគតិយុត្ត** | | | | | | | |
| ១.១ | រៀបចំដំឡើងអនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ឱ្យទៅជាច្បាប់ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ | ច្បាប់ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ត្រូវបានរៀបចំ អនុម័ត និងដាក់ឱ្យអនុវត្ត | ក.ស.ហ.វ (អ.ស.ប.) | X | X | X | X | |
| ១.២ | រៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ ដែលគ្របដណ្តប់នូវគ្រប់ហានិភ័យបំណុលពាក់ព័ន្ធទាំងអស់ ដោយរួមទាំងហានិភ័យនៃកាតព្វកិច្ចបំណុលដាយថាហេតុ ដែលអាចកើតចេញពីការធានាទូទាត់របស់រដ្ឋ | គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហានិភ័យបំណុលសាធារណៈ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តដោយប្រកាស | ក.ស.ហ.វ (អ.ស.ប.) | | X | | | |
| ១.៣ | ធ្វើបច្ចុប្បន្នកម្មនីតិវិធីរួមសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ | បច្ចុប្បន្នកម្មនីតិវិធីរួមសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តដោយប្រកាស | ក.ស.ហ.វ (អ.ស.ប.) | | | | X | |
| ១.៤ | ពិនិត្យ និងធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់នូវនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោង/កម្មវិធីហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ | បច្ចុប្បន្នកម្មនីតិវិធីរួមសម្រាប់អនុវត្តគម្រោង/កម្មវិធីហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តដោយអនុក្រឹត្យ | ក.ស.ហ.វ (អ.ស.ប.) | | | X | | |

| ល.រ. | ចង្កោមសកម្មភាព/សកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | អង្គភាព ទទួលបន្ទុក | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|---|---|
| ២ | វិភាគ និងគ្រប់គ្រងហានិភ័យ | | | | | | | |
| ២.១ | វិភាគ និងរៀបចំផែនការខ្ចីប្រាក់ពីគេប្រចាំឆ្នាំ (Annual Borrowing Plan) | ផែនការខ្ចីប្រាក់ពីគេប្រចាំឆ្នាំ ត្រូវបានរៀបចំ | ក.ស.ហ.វ (អ.ស.ប.) | | X | X | X | X |
| ២.២ | វិភាគចីរភាពបំណុល(Debt Sustainability Analysis) | លទ្ធផលនៃការវិភាគចីរភាពបំណុល ត្រូវបានរំលេចក្នុងព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា និងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត «យុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨» | ក.ស.ហ.វ (អ.ស.ប.) | X | X | X | X | X |
| ២.៣ | វិភាគថ្លៃ និងហានិភ័យបំណុល (Debt Portfolio Analysis) | លទ្ធផលនៃការវិភាគថ្លៃ និងហានិភ័យបំណុល ត្រូវបានរំលេចក្នុងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត «យុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨» | ក.ស.ហ.វ (អ.ស.ប.) | X | X | X | X | X |
| ២.៤ | ពិនិត្យ និងធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់នូវ៖ ១)ពិតាននៃការខ្ចីប្រាក់ពីគេ, ២)ពិតានធានាទូទាត់របស់រដ្ឋ និង ៣)ពិតានសូចនាករបំណុល ដើម្បីធានាបាននូវសង្គតិភាពជាមួយក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម | ពិតាននៃការខ្ចីប្រាក់ពីគេ, ការធានាទូទាត់របស់រដ្ឋ និង ពិតានសូចនាករបំណុលគន្លឹះ ត្រូវបានពិនិត្យ និងធ្វើបច្ចុប្បន្នកម្ម | ក.ស.ហ.វ (អ.ស.ប.) | X | X | X | X | X |
| ២.៥ | រៀបចំ «ក្របខ័ណ្ឌគោលនយោបាយហិរញ្ញប្បទានជាតិ» សម្រាប់ជាត្រីវិស័យតម្រង់ទិសការកៀរគរហិរញ្ញប្បទាន និងវិនិយោគ សម្រាប់គាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា | ក្របខ័ណ្ឌគោលនយោបាយហិរញ្ញប្បទានជាតិ ត្រូវបានរៀបចំ | ក.ស.ហ.វ (អ.ស.ប.) | X | X | | | |

| ល.រ. | ចង្កោមសកម្មភាព/សកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | អង្គភាពទទួលបន្ទុក | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|---|---|
| ២.៦ | សិក្សារៀបចំឯកសារទស្សនាទានស្តីពី «ផែនការអន្តរកាល (Transition Plan)» ដើម្បីកៀរគរហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានកម្រិតសម្បទានឬលក្ខខណ្ឌអនុគ្រោះខ្ពស់ សម្រាប់បំពេញតម្រូវការវិនិយោគសាធារណៈដែលបន្សាំនឹងការប្រែប្រួលអាកាសធាតុ (Climate Adaptation) | ឯកសារទស្សនាទានស្តីពីការរៀបចំ «ផែនការអន្តរកាល» ត្រូវបានរៀបចំ | ក.ស.ហ.វ (អ.ស.ប.) | | X | X | | |
| ២.៧ | បង្កើតយន្តការអន្តរក្រសួង ស្ថាប័ន សម្រាប់រៀបចំ «ក្របខ័ណ្ឌគោលនយោបាយស្តីពីការពង្រឹងចំណាត់ថ្នាក់ឥណទានរបស់ប្រទេស» | យន្តការអន្តរក្រសួង ស្ថាប័ន សម្រាប់រៀបចំ «ក្របខ័ណ្ឌគោលនយោបាយស្តីពីការពង្រឹងចំណាត់ថ្នាក់ឥណទានរបស់ប្រទេស» ត្រូវបានបង្កើត | ក.ស.ហ.វ (អ.ស.ប.) | | | X | | |
| ២.៨ | សិក្សារៀបចំឯកសារទស្សនាទានស្តីពី «ក្របខ័ណ្ឌគោលនយោបាយស្តីពីការពង្រឹងចំណាត់ថ្នាក់ឥណទានរបស់ប្រទេស» ដើម្បីកំណត់ឱ្យបានជាក់លាក់នូវចក្ខុវិស័យ, បង្គោលចរ, វិធានការជាយុទ្ធសាស្ត្រ, និងផែនការសកម្មភាពសំដៅបង្កើនចំណាត់ថ្នាក់ឥណទានរបស់កម្ពុជា (Sovereign Credit Rating) ឱ្យឈានដល់កម្រិតខ្ពស់បំផុត (AAA) ត្រឹមឆ្នាំ២០៥០ | ឯកសារទស្សនាទានស្តីពីការរៀបចំ «ក្របខ័ណ្ឌគោលនយោបាយស្តីពីការពង្រឹងចំណាត់ថ្នាក់ឥណទានរបស់ប្រទេស» ត្រូវបានរៀបចំ | ក.ស.ហ.វ (អ.ស.ប.) | | X | X | | |
| ២.៩ | បន្តសិក្សា និងតាមដានលើស្ថានភាព និងនិន្នាការនៃបំណុលរបស់វិស័យឯកជន និងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលអាចកើតចេញពីវិស័យធនាគារ និងហិរញ្ញវត្ថុ | របាយការណ៍ស្ថានភាព និងនិន្នាការនៃបំណុលរបស់វិស័យឯកជន និងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលអាចកើតចេញពីវិស័យធនាគារ និងហិរញ្ញវត្ថុ ត្រូវបានរៀបចំ | ធ.ជ.ក ក.ស.ហ.វ (អ.ស.ប.) | X | X | X | X | X |

| ល.រ. | ចង្កោមសកម្មភាព/សកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | អង្គភាពទទួលបន្ទុក | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|---|---|
| ៣ | **បន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងការឱ្យប្រាក់គេខ្ចី** | | | | | | | |
| ៣.១ | សិក្សារៀបចំគោលការណ៍ណែនាំសម្រាប់តាមដាន និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុរបស់ឥណាយិកដែលទទួលបានឥណទានពីរដ្ឋ | គោលការណ៍ណែនាំសម្រាប់តាមដាន និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុរបស់ឥណាយិកដែលទទួលបានឥណទានពីរដ្ឋ ត្រូវបានសិក្សារៀបចំ | ក.ស.ហ.វ (អ.ស.ប.) | | X | X | | |
| ៣.២ | ពិនិត្យ និងធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់នូវបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងការឱ្យប្រាក់គេខ្ចី | បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងការឱ្យប្រាក់គេខ្ចី ត្រូវបានពិនិត្យ និងធ្វើបច្ចុប្បន្នកម្ម | ក.ស.ហ.វ (អ.ស.ប.) | | | | X | |
| ៤ | **បន្តពង្រឹងការអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រងបំណុលសាធារណៈ** | | | | | | | |
| ៤.១ | រៀបចំសិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤-២០២៨ | សិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨ ត្រូវបានរៀបចំ | ក.ស.ហ.វ (អ.ស.ប.) | X | | | | |
| ៤.២ | បន្តរៀបចំ និងបោះផ្សាយព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា ប្រចាំត្រីមាស | ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា ត្រូវបានរៀបចំ និងបោះផ្សាយ ជារៀងរាល់ត្រីមាស | ក.ស.ហ.វ (អ.ស.ប.) | X | X | X | X | X |
| ៤.៣ | រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស នៃការអនុវត្ត «យុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨» | របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស នៃការអនុវត្ត «យុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨» ត្រូវបានរៀបចំ | ក.ស.ហ.វ (អ.ស.ប.) | X | X | X | X | X |
| ៤.៤ | ត្រួតពិនិត្យពាក់កណ្ដាលអាណត្តិ (Midterm Review) នូវការអនុវត្តយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨ | របាយការណ៍លទ្ធផលត្រួតពិនិត្យពាក់កណ្ដាលអាណត្តិនៃការអនុវត្តយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨ ត្រូវបានរៀបចំ | ក.ស.ហ.វ (អ.ស.ប.) | | | X | | |

| ល.រ. | ចង្កោមសកម្មភាព/សកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | អង្គភាពទទួលបន្ទុក | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|---|---|
| ៤.៥ | វាយតម្លៃការគ្រប់គ្រងបំណុលសាធារណៈ (DeMPA) ដើម្បីជាមូលដ្ឋានបន្តកែលម្អប្រព័ន្ធគ្រប់គ្រងបំណុលសាធារណៈ | របាយការណ៍វាយតម្លៃការគ្រប់គ្រងបំណុលសាធារណៈត្រូវបានរៀបចំ | ក.ស.ហ.វ (អ.ស.ប.) | | | | | X |
| ៥ | **បន្តពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស** | | | | | | | |
| ៥.១ | អនុវត្ត«ផែនការសកម្មភាពដែលបានដាក់ចេញនៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ២០២៤ - ២០២៨» | របាយការណ៍វឌ្ឍនភាពស្ដីពីការអនុវត្ត «ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ» ត្រូវបានរៀបចំ | ក.ស.ហ.វ (អ.ស.ប.) | X | X | X | X | X |
| សរុប | | | | ១០ | ១៥ | ១៤ | ១២ | ៩ |

***បញ្ចប់ត្រឹម ៥ ចង្កោមសកម្មភាព ស្មើនឹង ២១ សកម្មភាព។***

** ផែនការសកម្មភាពនេះ អាចនឹងត្រូវបានពិនិត្យ និងកែសម្រួល តាមការចាំបាច់។*

**<u>កំណត់សម្គាល់ ៖</u>**

- ក.ស.ហ.វ.៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អ.ស.ប.៖ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល
- ធ.ជ.ក.៖ ធនាគារជាតិ នៃកម្ពុជា

ឧបសម្ព័ន្ធទី៣

# ផែនការអភិវឌ្ឍន៍
# សមត្ថភាពស្ថាប័ន និង
# ធនធានមនុស្ស
# ២០២៤ - ២០២៨

# មាតិកា

**ជំពូកទី១៖ សេចក្តីផ្តើម** ........ ១

**ជំពូកទី២៖ គោលបំណង, គោលដៅ, និងវិសាលភាព**

២.១. គោលបំណង និងគោលដៅ ........ ២

២.២. វិសាលភាព ........ ២

**ជំពូកទី៣៖ ការវិភាគចំណុចខ្លាំង, ចំណុចខ្សោយ, កាលានុវត្តភាព, និងការគំរាមកំហែង**

៣.១. ចំណុចខ្លាំង ........ ៣

៣.២. ចំណុចខ្សោយ ........ ៣

៣.៣. កាលានុវត្តភាព ........ ៤

៣.៤. ការគំរាមកំហែង ........ ៤

**ជំពូកទី៤៖ ផែនការសកម្មភាពក្នុងការបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ២០២៤ - ២០២៨**

៤.១. ផែនការសកម្មភាពក្នុងការបន្តពង្រឹងសមត្ថភាពស្ថាប័ន ........ ៦

៤.២. ផែនការសកម្មភាពក្នុងការបន្តពង្រឹងសមត្ថភាពធនធានមនុស្ស ........ ៦

**ជំពូកទី៥៖ គម្រោងប៉ាន់ស្មានថវិកាចំណាយ សម្រាប់ការបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ២០២៤ - ២០២៨** ........ ៩

# ជំពូកទី១
# សេចក្តីផ្តើម

ដោយយល់ច្បាស់ពីសារៈសំខាន់នៃកិច្ចការគ្រប់គ្រងបំណុលសាធារណៈ ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិកន្លងមក រាជរដ្ឋាភិបាលបានអនុម័ត និងដាក់ឱ្យអនុវត្តនូវផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ភ្ជាប់ជាឧបសម្ព័ន្ធ នៃយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ចំនួន ៣ លើក រួចមកហើយ។

រាជរដ្ឋាភិបាល ដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការ បានអនុវត្តដោយជោគជ័យនូវផែនការទាំង ៣ ដំណាក់កាលខាងលើ ហើយបានធ្វើឱ្យសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រងបំណុលសាធារណៈរបស់កម្ពុជា មានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ ព្រមទាំងទទួលបានការកោតសរសើរ និងវាយតម្លៃខ្ពស់ពីដៃគូអភិវឌ្ឍនានា និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ ដូចជា៖ មូលនិធិរូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក, ធនាគារអភិវឌ្ឍន៍អាស៊ី, អង្គការសន្និសីទសហប្រជាជាតិសម្រាប់ពាណិជ្ជកម្មនិងអភិវឌ្ឍន៍ (United Nations Conference on Trade and Development – UNCTAD), និងអង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (Organization for Economic Co-operation and Development – OECD) ជាដើម។

ជាក់ស្តែង, នៅក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងបំណុលសាធារណៈកម្ពុជាបច្ចុប្បន្ន យើងមានមុខងារសំខាន់ៗទាំង ៣ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ រួចហើយ រួមមាន៖ ១) ការិយាល័យជួរមុខ (Front Office), ២) ការិយាល័យជួរកណ្តាល (Middle Office), និង ៣) ការិយាល័យជួរក្រោយ (Back Office) ដែលស្ថិតក្រោមឆ័ត្ររួមនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទន្ទឹមនេះ, យើងក៏កសាងបាននូវធនធានមនុស្ស ដែលមានសមត្ថភាពធ្វើកិច្ចការសំខាន់ៗជាច្រើន ប្រកបដោយភាពជាម្ចាស់ ដូចជា៖ ១) ការកសាងបទដ្ឋានគតិយុត្ត; ២) ការរៀបចំឯកសារគោលនយោបាយ, យុទ្ធសាស្ត្រ, នីតិវិធី, និងទស្សនាទាន; ៣) ការផលិតរបាយការណ៍និងព្រឹត្តិបត្រស្ថិតិបំណុល; ៤) ការវិភាគចីរភាពបំណុល, ចង្កោមបំណុល, ជាតុអំណោយ, ហានិភ័យបំណុលពាក់ព័ន្ធ ដោយរួមទាំងកាតព្វកិច្ចបំណុលជាយថាហេតុ; និង ៥) កិច្ចការពាក់ព័ន្ធសំខាន់ជាច្រើនផ្សេងទៀត។ ទោះយ៉ាងនេះក្តី, ក្នុងបរិការណ៍នៃការប្រែប្រួលសង្គម-សេដ្ឋកិច្ចសាកលលោក ក៏ដូចជាការឆ្លើយតបនឹងដំណើរវិវត្តន៍ឈានជាលំដាប់នៃសង្គម-សេដ្ឋកិច្ចកម្ពុជា ក្នុងដំណើរឡើងឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០, កម្ពុជាក៏មានភាពចាំបាច់ត្រូវយកចិត្តទុកដាក់ខ្លាំងក្លាថែមទៀត ក្នុងការបន្តពង្រឹងសមត្ថភាពធនធានមនុស្ស ពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ផងដែរ ជាពិសេស លើការងារវិភាគស៊ីជម្រៅ។

ក្នុងន័យនេះ, រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវ «**ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស ២០២៤ - ២០២៨**» សម្រាប់ប្រើប្រាស់ជាត្រីវិស័យក្នុងការបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨ និងឈានទៅដល់ការរៀបចំយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៩ - ២០៣៣ នាឆ្នាំ២០២៨ សំដៅរួមចំណែកបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលមធ្យ-វែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប ព្រមទាំងជានានូវការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងអនុវត្តគម្រោងវិនិយោគសាធារណៈ។

ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស ២០២៤ - ២០២៨ ជាឧបករណ៍ដ៏មានសារៈសំខាន់ និងមិនអាចខ្វះបាន ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨ ហើយផែនការនេះ ជា «**ឯកសាររស់**» ដែលអាចនឹងត្រូវបានត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្ម តាមការចាំបាច់។

# ជំពូកទី២
# គោលបំណង, គោលដៅ, និងវិសាលភាព

## ២.១. គោលបំណង និងគោលដៅ

«**ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស ២០២៤ - ២០២៨**» មានគោលបំណងបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីធានាបាននូវតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធភាព ក្នុងការគ្រប់គ្រងបំណុលសាធារណៈ សំដៅរួមចំណែកបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលមធ្យម-វែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប ព្រមទាំងធានានូវការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងអនុវត្តគម្រោងវិនិយោគសាធារណៈ។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ, ផែនការនេះ មានគោលដៅដាក់ចេញនូវផែនការសកម្មភាពក្នុងការបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ។

## ២.២. វិសាលភាព

ផែនការនេះ មានវិសាលភាពគ្របដណ្តប់លើការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈរបស់កម្ពុជា។

# ជំពូកទី៣
# ការវិភាគចំណុចខ្លាំង, ចំណុចខ្សោយ, កាលានុវត្តភាព, និងការគំរាមកំហែង

ក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងបំណុលសាធារណៈបច្ចុប្បន្ន បើទោះជាមានកម្មវិធីកសាងសមត្ថភាពតាមអភិក្រមនានាជាច្រើនឆ្នាំកន្លងមកហើយក្តី ក៏កម្ពុជានៅតែមានភាពចាំបាច់ ក្នុងការបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សបន្ថែមទៀត សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តការងារ ពិសេស កិច្ចការដែលមានលក្ខណៈស្មុគស្មាញ ដូចជា៖ ការវិភាគចីរភាពបំណុល, ការវិភាគបង្គោមបំណុល, ការគ្រប់គ្រងនិងតាមដានហានិភ័យបំណុលពាក់ព័ន្ធ, ការកសាងបទដ្ឋានគតិយុត្ត និងការរៀបចំយុទ្ធសាស្ត្របំណុលសាធារណៈ ក្រោយៗទៀត ជាដើម។

ក្នុងស្មារតីនេះ, ដើម្បីជាមូលដ្ឋានឈានទៅដាក់ចេញនូវផែនការសកម្មភាពបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ឆ្នាំ២០២៤ - ២០២៨ ប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ និងប្រាកដនិយម និងស្របតាមឧត្តមានុវត្តជាអន្តរជាតិ, រាជរដ្ឋាភិបាលបានវិភាគលើចំណុចខ្លាំង, ចំណុចខ្សោយ, កាលានុវត្តភាព, និងការគំរាមកំហែង (SWOT Analysis) ដូចខាងក្រោម៖

## ៣.១. ចំណុចខ្លាំង

- រាជរដ្ឋាភិបាលមានរបៀបវារៈគោលនយោបាយច្បាស់លាស់ ក្នុងការកសាង និងអភិវឌ្ឍប្រទេស ជាពិសេសការអភិវឌ្ឍធនធានមនុស្ស ដែលជាអាទិភាពទី១ នៃយុទ្ធសាស្ត្រចតុកោណ តាំងពីដំណាក់កាលទី៣ និងទី៤ មកម្ល៉េះ ហើយនៅតែបន្តជាអាទិភាពទី១ នៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១។
- រាជរដ្ឋាភិបាលមានឆន្ទៈគោលនយោបាយខ្ពស់ ក្នុងការបន្តសកម្មភាពអនុវត្តនូវកម្មវិធីកែទម្រង់គន្លឹះៗទាំង ៤ រួមមាន៖ ១) កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២) កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ, ៣) កម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, និង ៤) កម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលក្នុងនោះក៏ផ្តោតសំខាន់លើការបន្តពង្រឹងគុណភាពស្ថាប័ន និងធនធានមនុស្សនៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ ផងដែរ។
- រចនាសម្ព័ន្ធស្ថាប័នបច្ចុប្បន្ននៃអង្គភាពគ្រប់គ្រងបំណុលសាធារណៈ មានភាពរឹងមាំ ដោយគ្របដណ្តប់នូវមុខងារសំខាន់ទាំង ៣ នៃការគ្រប់គ្រងបំណុលសាធារណៈ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ រួមមាន៖ ១) ការិយាល័យជួរមុខ (Front Office), ២) ការិយាល័យជួរកណ្តាល (Middle Office), និង ៣) ការិយាល័យជួរក្រោយ (Back Office)។
- សមត្ថភាពធនធានមនុស្សក្នុងកិច្ចការគ្រប់គ្រងបំណុលសាធារណៈ មានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ដោយមានភាពជាម្ចាស់ធ្វើកិច្ចការសំខាន់ៗជាច្រើនបាន ដូចជា៖ ការរៀបចំឯកសារបទដ្ឋានគតិយុត្ត, គោលនយោបាយ, និងយុទ្ធសាស្ត្រនានា, ព្រមទាំងការវិភាគ និងកិច្ចការពាក់ព័ន្ធជាច្រើនផ្សេងទៀត។
- មន្ត្រីពាក់ព័ន្ធភាគច្រើន មានទំនួលខុសត្រូវខ្ពស់ចំពោះតួនាទី និងភារកិច្ចរបស់ខ្លួន ព្រមទាំងមានឆន្ទៈមោះមុតក្នុងការអភិវឌ្ឍសមត្ថភាពជំនាញបន្ថែម។

## ៣.២. ចំណុចខ្សោយ

- មុខងារនៃការគ្រប់គ្រងកាតព្វកិច្ចបំណុលជាយថាហេតុ ដែលកើតចេញពីការធានា ពុំទាន់មានលក្ខណៈប្រមូលផ្តុំនៅឡើយ។
- ថ្វីត្បិតតែសមត្ថភាពធនធានមនុស្សពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រងបំណុលសាធារណៈមានភាពរីកចម្រើន

គួរឱ្យកត់សម្គាល់ក្តី ក៏ប៉ុន្តែ ទាំងចំនួន និងកម្រិតសមត្ថភាពមន្ត្រី ជាពិសេស លើការងារវិភាគស៊ីជម្រៅ និងការងារជំនាញពាក់ព័ន្ធមួយចំនួនទៀត នៅពុំទាន់អាចឆ្លើយតបបានតាមទំហំការងារជាក់ស្តែងនៅឡើយ។

- ភាគច្រើននៃមន្ត្រីថ្មី ដែលទើបត្រូវបានជ្រើសរើសឱ្យមកបំពេញការងារ មានតែចំណេះដឹងជំនាញទូទៅពោលគឺ ពុំធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលជំនាញពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈនៅឡើយ ទន្ទឹមនេះ ក៏នៅស្ទើរបទពិសោធន៍ការងារផងដែរ។

## ៣.៣. កាលានុវត្តភាព

- **ផ្នែកបច្ចេកទេស៖** កម្ពុជាមានជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ដូចជា៖ ធនាគារពិភពលោក (World Bank), មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF), ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដោយរួមទាំងលេខាធិការដ្ឋានអាស៊ាន (ASEAN Secretariat), កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP), មូលនិធិអភិវឌ្ឍន៍មូលធនរបស់អង្គការសហប្រជាជាតិ (UNCDF), កម្មវិធីភាពជាដៃគូកម្ពុជា - អូស្ត្រាលីសម្រាប់ការអភិវឌ្ឍ ប្រកបដោយភាពធន់ (CAPRED), វិទ្យាស្ថានកំណើនបៃតងសកល (GGGI), គណៈកម្មការសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ (UNESCAP), និងទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ជាដើម។ ជាការអនុវត្តកន្លងមក, ដៃគូអភិវឌ្ឍទាំងនោះផ្តល់ជំនាញការអន្តរជាតិ ឬអ្នកជំនាញបច្ចេកទេស ដើម្បី៖ ១) ជួយសិក្សា និងផ្តល់ធាតុចូលសម្រាប់ជាមូលដ្ឋានក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត, គោលនយោបាយ, និងកិច្ចការបច្ចេកទេសពាក់ព័ន្ធ, និង ២) ការបណ្តុះបណ្តាលធនធានមនុស្សតាមរយៈវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា ដើម្បីផ្តល់ចំណេះដឹងជំនាញ និងបទពិសោធន៍លើការងារគ្រប់គ្រងបំណុលសាធារណៈ និងការងារពាក់ព័ន្ធនានា។ នៅថ្ងៃខាងមុខ, ដៃគូអភិវឌ្ឍទាំងនេះក៏នៅតែបង្ហាញឆន្ទៈក្នុងការជួយគាំទ្រដល់កម្ពុជា ក្នុងការកសាងប្រព័ន្ធពេញលេញសម្រាប់ការគ្រប់គ្រងការបោះផ្សាយ និងការជួញដូរមូលបត្ររដ្ឋផងដែរ។
- **ផ្នែកហិរញ្ញវត្ថុ៖** រាជរដ្ឋាភិបាលអាចប្រើប្រាស់ជំនួយហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍ និងពីប្រភពផ្សេងទៀត សម្រាប់ហិរញ្ញប្បទានមន្ត្រីពាក់ព័ន្ធទៅចូលរួមសិក្ខាសាលា, វគ្គបណ្តុះបណ្តាល, ទស្សនកិច្ចសិក្សា, សន្និសីទ, វេទិកា ទាំងក្នុងស្រុក និងក្រៅប្រទេស និងសម្រាប់ផ្តល់ការលើកទឹកចិត្តដល់មន្ត្រីដែលមានសមត្ថភាព និងឆន្ទៈវិជ្ជាជីវៈខ្ពស់។
- **ផ្នែកបច្ចេកវិទ្យាឌីជីថល៖** ក្នុងបរិបទឌីជីថលនីយកម្ម និងបទពិសោធន៍នៃការរស់នៅក្នុងបរិបទជំងឺកូវីដ-១៩ កន្លងមក បាននិងកំពុងជំរុញឱ្យស្ថាប័ននានាអាចប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់អនុវត្តកិច្ចការរដ្ឋបាលធុរកិច្ច និងទំនាក់ទំនងការងារបានកាន់តែមានប្រសិទ្ធភាព។ កត្តានេះផ្តល់ជាបរិយាកាសអំណោយផលដល់កិច្ចទំនាក់ទំនងជាមួយអង្គភាពមានសមត្ថកិច្ចក្រៅប្រទេសក្នុងកិច្ចគ្រប់គ្រងបំណុលសាធារណៈធ្វើការចែករំលែកចំណេះដឹង និងបទពិសោធន៍, ការភ្ជាប់ខ្លួន និងទាញយកចំណេះដឹងពីស្ថាប័នជំនាញអន្តរជាតិ តាមរយៈការចូលរួមសិក្ខាសាលា, វគ្គបណ្តុះបណ្តាល, សន្និសីទ ព្រមទាំងវេទិកា តាមប្រព័ន្ធអនឡាញ និងការសិក្សាស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធឺណែត។

## ៣.៤. ការគំរាមកំហែង

- ភាពទាក់ទាញខ្លាំងនៃការងារនៅតាមវិស័យឯកជន និងអង្គការ ស្ថាប័ននានា ដែលអាចជាបញ្ហាប្រឈមដ៏ចម្បង ក្នុងការរក្សាទុក និងស្រូបយកនូវធនធានមនុស្សល្អៗ ឱ្យនៅបន្ត និងមកបម្រើការងារ។
- ការផ្លាស់ប្ដូរគោលនយោបាយជាយថាហេតុរបស់ដៃគូអភិវឌ្ឍ ក្នុងការផ្ដល់ជំនួយបច្ចេកទេសដល់កម្ពុជា ខណៈពេលដែលស្ថានភាពសេដ្ឋកិច្ចសាកលមានភាពមិនប្រកដប្រជា រួមនឹងវិបត្តិភូមិសាស្ត្រនយោបាយ ដែលបន្តធ្វើឱ្យមានបច្ច័យអវិជ្ជមានដល់ការកើនឡើងសម្ពាធអតិផរណា និងការកើនឡើងអត្រាការប្រាក់សាកល។
- ភាពវិវត្តឥតឈប់ឈរនៃបច្ចេកវិទ្យាព័ត៌មានវិទ្យា និងភាពកាន់តែស្មុគស្មាញនៃវិស័យហិរញ្ញវត្ថុ ដែលអាចនឹងពិបាកក្នុងការពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ឱ្យស្របទៅតាមការវិវត្តជាក់ស្ដែង។

# ជំពូកទី៤
# ផែនការសកម្មភាពក្នុងការបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ២០២៤ - ២០២៨

ក្នុងគោលបំណងបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីធានានូវតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធភាព ក្នុងការគ្រប់គ្រងបំណុលសាធារណៈ សំដៅរួមចំណែកបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលមធ្យម-វែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប ព្រមទាំងធានានូវការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងអនុវត្តគម្រោងវិនិយោគសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ត្រូវអនុវត្តនូវផែនការសកម្មភាព ដូចតទៅ៖

## ៤.១. ផែនការសកម្មភាពក្នុងការបន្តពង្រឹងសមត្ថភាពស្ថាប័ន

- បន្តជ្រើសរើសមន្ត្រី និងមន្ត្រីកិច្ចសន្យាថ្មី ដែលមានសមត្ថភាពនិងឆន្ទៈវិជ្ជាជីវៈខ្ពស់បន្ថែមទៀតប្រកបដោយតម្លាភាព និងភាពប្រកួតប្រជែង ឱ្យស្របតាមទំហំការងារជាក់ស្តែង។
- បន្តអនុវត្តវិធានការចាំបាច់នានាក្នុងការរក្សាទុកមន្ត្រីមានសមត្ថភាព និងឆន្ទៈវិជ្ជាជីវៈខ្ពស់ ដែលមានស្រាប់ ឱ្យនៅបំពេញការងារ ដើម្បីបន្តនិរន្តរភាព។
- បែងចែកមន្ត្រីផ្អែកលើគុណវុឌ្ឍិ, ជំនាញ, និងការចង់បានរបស់មន្ត្រី ដើម្បីធានាបាននូវការប្រើប្រាស់ចំជំនាញ និងមានប្រសិទ្ធភាព។
- កសាង និងពង្រឹងប្រព័ន្ធលើកទឹកចិត្ត ទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុសម្បូរបែប ដែលជំរុញលើកទឹកចិត្តមន្ត្រីឱ្យសកម្ម និងបុរេសកម្មការងារ និងអនុវត្តប្រព័ន្ធនេះ ប្រកបដោយតម្លាភាព ព្រមទាំងត្រូវពង្រឹងប្រព័ន្ធ និងយន្តការតាមដានវាយតម្លៃសមិទ្ធកម្ម ដើម្បីជាមូលដ្ឋានសម្រាប់ការផ្តល់ការលើកទឹកចិត្ត។
- បន្តអនុវត្តការងារជាក្រុម, ប្រកបដោយវិជ្ជាជីវៈ និងគោរពក្រមសីលធម៌វិជ្ជាជីវៈ, ប្រកាន់ខ្ជាប់ស្មារតីបុរេសកម្ម, និងរៀនផង - ធ្វើផង។
- ពិនិត្យឡើងវិញ និងកែសម្រួលតួនាទី និងភារកិច្ច នៃអង្គភាពគ្រប់គ្រងបំណុលសាធារណៈ ស្របតាមតម្រូវការជាក់ស្តែង និងឧត្តមានុវត្តជាអន្តរជាតិ។

## ៤.២. ផែនការសកម្មភាពក្នុងការបន្តពង្រឹងសមត្ថភាពធនធានមនុស្ស

- បន្តបំពាក់បំប៉នសមត្ថភាពមន្ត្រីពាក់ព័ន្ធ តាមអភិក្រម ដូចខាងក្រោម៖
    - **ការបណ្តុះបណ្តាលក្នុងស្រុក** ដែលរួមមាន៖ ១) ការរៀបចំវគ្គបណ្តុះបណ្តាលជំនាញ ដែលបង្ហាត់បង្ហាញដោយជំនាញការអន្តរជាតិ ឬមន្ត្រីនៃស្ថាប័នជំនាញអន្តរជាតិនានា, ២) ការរៀបចំសិក្ខាសាលា, វេទិកា ឬសន្និសីទ ដោយមានការចូលរួមពីជំនាញការជាតិ អន្តរជាតិ ឬមន្ត្រីជំនាញនៃក្រសួង ស្ថាប័នពាក់ព័ន្ធ, ៣) ការចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា វេទិកាពាក់ព័ន្ធ, និង ៤) ការសិក្សាតាមប្រព័ន្ធអ៊ីនធឺណែត។
    - **ការបណ្តុះបណ្តាលក្រៅប្រទេស** ដែលរួមមាន៖ ១) ការចូលរួមវគ្គបណ្តុះបណ្តាលជំនាញ ដែលរៀបចំដោយអង្គការ-ស្ថាប័នក្នុងតំបន់ ឬ អន្តរជាតិនានា, ២) ការចូលរួមសិក្ខាសាលា, វេទិកា ឬសន្និសីទក្នុងតំបន់ ឬអន្តរជាតិ លើប្រធានបទជំនាញពាក់ព័ន្ធ, ៣) ការធ្វើទស្សនកិច្ចសិក្សានៅតាមក្រសួង ស្ថាប័នជំនាញនៃប្រទេសក្នុងតំបន់ និងប្រទេសជឿនលឿននានាលើសកលលោក, និង ៤) ការចូលរួមកម្មវិធីហាត់ការរបស់ស្ថាប័នជំនាញអន្តរជាតិ។

បន្ថែមលើនេះ ត្រូវរៀបចំឱ្យមានកម្មវិធីបណ្តុះបណ្តាលផ្ទៃក្នុង ដើម្បីជាការចែករំលែកចំណេះដឹងបន្តពីមន្ត្រីដែលបានចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ដល់មន្ត្រីពាក់ព័ន្ធផ្សេងទៀត។

- បន្តយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពធនធានមនុស្ស លើមុខជំនាញសំខាន់ៗ ពាក់ព័ន្ធនឹងសមត្ថកិច្ចនៅតាមក្រសួង ស្ថាប័ន របស់ខ្លួន ដូចជា៖
    - <u>ការគ្រប់គ្រងបំណុលសាធារណៈ</u>
        - ការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ (Medium Term Debt Management Strategy – MTDS)
        - ការវិភាគចីរភាពបំណុល (Debt Sustainability Analysis – DSA)
        - ការវិភាគថ្លៃ និងហានិភ័យបំណុល (Debt Portfolio Analysis – DPA)
        - ការវិភាគថ្លៃ និងហានិភ័យ (Cost at Risk – CaR and Value at Risk – VaR)
        - ការគណនាកាតព្វកិច្ចបំណុលជាយថាហេតុ (Contingent Liabilities Calculation)
        - ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុសាធារណៈ និងកាតព្វកិច្ចបំណុលជាយថាហេតុ (Managing Fiscal Risks and Contingent Liabilities)
        - ការវិភាគកម្រិតសម្បទាននៃឥណទាន (Grant Element)
        - ការវិភាគវិបត្តិបំណុលរបស់បណ្តាប្រទេសនានាលើសកលលោក
        - ការគ្រប់គ្រងការធានា និងការផ្តល់ឥណទានរបស់រដ្ឋ
        - ការរៀបចំបោះផ្សាយ និងដាក់លក់មូលបត្ររដ្ឋ និងសញ្ញាបណ្ណរដ្ឋអធិបតេយ្យ និងតាមវិស័យទាំងក្នុង និងក្រៅប្រទេស (Sovereign and Thematic Bond Issuance)
        - ការវាយតម្លៃចំណាត់ថ្នាក់ឥណទាន (Credit Rating)
        - ការគណនាថ្លៃមូលបត្ររដ្ឋ និងអត្រាគូប៉ុង (Bond Price/Coupon Calculation)
        - ការស្រាវជ្រាវ និងវិភាគទីផ្សារ (Market Research and Analysis)
        - ការបង្កើត និងវិភាគខ្សែកោងទិន្នផល (Yield Curve Calculation and Analysis)
        - ការរៀបចំយន្តការបញ្ចៀស ឬបង្ការការខាតបង់តម្លៃហិរញ្ញវត្ថុ (Hedging Mechanism)
        - ការតាមដាន និងត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ
        - ការរៀបចំនិតិវិធីរួមប្រតិបត្តិការសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ
        - ការកត់ត្រា និងផ្ទៀងផ្ទាត់ទិន្នន័យបំណុល
        - ការរៀបចំរបាយការណ៍ និងព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈ
        - ការគ្រប់គ្រង និងថែរក្សាទិន្នន័យបំណុល
        - ការរៀបចំការវាយតម្លៃការគ្រប់គ្រងបំណុលសាធារណៈ (Debt Management Performance Assessment – DeMPA)
        - ការវិភាគ និងវាយតម្លៃលើគម្រោងវិនិយោគសាធារណៈធំៗ និងស្មុគស្មាញតាមយន្តការ PPP
        - ការវិភាគ និងវាយតម្លៃគម្រោងតាមវិធីសាស្ត្រតម្លៃនៃលុយ (Value for Money)

- ការគណនា និងវិភាគហិរញ្ញវត្ថុនៃគម្រោង (Project Financial Analysis)
- ការគ្រប់គ្រងរដ្ឋបាល, ការគ្រប់គ្រងហិរញ្ញវត្ថុ និងកិច្ចលទ្ធកម្មគម្រោង
- ការវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុសារធារណៈ (Public Investment Management Assessment – PIMA)
- ការវិភាគលើរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសសាធារណៈ
- ការព្យាករសូចនាករម៉ាក្រូសេដ្ឋកិច្ចគន្លឹះៗ
- និងមុខជំនាញពាក់ព័ន្ធចាំបាច់ផ្សេងទៀត។

- <u>**មុខជំនាញពាក់ព័ន្ធផ្សេងទៀត**</u>
  - មូលដ្ឋានគ្រឹះម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយរូបិយវត្ថុ (Fundamentals of Macroeconomics and Monetary Policy)
  - មូលដ្ឋានគ្រឹះទីផ្សារហិរញ្ញវត្ថុ (Fundamentals of Financial Market)
  - ការគ្រប់គ្រងហិរញ្ញវត្ថុ (Financial Management)
  - ការគ្រប់គ្រងហិរញ្ញវត្ថុ និងបំណុលសាធារណៈ (Public Finance and Debt Management)
  - ស្ថិតិ និងការវិភាគទិន្នន័យ (Statistics and Data Analysis)
  - ឧបករណ៍គាំទ្រការវិភាគ (Analytical Tools)
  - ការគ្រប់គ្រងសាច់ប្រាក់ និងថវិកា (Cash Management and Budgeting)
  - នីតិវិធីពន្ធដារ (Taxation)។ល។

# ជំពូកទី៥
# គម្រោងប៉ាន់ស្មានថវិកាចំណាយ សម្រាប់ការបន្តពង្រឹងសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស ២០២៤ - ២០២៨

*ឯកតា៖ ពាន់ដុល្លារអាមេរិក*

| ផែនការសកម្មភាព | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | សរុប |
|---|---|---|---|---|---|---|
| ១) ក្នុងស្រុក | **១២៥** | **១២៥** | **១២៥** | **១២៥** | **១២៥** | **៦២៥** |
| ក) វគ្គបណ្តុះបណ្តាលជំនាញ | ៦០ | ៦០ | ៦០ | ៦០ | ៦០ | ៣០០ |
| ខ) សិក្ខាសាលា | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ១៥០ |
| គ) វេទិកា | ២០ | ២០ | ២០ | ២០ | ២០ | ១០០ |
| ឃ) សន្និសីទ | ១០ | ១០ | ១០ | ១០ | ១០ | ៥០ |
| ង) ការសិក្សាតាមប្រព័ន្ធអ៊ីនធឺណែត | ៥ | ៥ | ៥ | ៥ | ៥ | ២៥ |
| ២) ក្រៅប្រទេស | **២៥០** | **២៥០** | **២៥០** | **២៥០** | **២៥០** | **១ ២៥០** |
| ក) វគ្គបណ្តុះបណ្តាលជំនាញ | ៥០ | ៥០ | ៥០ | ៥០ | ៥០ | ២៥០ |
| ខ) សិក្ខាសាលា | ៤០ | ៤០ | ៤០ | ៤០ | ៤០ | ២០០ |
| គ) វេទិកា | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ១៥០ |
| ឃ) សន្និសីទអន្តរជាតិ | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ១៥០ |
| ង) ទស្សនកិច្ចសិក្សា | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ៥០០ |
| សរុប (១+២)៖ | **៣៧៥** | **៣៧៥** | **៣៧៥** | **៣៧៥** | **៣៧៥** | **១ ៨៧៥** |

# អនុក្រឹត្យ
# ស្ដីពី
# ការគ្រប់គ្រងបំណុលសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១៧១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងបំណុលសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨/អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០/អនក្រ/បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនិងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៣៤/អនក្រ/បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការដំឡើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .** _

អនុក្រឹត្យនេះ មានគោលដៅកំណត់នូវ គោលការណ៍ណែនាំ គោលនយោបាយ យុទ្ធសាស្ត្រ មុខងារគ្រប់គ្រង យន្តការគ្រប់គ្រង និងបទប្បញ្ញត្តិនានាស្តីពីការ គ្រប់គ្រងបំណុលសាធារណៈ ។

**មាត្រា ២ .** _

អនុក្រឹត្យនេះមានគោលបំណង ៖

១- ធានាថា ការគ្រប់គ្រងបំណុលសាធារណៈ ត្រូវបានអនុវត្តដោយអនុលោម តាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ ធនាគារជាតិនៃកម្ពុជា ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់ស្តីពីមូលបត្ររដ្ឋ និងបទប្បញ្ញត្តិ ពាក់ព័ន្ធទាំងឡាយដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

២- កំណត់ក្របខ័ណ្ឌសម្រាប់គ្រប់គ្រងបំណុលសាធារណៈប្រកបដោយប្រសិទ្ធភាព ដើម្បីធានាឲ្យបាននូវ ៖

- ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច
- ការឆ្លើយតបទៅនឹងតម្រូវការហិរញ្ញប្បទាន ដោយរក្សាហានិភ័យ និង បន្ទុកសេវាបំណុលសាធារណៈឲ្យនៅកម្រិតអប្បបរមា
- ការរួមចំណែកអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៣- កំណត់គោលដៅ និងគោលការណ៍នៃការខ្ចីប្រាក់ពីគេ និងនៃការធានារបស់រដ្ឋ ។

៤- កំណត់គោលការណ៍រៀបចំរបាយការណ៍ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ។

៥- កំណត់គោលការណ៍រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ។

៦- កំណត់គោលការណ៍រៀបចំរបាយការណ៍គណនេយ្យ ស្តីពីបន្ទុកសេវាបំណុលសាធារណៈ ស្របតាមចំណាត់ថ្នាក់ថវិកា និងប្លង់គណនេយ្យទូទៅនៃគណនេយ្យរដ្ឋ ។

៧- ធានាលើការប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់រដ្ឋឲ្យបានត្រឹមត្រូវ តាមរយៈការធ្វើប្រតិភូកម្ម និងការត្រួតពិនិត្យរាល់សកម្មភាពពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ។

**មាត្រា ៣ .‑**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើប្រតិបត្តិការ ដូចខាងក្រោម ៖

១- ការផ្តល់សិទ្ធិអំណាច ការធ្វើប្រតិភូកម្មអំណាច និងការទទួលខុសត្រូវលើការគ្រប់គ្រងបំណុលសាធារណៈ

២- ការខ្ចីប្រាក់ពីក្នុង និង ក្រៅប្រទេស

៣- ការបោះផ្សាយមូលបត្ររដ្ឋលើទីផ្សារហិរញ្ញវត្ថុក្នុងប្រទេស

៤- ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យលើទីផ្សារហិរញ្ញវត្ថុអន្តរជាតិ

៥- ការឱ្យប្រាក់គេខ្ចី

៦- ការធានា និងការកត់ត្រាកាតព្វកិច្ចបំណុលជាយថាហេតុ

៧- ការវិនិយោគដោយប្រើអតិរេកសាច់ប្រាក់ ឬអតិរេកថវិកា

៨- ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ និងការរៀបចំរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ

៩- កិច្ចបញ្ជិកា និងការរៀបចំរបាយការណ៍បំណុលសាធារណៈ ។

**មាត្រា ៤ .‑**

និយមន័យនៃវាក្យស័ព្ទសម្រាប់ប្រើប្រាស់ក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់ដោយសន្ទានុក្រមដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូកទី ២

## សិទ្ធិអំណាច ការធ្វើប្រតិភូកម្មអំណាច និងការទទួលខុសត្រូវ

**មាត្រា ៥ . _**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចចាត់ចែងលើរាល់ប្រតិបត្តិការពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ។

**មាត្រា ៦ . _**

ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និងស្ថិតក្រោមអំណាចនាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែមួយគត់ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ ការបោះផ្សាយមូលបត្ររដ្ឋ ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ការវិនិយោគ ការធានានិងការសន្យាផ្នែកហិរញ្ញវត្ថុនានា ការឲ្យប្រាក់គេខ្ចី និងការរៀបចំរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ ។

លក្ខខណ្ឌផ្នែកហិរញ្ញវត្ថុ និង ទំហំទឹកប្រាក់នៃការខ្ចីប្រាក់ពីគេ ការឱ្យប្រាក់គេខ្ចី ការបោះផ្សាយមូលបត្ររដ្ឋ ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ការធានានិងការសន្យាផ្នែកហិរញ្ញវត្ថុនានា ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

ការរៀបចំរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ ត្រូវកំណត់ដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

**មាត្រា ៧ . _**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិធ្វើប្រតិភូកម្មអំណាចដល់មន្ត្រីមួយ ឬច្រើនរូប ដើម្បីបំពេញភារកិច្ចដូចមានចែងក្នុងមាត្រា ៦ នៃអនុក្រឹត្យនេះ ។ ការធ្វើប្រតិភូកម្មអំណាចត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

**មាត្រា ៨ . _**

វៀរលែងតែមានបដិប្បញ្ញត្តិដោយច្បាប់ និងស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចខ្ចីប្រាក់ពីគេសម្រាប់បម្រើឲ្យគោលដៅ ដូចខាងក្រោម ៖

១- ហិរញ្ញប្បទានលើគម្រោងអាទិភាព ដែលមានកំណត់ក្នុងកម្មវិធីវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាល

២- បន្តពង្រឹងការគ្រប់គ្រងគោលនយោបាយថវិកា

៣- ផ្តល់ឲ្យសហគ្រាសសាធារណៈខ្ចី

៤- ផ្តល់ឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុខ្ចី ដោយធ្វើការពិគ្រោះយោបល់ជាមួយធនាគារជាតិនៃកម្ពុជាជាមុន

៥- ហិរញ្ញប្បទានលើឱនភាពថវិកា

៦- ទទួលបាននូវរូបិយប័ណ្ណបរទេស

៧- ហិរញ្ញប្បទានលើបំណុលដែលដល់ឥណប្រតិទាន

៨- ផ្តល់ឲ្យរដ្ឋបរទេសខ្ចី ។

**មាត្រា ៩ . _**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចធ្វើប្រតិបត្តិការណាមួយដែលនាំឱ្យកើតមានបំណុលសាធារណៈបាន លុះត្រាតែធ្វើឡើងស្របតាមគោលការណ៍ និងលក្ខខណ្ឌកំណត់ដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់ស្តីពីមូលបត្ររដ្ឋ និងបទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយ ដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១០ . _**

រាល់ការដោះស្រាយកាតព្វកិច្ចបំណុលសាធារណៈរបស់រដ្ឋ ត្រូវធ្វើឡើងតាមគោលការណ៍ស្មើភាពចំពោះគ្រប់ម្ចាស់បំណុលទាំងអស់ ។

វៀរលែងតែមានបដិប្បញ្ញត្តិដោយច្បាប់ រាជរដ្ឋាភិបាលមិនត្រូវយកធនធាន ឬទ្រព្យសម្បត្តិរដ្ឋ ឬចំណូលរដ្ឋ ធ្វើជាកម្មវត្ថុនៃការបញ្ចាំក្នុងការខ្ចីប្រាក់ពីគេ ការបោះផ្សាយមូលបត្ររដ្ឋ ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ការផ្តល់ការសន្យាឬការធានាណាមួយ ដែលនាំឱ្យកើតកាតព្វកិច្ចបំណុលបានទេ ។ ធនធាន ឬទ្រព្យសម្បត្តិរដ្ឋ ឬចំណូលរដ្ឋ ត្រូវទទួលបាននូវការការពារដោយរាជរដ្ឋាភិបាលពីការរឹបអូស ឬការឃាត់ទុកផ្សេងៗ ។

**មាត្រា ១១ . _**

រាជរដ្ឋាភិបាល ត្រូវបង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានភារកិច្ចរៀបចំនិងត្រួតពិនិត្យ

ការអនុវត្តគោលនយោបាយគ្រប់គ្រងបំណុលសាធារណៈ និងពិនិត្យយល់ព្រមលើយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈមុននឹងដាក់សុំការសម្រេចពីនាយករដ្ឋមន្ត្រី ។

គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ត្រូវមានសមាសភាពមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ។

**មាត្រា ១២ . _**

រាល់ការងារបច្ចេកទេសនិងប្រតិបត្តិការពាក់ព័ន្ធនឹងមូលបត្ររដ្ឋ អាចអនុវត្តដោយធនាគារជាតិនៃកម្ពុជា ក្នុងនាមជាភ្នាក់ងារគ្រប់គ្រងមូលបត្ររដ្ឋរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៣ . _**

រាជរដ្ឋាភិបាលត្រូវបង្កើតមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ដើម្បីគ្រប់គ្រងការបោះផ្សាយនិងការទូទាត់សងមូលបត្ររដ្ឋ និងការងារពាក់ព័ន្ធផ្សេងទៀត ។

អនុញ្ញាតឲ្យរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដាក់ឱ្យធ្វើប្រតិបត្តិការ និងគ្រប់គ្រងមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចធ្វើប្រតិភូកម្មអំណាចពាក់ព័ន្ធនឹងប្រតិបត្តិការ និងការគ្រប់គ្រងមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ជូនទេសាភិបាលធនាគារជាតិនៃកម្ពុជា ។

**មាត្រា ១៤ . _**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្កើតគណៈកម្មាធិការគ្រប់គ្រងប្រតិបត្តិការមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ដើម្បីពិនិត្យ ពិភាក្សា និងលើកយោបល់ជូនគណៈកម្មាធិការចម្រុះសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ ស្តីពីការរៀបចំក្របខ័ណ្ឌគតិយុត្តិពាក់ព័ន្ធនឹងមូលបត្ររដ្ឋ ព្រមទាំងកិច្ចប្រតិបត្តិការនិងការគ្រប់គ្រងមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ។

**មាត្រា ១៥ . _**

គណៈកម្មាធិការគ្រប់គ្រងប្រតិបត្តិការមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ត្រូវមានសមាជិកយ៉ាងច្រើន ៩រូប ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវតែងតាំងសមាជិកជាមន្ត្រីជាន់ខ្ពស់ ដែលមានសមាសភាពមកពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ធនាគារជាតិនៃកម្ពុជា ក្រសួង និងស្ថាប័នពាក់ព័ន្ធ ផ្អែកតាមសំណើរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា និងប្រធានស្ថាប័នពាក់ព័ន្ធ ។

គណៈកម្មាធិការគ្រប់គ្រងប្រតិបត្តិការមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ត្រូវដឹកនាំដោយអគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវមានលេខាធិការដ្ឋានសម្រាប់តាមដានត្រួតពិនិត្យលើប្រតិបត្តិការពាក់ព័ន្ធនឹងការបោះផ្សាយមូលបត្ររដ្ឋ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគ្រប់គ្រងប្រតិបត្តិការមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

**មាត្រា ១៦ . _**

អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវទទួលបន្ទុកលើរាល់ប្រតិបត្តិការពាក់ព័ន្ធនឹងមូលបត្ររដ្ឋមិនអាចជួញដូរបាន ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៧ . _**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចរៀបចំរបាយការណ៍ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ជូនរាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា តាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

## ជំពូកទី ៣
## បំណុលសាធារណៈ ការឲ្យប្រាក់គេខ្ចី និងការវិនិយោគ

**មាត្រា ១៨ . _**

រាល់ការខ្ចីប្រាក់ពីគេ ការបោះផ្សាយនិងការដាក់លក់មូលបត្ររដ្ឋលើទីផ្សារក្នុងប្រទេស ការបោះផ្សាយនិងការដាក់លក់សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យលើទីផ្សារអន្តរជាតិ ការធានា និងកាតព្វកិច្ចបំណុលជាយថាហេតុ ត្រូវធ្វើឡើងស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងច្បាប់ស្តីពីមូលបត្ររដ្ឋ ។

រាល់ការងារបច្ចេកទេស និងប្រតិបត្តិការពាក់ព័ន្ធនឹងការខ្ចីប្រាក់ពីគេ ការបោះផ្សាយនិងការដាក់លក់មូលបត្ររដ្ឋលើទីផ្សារក្នុងប្រទេស ការបោះផ្សាយនិងការដាក់

លក់សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យលើទីផ្សារអន្តរជាតិ ការធានា និងកាតព្វកិច្ចបំណុលជាយថាហេតុ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ឬប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមបទប្បញ្ញតិនៃច្បាប់ និងតាមការសម្រេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ១៩ . _**

រាល់ការដកសាច់ប្រាក់ ការចាត់ចែង និងការទូទាត់សេវាបំណុលសាធារណៈក្រៅប្រទេស ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌ និងនីតិវិធី ដែលមានចែងក្នុងកិច្ចព្រមព្រៀងឥណទាន និងបទប្បញ្ញត្តិពាក់ព័ន្ធដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

ការបោះផ្សាយនិងការដាក់លក់មូលបត្ររដ្ឋលើទីផ្សារក្នុងប្រទេស ត្រូវអនុវត្តតាមច្បាប់ស្តីពីមូលបត្ររដ្ឋ ។

ការបោះផ្សាយនិងការដាក់លក់សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យលើទីផ្សារអន្តរជាតិ ត្រូវអនុវត្តតាមសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ កិច្ចព្រមព្រៀង ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។ ការចាត់ចែង និងការទូទាត់សេវាបំណុលនៃសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌ ដែលមានចែងក្នុងកិច្ចព្រមព្រៀង ព្រមទាំងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២០ . _**

ស្ថិតក្រោមបទប្បញ្ញតិនៃច្បាប់ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងនាមរាជរដ្ឋាភិបាល គឺជាអ្នកផ្តល់ការធានាជាលាយលក្ខណ៍អក្សរលើកិច្ចសន្យា ឬកិច្ចព្រមព្រៀង ឬគម្រោងដែលអនុវត្តដោយសហគ្រាសសាធារណៈ ឬសហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

រាល់សហគ្រាសសាធារណៈ ឬសហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានការធានាពីរាជរដ្ឋាភិបាល ត្រូវទូទាត់កម្រៃធានា និងកម្រៃពាក់ព័ន្ធផ្សេងទៀតជូនរាជរដ្ឋាភិបាល ។

គោលនយោបាយកំណត់កម្រៃធានា និងកម្រៃពាក់ព័ន្ធផ្សេងទៀត ព្រមទាំងកាតព្វកិច្ចរបាយការណ៍របស់សហគ្រាសសាធារណៈ ឬសហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានការធានា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

រាល់ការចរចាពាក់ព័ន្ធនឹងការធានា ត្រូវធ្វើឡើងដោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

អនុញ្ញាតឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយកកម្រៃពីការធានា និងកម្រៃពាក់ព័ន្ធផ្សេងទៀត សម្រាប់ជាគុណប្រយោជន៍នៃចំណូលថវិការដ្ឋ និងការគ្រប់គ្រងបំណុលសាធារណៈ ។

**មាត្រា ២១ . _**

សហគ្រាសសាធារណៈ ឬសហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានការធានាពីរាជរដ្ឋាភិបាល តែការធានានោះត្រូវបានដកហូតមកវិញ ដោយសារការខកខានមិនបានបំពេញកាតព្វកិច្ចសេវាបំណុលតាមកិច្ចព្រមព្រៀង ត្រូវមានកាតព្វកិច្ចទូទាត់ជូនរាជរដ្ឋាភិបាលនូវរាល់ការចំណាយពាក់ព័ន្ធរួមមាន ៖ សេវាបំណុល ប្រាក់ពិន័យ និងចំណាយពាក់ព័ន្ធផ្សេងទៀត ។

**មាត្រា ២២ . _**

រាល់ការឱ្យប្រាក់គេខ្ចី ត្រូវធ្វើឡើងស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ក្រោមទម្រង់ជាកិច្ចព្រមព្រៀងឥណទានដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងនាមរាជរដ្ឋាភិបាល ឬតាមការប្រទានសិទ្ធិ ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ។

រាល់ឥណទាយិក ដែលទទួលបានហិរញ្ញប្បទានឥណទានពីរាជរដ្ឋាភិបាល ត្រូវទូទាត់សេវាបំណុលជូនរាជរដ្ឋាភិបាល ។

គោលនយោបាយកំណត់លក្ខខណ្ឌនៃការឲ្យប្រាក់គេខ្ចី និងកាតព្វកិច្ចរបាយការណ៍របស់ឥណទាយិក ដែលទទួលបានហិរញ្ញប្បទានឥណទានពីរាជរដ្ឋាភិបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

រាល់ការងារបច្ចេកទេស និងប្រតិបត្តិការពាក់ព័ន្ធនឹងការឱ្យប្រាក់គេខ្ចី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២៣ . _**

ស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និងក្រោមអំណាចនាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែមួយគត់ ដែលមានសិទ្ធិក្នុងការវិនិយោគដោយ

ប្រើអតិរេកសាច់ប្រាក់ ឬអតិរេកថវិកា ក្រោមទម្រង់ជាការវិនិយោគលើសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យនៃរដ្ឋបរទេស និងការវិនិយោគលើអចលកម្មហិរញ្ញវត្ថុផ្សេងៗ ។

## ជំពូកទី ៤
## ការទូទាត់សេវាបំណុលសាធារណៈ

**មាត្រា ២៤ .-**

រាល់ការទូទាត់សេវាបំណុលសាធារណៈ ត្រូវអនុវត្តដោយអនុលោមតាមច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់ស្តីពីមូលបត្ររដ្ឋ និងកិច្ចព្រមព្រៀងឥណទាន ។

**មាត្រា ២៥ .-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចព្យាករណ៍សេវាបំណុលសាធារណៈស្របតាមចំណាត់ថ្នាក់ថវិកា និងប្លង់គណនេយ្យទូទៅនៃគណនេយ្យរដ្ឋ ដើម្បីដាក់បញ្ចូលទៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

**មាត្រា ២៦ .-**

រាល់ការទូទាត់សេវាបំណុលសាធារណៈ ត្រូវធ្វើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកលែងតែការទូទាត់ដោយប្រើមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ដែលត្រូវធ្វើឡើងស្របតាមបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងមូលបត្ររដ្ឋ ។

នីតិវិធី និងយន្តការនៃការទូទាត់សេវាបំណុលសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៥
## យុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ

**មាត្រា ២៧ .-**

យុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ គឺជាក្របខ័ណ្ឌយុទ្ធសាស្ត្រ ដែលចែងអំពីគោលដៅគ្រប់គ្រងបំណុលសាធារណៈរយៈពេលមធ្យម ឬវែង របស់រាជរដ្ឋាភិបាល អនុលោមតាមបរិបទនៃក្របខ័ណ្ឌគោលនយោបាយថវិកា ស្ថានភាពបំណុលបច្ចុប្បន្ន និង

ផែនការតម្រូវការហិរញ្ញប្បទាន ដោយរក្សាហានិភ័យ និងបន្ទុកសេវាបំណុលសាធារណៈឲ្យនៅកម្រិតអប្បបរមា ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចរៀបចំសេចក្ដីព្រាងយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈរៀងរាល់ ៥ឆ្នាំម្ដង ដើម្បីដាក់ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈពិនិត្យយល់ព្រម មុននឹងសុំការសម្រេចពីនាយករដ្ឋមន្ត្រី ។

យុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ អាចត្រូវបានធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់ ។

**មាត្រា ២៨ .** –

រាល់ប្រតិបត្តិការពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ត្រូវអនុវត្តអនុលោមតាមយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ។

**មាត្រា ២៩ .** –

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចផ្សព្វផ្សាយជាសាធារណៈនូវខ្លឹមសារសង្ខេបនៃយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ។

ទម្រង់ និងខ្លឹមសារសង្ខេបនៃយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៣០ .** –

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចតាមដានរាល់សូចនាករសំខាន់ៗនៃបំណុលក្រៅប្រទេសនិងបំណុលសាធារណៈ និងវិភាគចីរភាពបំណុលរៀងរាល់ ២ឆ្នាំម្ដង ។ ការវិភាគចីរភាពបំណុល អាចត្រូវបានធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់ ។

**មាត្រា ៣១ .** –

យន្តការ និងវិធីសាស្ត្រក្នុងការវិភាគចីរភាពបំណុល និងការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៦
## កិច្ចបញ្ជិកា និង ការរៀបចំរបាយការណ៍

**មាត្រា ៣២.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចធ្វើកិច្ចបញ្ជិកានូវរាល់ប្រតិបត្តិការហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ក្នុងគណនីរតនាគារជាតិស្របតាមចំណាត់ថ្នាក់ថវិកា និងប្លង់គណនេយ្យទូទៅនៃគណនេយ្យរដ្ឋ ។

**មាត្រា ៣៣.-**

វិធាននៃកិច្ចបញ្ជិកាគណនេយ្យ ពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៣៤.-**

អនុញ្ញាតឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចេញផ្សាយជាផ្លូវការនូវព័ត៌មានស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ។

ទម្រង់ និងខ្លឹមសារនៃព័ត៌មានស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ៣៥.-**

មន្ត្រីសាធារណៈគ្រប់ជាន់ថ្នាក់ ដែលត្រូវបានរកឃើញថា មិនបានគោរពតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ក្នុងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនដែលរដ្ឋបានប្រគល់ជូន ត្រូវទទួលទណ្ឌកម្មខាងវិន័យទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិជាធរមាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៣៦ . _**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៧ . _**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចមាត្រា ៣៧
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# សទ្ទានុក្រមសម្រាប់ប្រើប្រាស់ក្នុង
# អនុក្រឹត្យស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ

**ការខ្ចីប្រាក់ពីគេ** (Borrowing) សំដៅដល់ប្រតិបត្តិការដូចខាងក្រោម ៖

១- ការបោះផ្សាយមូលបត្ររដ្ឋ

២- ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ

៣- ការចុះកិច្ចព្រមព្រៀងឥណទានជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ឬរដ្ឋាភិបាលបរទេស ឬ ភ្នាក់ងារឥណទានរបស់រដ្ឋាភិបាលបរទេស

៤- ការចុះកិច្ចព្រមព្រៀងឥណទានជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៥- ការខ្ចីប្រាក់ពីធនាគារជាតិនៃកម្ពុជា សម្រាប់ហិរញ្ញប្បទានលើឱនភាពថវិការយៈពេលខ្លី ស្របតាមលក្ខខណ្ឌកំណត់នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា និងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

៦- ការចុះកិច្ចព្រមព្រៀងឥណទានផ្សេងទៀត ។

រាល់ការទិញជំពាក់នូវទំនិញ ឬសេវា ដែលមានរយៈពេល តិចជាងឬស្មើ ១៨០ថ្ងៃ គិតចាប់ពីថ្ងៃទិញ មិនត្រូវបានចាត់ទុកជាការខ្ចីប្រាក់ពីគេឡើយ ។

**ការគ្រប់គ្រងបំណុលសាធារណៈ** (Public Debt Management) សំដៅដល់ការគ្រប់គ្រងលើរាល់ប្រតិបត្តិការរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹង ការខ្ចីប្រាក់ពីគេ ការឲ្យប្រាក់គេខ្ចី ការបោះផ្សាយនិងការដាក់លក់មូលបត្ររដ្ឋ ការបោះផ្សាយនិងការដាក់លក់សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ការធានា កាតព្វកិច្ចបំណុលជាយថាហេតុ ការទូទាត់សេវាបំណុល ការរៀបចំរចនាសម្ព័ន្ធបំណុលឡើងវិញ ការគ្រប់គ្រងហានិភ័យ ការវិនិយោគដោយប្រើអតិរេកសាច់ប្រាក់ ឬអតិរេកថវិកា និងប្រតិបត្តិការផ្សេងទៀតពាក់ព័ន្ធនឹងបំណុលសាធារណៈ។

**កាតព្វកិច្ចបំណុលជាយថាហេតុ** (Contingent Liability) សំដៅដល់កាតព្វកិច្ចហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលក្នុងការទូទាត់សំណង ប្រសិនបើមានព្រឹត្តិការណ៍

ជាក់លាក់ណាមួយកើតឡើងនាពេលអនាគត ដូចជា ការធានា ការរ៉ាប់រង ការទូទាត់សំណងអន្តរាយ ការបង់វិភាគទានដើម្បីធានាសមាជិកភាពកម្ពុជាក្នុងអង្គការអន្តរជាតិនានា និងការផ្តល់សំណងតាមបណ្តឹងនីត្យានុកូល ។

**ការធានា** (Guarantee) សំដៅដល់កាតព្វកិច្ចទូទាត់សេវាបំណុលរបស់សហគ្រាសសាធារណៈ សហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលរាជរដ្ឋាភិបាលបានធានាសងជំនួសនូវការប្រាក់ ឬប្រាក់ដើម ឬទាំងការប្រាក់និងប្រាក់ដើម ព្រមទាំងកម្រៃពាក់ព័ន្ធផ្សេងទៀត ក្នុងករណីដែលសហគ្រាសសាធារណៈ សហគ្រាសពាណិជ្ជកម្ម ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនោះ ពុំមានលទ្ធភាពបំពេញកាតព្វកិច្ចទូទាត់សេវាបំណុល ។

**ការរៀបចំរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ** (Debt Restructuring) សំដៅដល់ ការធ្វើហិរញ្ញប្បទានឡើងវិញចំពោះបំណុលបច្ចុប្បន្ន ការបំប្លែងបំណុល ការបង្រួមបំណុល ការទូទាត់សងបំណុលមុនឥណប្រតិទាន ការរៀបចំកម្មវិធីសងបំណុលឡើងវិញ ការរំកិលបំណុល ការទិញបំណុលមកវិញ និងការដោះដូរបំណុល ដើម្បីកាត់បន្ថយបន្ទុកសេវាបំណុល និងហានិភ័យ ។ វាក្យស័ព្ទដែលប្រើសម្រាប់និយមន័យនេះត្រូវបានកំណត់ដូចខាងក្រោម ៖

- **ការបំប្លែងបំណុល** (Debt Conversion) សំដៅដល់ការដោះដូរបំណុល ដើម្បីទទួលបានជាថ្នូរមកវិញនូវទុនវិនិយោគ សម្រាប់ហិរញ្ញប្បទានលើគម្រោង ឬការអនុវត្តគោលនយោបាយអាទិភាពបន្ទាន់ណាមួយ ។
- **ការបង្រួមបំណុល** (Debt Consolidation) សំដៅដល់ការបោះផ្សាយ និងដាក់លក់បំណុលថ្មី ដើម្បីហិរញ្ញប្បទានដល់ការប្រមូលទិញបំណុលបច្ចុប្បន្នមកវិញ ក្នុងគោលដៅកាត់បន្ថយចំនួនប័ណ្ណរតនាគារ ឬសញ្ញាប័ណ្ណរតនាគារ ។ ប្រតិបត្តិការនេះច្រើនប្រើនៅក្នុងទីផ្សារមូលបត្រក្នុងប្រទេស ។
- **ការទូទាត់សងមុន** (Prepayment) សំដៅដល់ការអនុវត្តសិទ្ធិក្នុងការទូទាត់សងប្រាក់ដើមមុនឥណប្រតិទានតាមតម្លៃចារឹក ឬដោយមានបន្ថែមប្រាក់ពិន័យ ដូចមានចែងក្នុងកិច្ចព្រមព្រៀងឥណទាន ។
- **ការរំកិលបំណុល** (Rolling Over) សំដៅដល់ការបោះផ្សាយ និងដាក់លក់បំណុលថ្មី សម្រាប់ទូទាត់សងបំណុលបច្ចុប្បន្នដែលដល់ឥណប្រតិទាន ។ ប្រតិបត្តិការនេះច្រើនប្រើសម្រាប់ការដាក់លក់ប័ណ្ណរតនាគារ ។
- **ការដោះដូរបំណុល** (Debt Swap) សំដៅដល់ការប្តូរពីកាតព្វកិច្ច

បំណុលមួយទៅកាតព្វកិច្ចបំណុលមួយផ្សេងទៀត ដែលមានរចនាសម្ព័ន្ធបំណុលផ្សេងគ្នា ដូចជា ៖ រូបិយប័ណ្ណ ឬអត្រាការប្រាក់ ឬតណប្រតិទាន ។

**ការវិនិយោគ** (Investments) សំដៅដល់ការទិញសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យនៃរដ្ឋបរទេស ឬការវិនិយោគលើអចលកម្មហិរញ្ញវត្ថុផ្សេងទៀត ដោយប្រើអតិរេកសាច់ប្រាក់ ឬអតិរេកថវិកា ។

**ការឱ្យប្រាក់គេខ្ចី** (Lending and Onlending) សំដៅដល់ប្រាក់របស់រដ្ឋ ឬប្រាក់ដែលរដ្ឋខ្ចីពីគេ ឬហិរញ្ញប្បទានឥតសំណងពីដៃគូអភិវឌ្ឍន៍ សម្រាប់ឲ្យសហគ្រាសសាធារណៈ ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬរដ្ឋបរទេសខ្ចី ក្នុងគោលដៅជម្រុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ។

**ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ** (Annual Financial Management Law) គ្រោង និងអនុញ្ញាតសម្រាប់ឆ្នាំនីមួយៗនូវប្រភពធនធាន និងបន្ទុករបស់រដ្ឋ ។

**បំណុលក្រៅប្រទេស** (External Debt) សំដៅដល់បំណុលក្រៅប្រទេសរបស់ព្រះរាជាណាចក្រកម្ពុជាដែលរួមមាន ៖ បំណុលសាធារណៈ បំណុលផ្នែកឯកជន និងបំណុលដែលរដ្ឋាភិបាលមុនមិនទាន់បានដោះស្រាយ ។

**បំណុលសាធារណៈ** (Public Debt) សំដៅដល់បំណុលរបស់រដ្ឋ ដែលកើតឡើងស្របតាមច្បាប់អនុញ្ញាត និងដោយមិនរាប់បញ្ចូលបំណុលដែលពុំមានការធានាពីរាជរដ្ឋាភិបាល។

**ភ្នាក់ងារគ្រប់គ្រងមូលបត្ររដ្ឋ** (Government Securities Management Agency – GSMA) សំដៅដល់ធនាគារជាតិនៃកម្ពុជាដែលធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងមូលបត្ររដ្ឋតាមការធ្វើប្រតិភូកម្មអំណាចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែប្រតិបត្តិការពាក់ព័ន្ធនឹងមូលបត្ររដ្ឋមិនអាចជួញដូរបាន ។

**មូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ** (Government Securities Management Fund – GSMF) សំដៅដល់ប្រាក់ដែលផ្តល់ឱ្យដោយរាជរដ្ឋាភិបាល និងប្រាក់ដែលបានមកពីស្ថាប័នឯកជន និងសាធារណៈតាមរយៈការបោះផ្សាយមូលបត្ររដ្ឋ ។

**មូលបត្ររដ្ឋមិនអាចជួញដូរបាន** (Non-marketable Securities) សំដៅដល់មូលបត្រទាំងឡាយណាដែលត្រូវសងទៅឲ្យអ្នកកាន់កាប់មូលបត្រដែលបានចុះបញ្ជី ឬសន្តតិជនពេញសិទ្ធិតាមលក្ខខណ្ឌរបស់មូលបត្រនោះ ដោយស្របទៅតាមវិសាលភាព និងការកំណត់របស់ប្រកាសដែលដាក់ឲ្យអនុវត្តដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អ្នកកាន់កាប់មូលបត្រ ឬសន្តតិជនពេញសិទ្ធិ មានសិទ្ធិស្នើសុំការទូទាត់សង

មុនឥណប្រតិទាន ទៅតាមលក្ខខណ្ឌនៃមូលបត្រទាំងនោះ ។

**មូលបត្ររដ្ឋ** (Government Securities) សំដៅដល់ប័ណ្ណ សញ្ញាប័ណ្ណ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល។ មូលបត្ររដ្ឋរួមមាន ៖

១- ប័ណ្ណរតនាគារដែលមានឥណប្រតិទានតិចជាងមួយឆ្នាំ

២- សញ្ញាប័ណ្ណរតនាគារដែលមានឥណប្រតិទានចាប់ពីមួយឆ្នាំឡើងទៅ

៣- សញ្ញាប័ណ្ណដែលផលចំណូលផ្សារភ្ជាប់ជាមួយនឹងអត្រាអតិផរណា ឬអត្រាប្តូរប្រាក់ ឬអត្រាផ្សេងៗ

៤- មូលបត្ររដ្ឋដែលមិនអាចជួញដូរបាន

៥- មូលបត្ររដ្ឋផ្សេងៗដទៃទៀត ដែលបោះផ្សាយស្របតាមច្បាប់អនុញ្ញាត ។

**សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ** (Sovereign Bonds) សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលត្រូវបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាលលើទីផ្សារអន្តរជាតិ ។

**សេវាបំណុល** (Debt Service) សំដៅដល់ការទូទាត់ប្រាក់ដើម ការប្រាក់ និងកម្រៃពាក់ព័ន្ធផ្សេងទៀតនៃកាតព្វកិច្ចបំណុល ។

**សហគ្រាសសាធារណៈ** (Public Enterprise) សំដៅដល់សហគ្រាសដែលមានដើមទុនទាំងអស់ ឬភាគច្រើនជារបស់រដ្ឋ ។ សហគ្រាសសាធារណៈមានបេសកកម្មបង្កលក្ខណៈដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ជាអាទិ៍ក្នុងការបង្កើនតម្លៃធនធានធម្មជាតិ និងការបង្កើតអាជីព ។

# សេចក្ដីសម្រេច
# ស្ដីពី
# ការបង្កើតគណៈកម្មាធិការ
# គ្រប់គ្រងបំណុលសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧១ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ

★

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៩២ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងមុខតំណែងឥស្សរជនជារដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៦៧៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការតែងតាំងអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៤០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៤០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ

- សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ១១.សសរ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១._**

បង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈមានសមាសភាព ដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១-ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ | **អូន ព័ន្ធមុនីរ័ត្ន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២-លោកជំទាវ | **ជា សិរី** | ទេសាភិបាល ធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៣-ឯកឧត្តម | **វង្ស វិសិលវ៉ា** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៤-ឯកឧត្តម | **រ័ត្ន សុវណ្ណនរៈ** | ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៥-ឯកឧត្តម | **ម៉ែន ធីរុទ្ធ** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦-ឯកឧត្តម | **ឈួន សិរីរិទ្ធិ** | អគ្គនាយក នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៧-លោក | **ឃូ ទុំតញ្ញី** | អគ្គនាយកគោលនយោបាយ និងសហប្រតិបត្តិការអន្តរជាតិ ធនាគារជាតិនៃកម្ពុជា | សមាជិក។ |

**ប្រការ២._**

គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ជាចំណុចប្រមូលផ្តុំរបស់រាជរដ្ឋាភិបាល មានមុខងារ និងភារកិច្ច ដូចតទៅ÷

- រៀបចំ និងត្រួតពិនិត្យការអនុវត្តចក្ខុវិស័យ និងគោលនយោបាយស្តីពីការគ្រប់គ្រងបំណុលសាធារណៈ
- ពិនិត្យយល់ព្រមលើយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ មុននឹងដាក់សុំការសម្រេចពីនាយករដ្ឋមន្ត្រី
- ធ្វើជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការសម្របសម្រួលគោលនយោបាយពាក់ព័ន្ធ ដើម្បីធានាឱ្យមានសង្គតិភាពរវាងកិច្ចដំណើរការគ្រប់គ្រងបំណុលសាធារណៈ ជាមួយនឹងគោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុ, ថវិកា, និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល។

**ប្រការ៣._**

គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ធ្វើការប្រជុំសាមញ្ញរបស់ខ្លួនក្នុងរយៈពេល ៦ (ប្រាំមួយ) ខែមួយដង តាមការអញ្ជើញរបស់ប្រធាន ឬអាចប្រជុំញឹកញាប់ជាងនេះ ទៅតាមតម្រូវការចាំបាច់នៃការងារ។

**ប្រការ៤._**

គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ អាចបង្កើតគណៈកម្មការ ឬក្រុមការងារផ្សេងៗទៅតាមការចាំបាច់ ដើម្បីសម្របសម្រួលការរៀបចំ និងតាមដានការអនុវត្តផែនការសកម្មភាព កម្មវិធីនានា ពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ។

**ប្រការ៥._**

ប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ អាចអញ្ជើញថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនានា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធដែលមិនមែនជាសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ឱ្យចូលរួមប្រជុំតាមតម្រូវការចាំបាច់នៃការងារ។

**ប្រការ៦._**

ក្នុងករណីអវត្តមាន សមាជិកនៃគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈអាចស្នើសុំការអនុញ្ញាតពីប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីចាត់តាំងមន្ត្រីពាក់ព័ន្ធឱ្យចូលរួមប្រជុំជំនួស។ សមាជិកគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ អាចស្នើសុំការអនុញ្ញាតពីប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ឱ្យមន្ត្រីជំនាញដែលមានការពាក់ព័ន្ធផ្ទាល់ទៅនឹងការងារគ្រប់គ្រងបំណុលសាធារណៈ ចូលរួមប្រជុំក្នុងឋានៈជាមន្ត្រីជំនួយការ។

**ប្រការ៧._**

គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ មានអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន បំពេញមុខងារជាសេនាធិការបច្ចេកទេសរបស់ខ្លួនក្នុងការបំពេញការងារ។

**ប្រការ៨._**

គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងការបំពេញការងាររបស់ខ្លួន។

**ប្រការ៩._**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៥ រោច ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែមេសា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# សមាសភាព

# ក្រុមការងារបច្ចេកទេសរៀបចំ

# យុទ្ធសាស្ត្រស្តីពី

# ការគ្រប់គ្រងបំណុលសាធារណៈ

# ២០២៤ - ២០២៨

*« **យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤ - ២០២៨** » ត្រូវបានរៀបចំ និងតាក់តែង ដោយក្រុមការងារបច្ចេកទេសរបស់**អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (អ.ស.ប.) នៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមការណែនាំរបស់គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ** ដែលបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៧១ សសរ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ តាមទស្សនៈគិតគូរវែងឆ្ងាយប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា។*

*ក្រុមការងារបច្ចេកទេសនេះ ដឹកនាំផ្ទាល់ដោយឯកឧត្តម **ម៉ែន ធីរុត្ថ** អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសម្របសម្រួលដោយឯកឧត្តម **ឈួន សំរិទ្ធិ** អគ្គនាយក នៃ អ.ស.ប. ដែលមានសមាសភាព ដូចខាងក្រោម៖*

| | | | |
|---|---|---|---|
| ១- | លោក | **ម៉ាង សុតារ៉ា** | អគ្គនាយករង នៃ អ.ស.ប. និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ |
| ២- | លោក | **ឃឹម ហ្វាដាណោ** | អគ្គនាយករង នៃ អ.ស.ប. |
| ៣- | លោកស្រី | **ឈុន វីរៈវឌ្ឍនា** | អតីតប្រធាននាយកដ្ឋានវិភាគ និងគ្រប់គ្រងហានិភ័យបំណុល |
| ៤- | លោកស្រី | **ឌុន មូនីតា** | ប្រធាននាយកដ្ឋានវិភាគ និងគ្រប់គ្រងហានិភ័យបំណុល |
| ៥- | លោក | **ខៀវ ណារ៉ាវ៉ា** | ប្រធាននាយកដ្ឋានគ្រប់គ្រងសេវាបំណុល |
| ៦- | លោក | **ឆៀង សុខតីរស្មី** | ប្រធាននាយកដ្ឋានមូលបត្ររដ្ឋ |
| ៧- | លោក | **មាស គីមហេង** | អនុប្រធាននាយកដ្ឋានវិភាគ និងគ្រប់គ្រងហានិភ័យបំណុល |
| ៨- | លោកស្រី | **គុណា ម៉ាលីនាថ** | អនុប្រធាននាយកដ្ឋានមូលបត្ររដ្ឋ |
| ៩- | លោក | **សេង សេរីរដ្ឋ** | ប្រធានការិយាល័យគ្រប់គ្រងហានិភ័យ |
| ១០- | កញ្ញា | **លឹម លីចេង** | មន្ត្រីនៃនាយកដ្ឋានវិភាគ និងគ្រប់គ្រងហានិភ័យបំណុល |
| ១១- | កញ្ញា | **ធឿន វត្តីឆត្រីស្ទីនា** | មន្ត្រីនៃនាយកដ្ឋានវិភាគ និងគ្រប់គ្រងហានិភ័យបំណុល |
| ១២- | លោកស្រី | **គង់ យ៉ាដា** | មន្ត្រីនៃនាយកដ្ឋានមូលបត្ររដ្ឋ |
| ១៣- | លោក | **សៀម ពេជ្រណារុះ** | មន្ត្រីនៃនាយកដ្ឋានមូលបត្ររដ្ឋ |
| ១៤- | លោក | **អ៊ុន ពិសិដ្ឋ** | មន្ត្រីនៃនាយកដ្ឋានមូលបត្ររដ្ឋ |
| ១៥- | លោក | **ប៉ែន ម៉ុនថង** | មន្ត្រីនៃនាយកដ្ឋានវិភាគ និងគ្រប់គ្រងហានិភ័យបំណុល |
| ១៦- | កញ្ញា | **អៀវ គីរីតីនីតា** | មន្ត្រីនៃនាយកដ្ឋានវិភាគ និងគ្រប់គ្រងហានិភ័យបំណុល |
| ១៧- | លោកស្រី | **សេង សុផាវឌី** | មន្ត្រីជំនាញផ្នែកវិភាគ និងគ្រប់គ្រងហានិភ័យបំណុល |
| ១៨- | កញ្ញា | **ផេងផល ចន្ទ្រីកា** | មន្ត្រីជំនាញផ្នែកវិភាគ និងគ្រប់គ្រងហានិភ័យបំណុល |
| ១៩- | កញ្ញា | **លុយ សិរីបញ្ញា** | មន្ត្រីជំនាញផ្នែកវិភាគ និងគ្រប់គ្រងហានិភ័យបំណុល |
| ២០- | កញ្ញា | **ហោ គីមម៉ី** | មន្ត្រីជំនាញផ្នែកវិភាគ និងគ្រប់គ្រងហានិភ័យបំណុល |
| ២១- | លោក | **គា នៃហុង** | មន្ត្រីជំនាញផ្នែកមូលបត្ររដ្ឋ |

ទាញយកឯកសារ
តាមរយៈ QR Code

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
អាសយដ្ឋាន៖ ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ, រាជធានីភ្នំពេញ
Website: www.mef.gov.kh
Email: admin@mef.gov.kh
Hotline: (855) 23 890 666